Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា
ខែមិថុនា ឆ្នាំ២០២៤

THE WORLD BANK
IBRD • IDA | WORLD BANK GROUP
East Asia & Pacific

# ការងើបឡើងវិញនៃការនាំចេញ និង បម្រែបម្រួលពាណិជ្ជកម្មរបស់កម្ពុជា




## ប្រធានបទពិសេស

ពង្រឹងប្រព័ន្ធអប់រំរបស់កម្ពុជា
ដើម្បីកំណើននាពេលអនាគត

បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា

ខែមិថុនា ឆ្នាំ ២០២៤

# ការរើបឡើងវិញនៃការនាំចេញ និង បម្រែបម្រួលពាណិជ្ជកម្មរបស់កម្ពុជា

## ប្រធានបទពិសេស

## ពង្រឹងប្រព័ន្ធអប់រំរបស់កម្ពុជា ដើម្បីកំណើននាពេលអនាគត

THE WORLD BANK
IBRD • IDA | WORLD BANK GROUP
East Asia & Pacific

# តារាងមាតិកា


**សេចក្ដីថ្លែងអំណរគុណ . . . v**

**អក្សរកាត់ និងពាក្យកាត់ . . . vi**

**ផ្នែកទី១ ៖ ការអភិវឌ្ឍសេដ្ឋកិច្ចនាពេលបច្ចុប្បន្ននិងទស្សនវិស័យ . . . 1**

**សេចក្ដីសង្ខេប . . . 2**

ការអភិវឌ្ឍកាលពីពេលថ្មីៗនេះ . . . 2

ទស្សនវិស័យ . . . 4

ជម្រើសគោលនយោបាយ . . . 4

**ការអភិវឌ្ឍថ្មីៗ . . . 8**

សកម្មភាពសេដ្ឋកិច្ចមានការកើនឡើង . . . 8

ចំនួនភ្ញៀវទេសចរអន្តរជាតិដែលមកដល់កម្ពុជាមានការកើនឡើង . . . 10

ចំនួនភ្ញៀវទេសចរបរទេសដែលមកទស្សនាខេត្តសៀមរាប នៅតែមានចំនួនតិចជាងកាលពីមុនឆ្នាំ ២០១៩ . . . 11

ការនាំចេញទំនិញស្ទុះឡើង . . . 12

អាស៊ានបានក្លាយជាទីផ្សារនាំចេញធំទី ២ របស់កម្ពុជា . . . 12

ចំនួនការងារក្នុងវិស័យកម្មន្តសាលកើនឡើង ដោយសារការពង្រីកការនាំចេញផលិតផល GTF . . . 13

តម្លៃគម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តស្ទុះឡើង . . . 14

ការអភិវឌ្ឍអចលនទ្រព្យបន្តនៅទ្រឹង . . . 15

ការនាំចូលសម្ភារសំណង់ទូទៅងើបឡើង . . . 16

ផលិតកម្មដំណាំកើនឡើង . . . 18

កម្ពុជាកំពុងប្រែក្លាយទៅជាប្រទេសនាំចេញកសិផលដ៏សំខាន់មួយ . . . 18

ចាំបាច់ត្រូវកែលម្អបរិយាកាសធុរកិច្ចឱ្យកាន់តែប្រសើរឡើង . . . 19

ការប្រើប្រាស់ដោយវិស័យឯកជនមានភាពប្រសើរឡើងបន្តិច . . . 20

អតិផរណាធ្លាក់ដល់ ០ ក្នុងរយៈពេល ១២ ខែ គិតត្រឹមដំណាច់ខែ មីនា ឆ្នាំ ២០២៤ . . . 21

២០២៣ជាឆ្នាំដែលមានអតិរេកគណនីចរន្តខ្ពស់មិនធ្លាប់មាន . . . 23

ប្រាក់រៀលឡើងថ្លៃធៀបនឹងរូបិយប័ណ្ណក្នុងតំបន់ . . . 24

ការផ្គត់ផ្គង់រូបិយវត្ថុកើនឡើងបន្តិច . . . 25

អត្រាការប្រាក់ក្នុងស្រុកនៅតែខ្ពស់ . . . 25

ឥណទានស្រុតចុះយ៉ាងគំហុក ដោយសារភាពជាប់គាំងនៃសកម្មភាពអភិវឌ្ឍន៍លំនៅដ្ឋាន . . . 26

ឥណទានកំពុងងាកចេញពីវិស័យអចលនទ្រព្យ ឆ្ពោះទៅរកវិស័យពាណិជ្ជកម្ម និងកសិកម្ម . . . 26

ការប្រមូលចំណូលក្នុងស្រុកនៅតែថមថយ . . . 27

ចំណាយថវិកាកើនក្នុងកម្រិតសមរម្យ . . . 27

ឱនភាពសារពើពន្ធជារួមរីកធំ . . . 28

ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់នៅបន្ត . . . 29

ទំហំបំណុលសាធារណៈកើនដល់ ៣៥,៥ ភាគរយនៃផសស . . . 29

កម្ពុជានៅតែមានហានិភ័យទាបនៃសម្ពាធបំណុលខាងក្រៅ និងជារួម . . . 31

**ចក្ខុវិស័យ . . . 31**

**បញ្ហាប្រឈម និងហានិភ័យ . . . 31**

**ជម្រើសគោលនយោបាយ . . . 32**

**ផ្នែកទី២ ៖ ការពង្រឹងប្រព័ន្ធអប់រំរបស់កម្ពុជាដើម្បីកំណើននាពេលអនាគត . . . 35**

សេចក្ដីផ្ដើម . . . 37

លទ្ធភាពទទួលបាន និងសមធម៌ក្នុងការអប់រំ . . . 38

ការចំណាយលើការអប់រំ និងលទ្ធផលសិក្សា . . . 41

ប្រសិទ្ធភាពគ្រូបង្រៀន . . . 44

**អនុសាសន៍ . . . 47**

**ឧបសម្ព័ន្ធ. កម្ពុជា – សូចនាករសំខាន់ៗ . . . 50**

**គន្ថនិទ្ទេស . . . 53**

# ប្រអប់


**ប្រអប់ទី ១.** ការអភិវឌ្ឍសេដ្ឋកិច្ច និងទស្សនវិស័យសេដ្ឋកិច្ចសកល . . . 9
**ប្រអប់ទី ២.** អង្កេតសហគ្រាសឆ្នាំ ២០២៣ ដោយធនាគារពិភពលោក . . . 17
**ប្រអប់ទី ៣.** អតិរេកគណនីចរន្ត ឆ្នាំ ២០២៣ . . . 22


# រូបភាព


**រូប ES.១.** សង្ខេបការអភិវឌ្ឍថ្មីៗនៅកម្ពុជា . . . 7
**រូប B.១.១.** កំណើនសកល . . . 10
**រូប B.១.២.** កំណើនពាណិជ្ជកម្មទំនិញសកល . . . 10
**រូប ១.** សេដ្ឋកិច្ចបន្តងើបឡើងការរួមចំណែកដល់កំណើន ផសស ពិត . . . 11
**រូប ២.** ការមកដល់នៃភ្ញៀវទេសចរណ៍ និងចំណូលពីទេសចរណ៍ ក្នុងរយៈពេល ៣ ខែ . . . 11
**រូប ៣.** ការរួមចំណែកដល់កំណើនការនាំចេញបែងចែកតាមផលិតផល . . . 12
**រូប ៤.** ការរួមចំណែកដល់កំណើនការនាំចេញបែងចែកតាមទីផ្សារ . . . 12
**រូប ៥.** ចំនួនការងារ និងរោងចក្រក្នុងវិស័យកម្មន្តសាល . . . 13
**រូប ៦.** ចំនួនការងារក្នុងឧស្សាហកម្មសំលៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង . . . 13
**រូប ៧.** តម្លៃគម្រោង QIP ដែលត្រូវបានអនុម័ត . . . 14
**រូប ៨.** គម្រោងទទួលបានហិរញ្ញប្បទានពីការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត បែងចែកតាមវិស័យ . . . 14
**រូប ៩.** លិខិតអនុញ្ញាតគម្រោងអចលនទ្រព្យដែលត្រូវបានអនុម័ត . . . 15
**រូប ១០.** ផ្ទៃក្រឡាក្នុងលិខិតអនុញ្ញាតដែលត្រូវបានអនុម័ត បែងចែកតាមប្រភេទអចលនទ្រព្យ . . . 15
**រូប ១១.** ការនាំចេញផលិតផលកសិកម្មក្នុងរយៈពេល ៣ ខែ . . . 16
**រូប ១២.** ចំណែកនៃការនាំចេញផលិតផលកសិកម្ម . . . 16
**រូប B.២.១.** របាំងធំៗទាំង ៥ ក្នុងឆ្នាំ ២០២៣ . . . 18
**រូប ១៣.** អង្កេតសហគ្រាសឆ្នាំ ២០២៣-ការប្រៀបធៀបក្នុងតំបន់ . . . 19
**រូប ១៤.** អង្កេតសហគ្រាសសម្រាប់កម្ពុជារបាំងធំៗ ១០ក្នុងបរិយាកាសធុរកិច្ច . . . 19
**រូប ១៥.** ការនាំចូលទំនិញប្រើប្រាស់ មានភាពប្រសើរឡើង . . . 20
**រូប ១៦.** អតិផរណា ថយចុះការរួមចំណែកដល់អតិផរណារយៈពេល ១២ ខែ . . . 20
**រូប ១៧.** អតិរេកគណនីចរន្ត គឺខ្ពស់មិនធ្លាប់មាន . . . 21
**រូប ១៨.** ប្រាក់រៀលឡើងថ្លៃ ធៀបនឹងរូបិយវត្ថុក្នុងតំបន់ . . . 21
**រូប B.៣.១.** គណនីចរន្ត . . . 23
**រូប B.៣.២.** ការជួញដូរមាសសរុប . . . 23
**រូប ១៩.** កំណើនរូបិយវត្ថុទូទៅ ងើបឡើងវិញការរួមចំណែកដល់កំណើនរូបិយវត្ថុទូទៅ . . . 25
**រូប ២០.** អត្រាការប្រាក់នៅតែខ្ពស់អត្រាការប្រាក់ក្នុងស្រុក . . . 25
**រូប ២១.** កំណើនឥណទានក្នុងស្រុក ថយចុះ . . . 27
**រូប ២២.** វិភាជឥណទានក្នុងស្រុកងាកទៅផ្តល់ហិរញ្ញប្បទានដល់វិស័យពាណិជ្ជកម្ម និងកសិកម្ម . . . 27
**រូប ២៣.** ចំណូលក្នុងស្រុក ថយចុះចំណូលក្នុងស្រុកទូទៅរបស់រដ្ឋាភិបាល . . . 28
**រូប ២៤.** ចំណាយនៅតែត្បិតត្បៀតចំណាយទូទៅរបស់រដ្ឋាភិបាល . . . 28

**រូប ២៥.** ប្រតិបត្តិការទូទៅរបស់រដ្ឋាភិបាល . . . . . 29
**រូប ២៦.** អតិរេក/ឱនភាពទូទៅរបស់រដ្ឋាភិបាល និងហិរញ្ញប្បទាន . . . . . 29
**រូប S.១.** អត្រាពិតនៃការសិក្សា បែងចែកតាមកម្រិតសាលា . . . . . 38
**រូប S.២.** មូលហេតុនៃការមិនចុះឈ្មោះចូលរៀន . . . . . 38
**រូប S.៣.** អត្រាពិតនៃការសិក្សា តាមយេនឌ័រ ទីតាំង និងស្ថានភាពសង្គមកិច្ច-សេដ្ឋកិច្ច បែងចែកតាមកម្រិតសាលា ឆ្នាំ ២០១៩ . . 39
**រូប S.៤.** អត្រាពិតនៃការសិក្សា បែងចែកតាមតំបន់ ឆ្នាំ ២០០៩-១៩ . . . . . 39
**រូប S.៥.** អត្រាពិតនៃការសិក្សា បែងចែកតាមបញ្ចភាគទ្រព្យសម្បត្តិ (លើបំផុត និងក្រោមបំផុត) ឆ្នាំ ២០០៩-១៩ . . . . . 40
**រូប S.៦.** អត្រាពិតនៃការសិក្សា បែងចែកតាមយេនឌ័រ ឆ្នាំ ២០០៩-១៩ . . . . . 40
**រូប S.៧.** អត្រាចុះឈ្មោះចូលរៀនរបស់កុមារតូច បែងចែកតាមអាយុ . . . . . 41
**រូប S.៨.** ចំណាយសាធារណៈលើការអប់រំ (% នៃ ផសស), ២០១១-២១ . . . . . 42
**រូប S.៩.** ចំណាយរបស់ក្រសួងអប់រំ យុវជន និងកីឡា បែងចែកជាប្រភេទ (% នៃចំណាយសរុបរបស់ក្រសួង), ២០១១-២១ . . . 42
**រូប S.១០.** ចំណែកនៃសិស្សថ្នាក់ទី ៥ ដែលស្ទាត់ខាងគណិតវិទ្យា និងអំណាន, SEA-PLM ២០១៩ . . . . . 42
**រូប S.១១.** ភាគរយនៃសិស្សថ្នាក់ទី ៥ ដែលស្ទាត់ជំនាញផ្នែកអំណាន និងគណិតវិទ្យា តាមការបង្ហាញក្នុងអង្កេតសង្គមកិច្ច-សេដ្ឋកិច្ច (SES) . . . . . 43
**រូប S១២.** ពិន្ទុតេស្តសិស្សនៅថ្នាក់ជាតិ (រង្វាយតម្លៃការសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី ៦), ២០១៣-២១. . . . . 44
**រូប S១៣.** ឱនភាព/អតិរេកគ្រូបង្រៀនសរុប បែងចែកតាមតំបន់ . . . . . 45
**រូប S១៤.** លទ្ធផល PISA បែងចែកតាមទីតាំង . . . . . 45

# តារាង

**តារាង ES.១.** ទស្សនវិស័យនៅកម្រិតម៉ាក្រូ . . . . . 4
**តារាង B.២.១.** លទ្ធផលរកឃើញពីអង្កេតសហគ្រាស . . . . . 18
**តារាង ១.** សមាសភាគនៃកម្មវិធីកញ្ចប់គ្រួសារ. . . . . 30
**តារាង ២.** ចក្ខុវិស័យម៉ាក្រូបញ្ជាក់ពីការបន្តដើបឡើងនៃសេដ្ឋកិច្ច . . . . . 33

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា (CEU) ខែមិថុនា ឆ្នាំ ២០២៤ ត្រូវបានរៀបចំឡើងដោយ Lauri Pynnonen, Lars M. Sondergaard, Tara Beteille, និង Saurav Katwal ដោយមានការផ្តល់មតិយោបល់ដោយ Samuel Christopher Hill, Kimsun Tong, Faya Hayati, Tsuyoshi Fukao, Fata No, និង Runsinarith Phim។ ហ៊ាវ ចាន់កេសី បំពេញតួនាទីជាជំនួយការស្រាវជ្រាវ។ ហេង សៀកហៀង ផ្តល់ការគាំទ្រផ្នែករដ្ឋបាល។ ប៊ូ សារឿន ជួយការងារចេញសេចក្តីប្រកាសព័ត៌មាន ការផ្សាយព័ត៌មានតាមរយៈគេហទំព័រ និងការរៀបចំកម្មវិធីផ្សព្វផ្សាយ។

ក្រុមការងារ ធ្វើការក្រោមការណែនាំជារួមរបស់ Sebastian Eckardt និង Cristian Aedo។ ក្រុមការងារសូមថ្លែងអំណរគុណចំពោះដំបូន្មាន និងមតិយោបល់ដែលផ្តល់ដោយ Lalita M. Moorty, Mariam Sherman, និង Maryam Salim។ សហការីជាច្រើន ដូចជា Aaditya Mattoo និង Ergys Islamaj បានផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍នេះ។

ក្រុមការងារ សូមថ្លែងអំណរគុណដល់អាជ្ញាធរកម្ពុជា ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ដែលបានចូលរួមសហការ និងផ្តល់ការគាំទ្រ។ អាជ្ញាធរទាំងនេះ ទើបតែបានកែសម្រួលមូលដ្ឋានគណនាផលិតផលសរុបក្នុងស្រុក (ផ.ស.ស) របស់កម្ពុជា។ ទិន្នន័យ ផ.ស.ស ដែលបានកែសម្រួលមូលដ្ឋានសម្រាប់គណនា នឹងត្រូវយកមកប្រើប្រាស់នៅក្នុងរបាយការណ៍ CEU បន្ទាប់។ របាយការណ៍នេះក៏ទទួលបានដំបូន្មាន មតិយោបល់ និងទស្សនៈពីអ្នកពាក់ព័ន្ធជាច្រើននៅកម្ពុជា រួមទាំងមិត្តអ្នកអាន និងអ្នកផ្តល់មតិរិះគន់ផងដែរ។

របាយការណ៍ CEU ដែលត្រូវបានរៀបចំឡើង ២ ដងក្នុងមួយឆ្នាំ ផ្តល់ព័ត៌មានបច្ចុប្បន្នភាពអំពីការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា។ របាយការណ៍នេះត្រូវបានផ្សព្វផ្សាយ និងពិភាក្សាយ៉ាងទូលំទូលាយ ដូចជាក្នុងចំណោមអាជ្ញាធរកម្ពុជា ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ក្រុមធនាគារគំនិត អង្គការសង្គមស៊ីវិល និងស្ថាប័នសិក្សាស្រាវជ្រាវ។

សម្រាប់មើលព័ត៌មានអំពីធនាគារពិភពលោក និងសកម្មភាពរបស់ធនាគារពិភពលោកនៅកម្ពុជា សូមចូលលើគេហទំព័ររបស់យើង www.worldbank.org/cambodia។

ដើម្បីមានឈ្មោះ នៅក្នុងបញ្ជីផ្សព្វផ្សាយរបាយការណ៍ CEU និងឯកសារបោះពុម្ពផ្សាយដែលពាក់ព័ន្ធតាមអ៊ីមែល សូមទាក់ទងទៅកាន់ ហេង សៀកហៀង (sheng៤@worldbank.org)។ សម្រាប់សំណួរផ្សេងៗអំពីខ្លឹមសារនៃរបាយការណ៍នេះ សូមទាក់ទង ប៊ូ សារឿន (sbou@worldbank.org)។

របកគំឃើញ ការបកស្រាយ និងសេចក្តីសន្និដ្ឋាន ដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍នេះ មិនឆ្លុះបញ្ចាំងជាចាំបាច់ពីទស្សនៈរបស់នាយកប្រតិបត្តិនៃធនាគារពិភពលោក ឬរដ្ឋាភិបាលដែលតំណាងដោយនាយកប្រតិបតិទាំងនេះនោះឡើយ។ ធនាគារពិភពលោក ពុំធានាសុក្រឹតភាពនៃទិន្នន័យដែលត្រូវបានបញ្ចូលក្នុងរបាយការណ៍នេះឡើយ។ ព្រំដែន ពណ៌សម្បុរ ឈ្មោះប្រទេស និងដែនដី ព្រមទាំងព័ត៌មានដទៃទៀត ដែលត្រូវបានបង្ហាញលើផែនទីណាមួយក្នុងរបាយការណ៍នេះ មិនមែនជាការបង្ហាញពីការវិនិច្ឆ័យរបស់ធនាគារពិភពលោក លើស្ថានភាពស្របច្បាប់របស់ដែនដីណា ឬជាការផ្តល់ការយល់ព្រម ឬការទទួលយកព្រំប្រទល់នៃដែនដីទាំងនេះនោះឡើយ។

# អក្សរកាត់ និងពាក្យកាត់

| | |
|---|---|
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CEU | របាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា |
| COVID-១៩ | ជំងឺបង្កឡើងដោយវីរុសកូរ៉ូណា ឆ្នាំ ២០១៩ |
| CPI | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ |
| CSES | ការសង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា |
| EAP | តំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក |
| ECE | ការអប់រំកុមារ |
| EU | សហភាពអឺរ៉ុប |
| FDI | ការវិនិយោគដោយផ្ទាល់ពីបរទេស |
| FP | កញ្ចប់គ្រួសារ |
| ផ.ស.ស | ផលិតផលសរុបក្នុងស្រុក |
| GTF | សំលៀកបំពាក់ ទំនិញសម្រាប់ការធ្វើដំណើរ និងស្បែកជើង |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MFI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| NBC | ធនាគារជាតិនៃកម្ពុជា |
| NLA | ការវាយតម្លៃលើការរៀនសូត្រនៅថ្នាក់ជាតិ |
| PISA | កម្មវិធីវាយតម្លៃសិស្សអន្តរជាតិ |
| QIP | គម្រោងវិនិយោគដែលបំពេញតាមលក្ខណៈសម្បត្តិគ្រប់គ្រាន់ |
| SEA-PLM ២០១៩ | របាយការណ៍ស្តីពីរង្វាស់ការរៀនសូត្រនៅកម្រិតបឋមសិក្សានៅអាស៊ីអាគ្នេយ៍ ឆ្នាំ ២០១៩ |
| TVET | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| UN | អង្គការសហប្រជាជាតិ |
| U.S. | សហរដ្ឋអាមេរិក |
| US$ | ដុល្លារសហរដ្ឋអាមេរិក |
| VAT | អាករលើតម្លៃបន្ថែម |
| y/y | ធៀបនឹងឆ្នាំមុន |

# ផ្នែកទី១ ៖

# ការអភិវឌ្ឍសេដ្ឋកិច្ច នាពេលបច្ចុប្បន្ន និងទស្សនវិស័យ



# សេចក្ដីសង្ខេប

## *ការអភិវឌ្ឍកាលពីពេលថ្មីៗនេះ*

**សកម្មភាពសេដ្ឋកិច្ចនៅកម្ពុជា មានការកើនឡើងនៅត្រីមាសទី ១ ឆ្នាំ ២០២៤ ដោយមានការជំរុញភាគច្រើន ដោយសារការនាំចេញទំនិញ និងសេវាកម្ម។** ខណៈពេលដែលតម្រូវការក្នុងស្រុកនៅបន្តថមថយ ព្រោះតែការធ្លាក់ចុះយ៉ាងគំហុកនៃកំណើនឥណទានក្នុងស្រុក ដោយសារផលប៉ះពាល់នៃឱនភាពទីផ្សារអចលនទ្រព្យ និងការរឹតបន្តឹងលក្ខខណ្ឌហិរញ្ញវត្ថុ រួមទាំងការបង្កើនអត្រាការប្រាក់ ការនាំចេញទំនិញ និងសេវាកម្មមានការកើនឡើង។ ចំនួនភ្ញៀវទេសចរបរទេសមកកាន់កម្ពុជា ក៏បន្តមានការកើនឡើងផងដែរ ទិន្នន័យដែលទទួលបានបង្ហាញថា ក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤ ការនាំចេញផ្នែកសេវាកម្មមានការកើនឡើងយ៉ាងឆាប់រហ័ស ដោយចំនួនភ្ញៀវទេសចរអន្តរជាតិចូលមកក្នុងប្រទេសកម្ពុជាកើនឡើង ២២,៥ ភាគរយបើធៀបនឹងឆ្នាំមុន (y/y) ដល់ ៨៤,២ ភាគរយ នៃចំនួនភ្ញៀវទេសចរមកដល់ ដែលត្រូវបានកត់ត្រាក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១៩។ ជាការបង្ហាញពីកំណើនចំណូលពីវិស័យទេសចរណ៍ ចំណូលពីថ្លៃលក់សំបុត្រចូលទស្សនាប្រាសាទអង្គរវត្ត មានការកើនឡើងយ៉ាងឆាប់រហ័ស ពោលគឺ ៩៥,៩ ភាគរយបើធៀបនឹងឆ្នាំមុនក្នុងរយៈពេលដូចគ្នានេះ កើនឡើងដល់ ៥៨,៧ ភាគរយនៃកម្រិតកាលពីឆ្នាំ ២០១៩។

**ការនាំចេញទំនិញក៏ចាប់ផ្ដើមមានការកើនឡើងផងដែរ ទន្ទឹមពេលដែលតម្រូវការនៅក្រៅប្រទេសមានភាពប្រសើរជាងមុន។** ការនាំចេញទំនិញមានការកើនឡើងនៅក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤ ពោលគឺកើនឡើង ១៧,២ ភាគរយបើធៀបនឹងឆ្នាំមុន ដល់ ៦,៣ ប៊ីលានដុល្លារ។ កំណើននេះមួយភាគធំដោយសារតែការងើបឡើងវិញនៃការនាំចេញផលិតផលសម្លៀកបំពាក់ ទំនិញសម្រាប់ការធ្វើដំណើរ និងស្បែកជើង (GTF) ទៅកាន់ទីផ្សារនៅសហរដ្ឋអាមេរិក (U.S.) និងសហភាពអឺរ៉ុប (EU)។ កំណើនអតិផរណាមិនមែន GTF ដូចជាទំនិញកសិកម្ម អេឡិចត្រូនិក អគ្គិសនី ស្បែក និងផលិតផលធ្វើពីឈើ ដូចជាសង្ហារិមជាដើម បន្តមានភាពធន់។ កម្ពុជាបានក្លាយខ្លួនជាអ្នកនាំចេញកសិផលមួយ ក្នុងចំណោមប្រទេសនាំចេញកសិផលធំៗ ហើយបច្ចុប្បន្ននេះបានក្លាយទៅជាប្រទេសមួយក្នុងចំណោមប្រទេសផលិតអង្ករច្រើនជាងគេទាំង ៩ នៅក្នុងពិភពលោក។ ការនាំចេញកសិផលកើនឡើងជិត ៤ ដងក្នុងទសវត្សរ៍ចុងក្រោយនេះ។

**ចាប់តាំងពីឆ្នាំ ២០២៣ មកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) បានវ៉ាទីផ្សារសហភាពអឺរ៉ុប និងបានក្លាយជាទីផ្សារនាំចេញធំជាងគេទី ២ របស់កម្ពុជា។** នៅក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤ ការនាំចេញទៅកាន់ប្រទេសអាស៊ានស្មើនឹង ២៨,០ ភាគរយនៃការនាំចេញសរុបរបស់កម្ពុជា កើនឡើងពី ២៤,៧ ភាគរយក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០២៣ (និង ១៤,៦ ភាគរយក្នុងឆ្នាំ ២០២២)។ នៅក្នុងត្រីមាសទី ១ ឆ្នាំ ២០២៤ ទីផ្សារអាស៊ានកើនឡើង ៣៣,១ ភាគរយបើធៀបនឹងឆ្នាំមុន ដោយនាំចូលផលិតផលកសិកម្ម ៨៥ ភាគរយនៃទំនិញកសិកម្មនាំចេញសរុបរបស់កម្ពុជា។ ទំនិញកសិកម្ម សំខាន់ៗ រួមមានអង្ករ ដំឡូងមី គ្រាប់ស្វាយចន្ទី និងកៅស៊ូ។ ការនាំចេញផលិតផលកសិកម្មកម្ពុជាកើនឡើងនៅត្រីមាសទី ១ ឆ្នាំ ២០២៤ នៅកម្រិត ២៨,១ ភាគរយបើធៀបនឹងឆ្នាំមុន កើនឡើងដល់ ១,១ ប៊ីលានដុល្លារ ឬ ១៧,៤ ភាគរយនៃការនាំចេញទំនិញសរុប ឈរនៅកម្រិតទី ២ បន្ទាប់ពីការនាំចេញសម្លៀកបំពាក់ដែលស្មើនឹង ២ ប៊ីលានដុល្លារ។

**ទន្ទឹមនឹងសមិទ្ធកម្មពាណិជ្ជកម្មដ៏រឹងមាំ ការវិនិយោគដោយផ្ទាល់ពីបរទេស នៅក្នុងវិស័យដែលអាចជួញដូរបាននៅតែបន្តមានភាពធន់។** តម្លៃនៃការវិនិយោគក្រោមហិរញ្ញប្បទានពី (FDI) (ក្រៅតំបន់សេដ្ឋកិច្ចពិសេស) ក្រោមរបបគម្រោងវិនិយោគដែលបំពេញតាមលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) មានការកើនឡើងដល់ ៤៥៥ លានដុល្លារ ឬជាការកើនឡើងដល់ ១៤៩,៨ ភាគរយធៀបនឹងឆ្នាំមុននៅក្នុងត្រីមាសទី ១ ឆ្នាំ ២០២៤។

**ផ្ទុយទៅវិញ សកម្មភាពនៅក្នុងវិស័យសំណង់ និងអចលនទ្រព្យនៅបន្តថមថយ។** ការផ្ដល់ឥណទាន ក្នុងស្រុកដល់វិស័យអចលនទ្រព្យ មានការថមថយគួរឱ្យកត់សម្គាល់។ ការកែតម្រូវទីផ្សារលំនៅឋាននៅតែបន្តមាន មួយផ្នែកធំដោយសារតែការកើនឡើងគួរឱ្យកត់សម្គាល់នូវការផ្គត់ផ្គង់ ក្នុងអំឡុងពេលដែលវិស័យសំណង់រីកចម្រើនខ្លាំង នៅមុនពេលដែលមានការឆ្លងរាតត្បាតនៃជំងឺកូវីដ ១៩ ដោយសារកំណើនការប្រាក់។ តម្លៃនៃគម្រោងអភិវឌ្ឍអចលនទ្រព្យដែលបានទទួលការអនុម័តថយចុះ ៣៨,៨ ភាគរយធៀបនឹងឆ្នាំមុន ក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤ ដែលបង្ហាញពីការថយចុះនូវចំណាប់អារម្មណ៍របស់វិនិយោគិន ក្នុងការវិនិយោគលើវិស័យអចលនទ្រព្យ។

**គណនីចរន្តមានភាពប្រសើរ ដ្បិតឱនភាពពាណិជ្ជកម្មបានរួមតូច។** ខណៈពេលដែលការនាំចេញទំនិញមានការកើនឡើង ការនាំចូលទំនិញបន្តកើនឡើងតិចតួចប៉ុណ្ណោះស្មើនឹង ៦,៣៩ ប៊ីលានដុល្លារ ឬកើនឡើង ៩,០ ភាគរយធៀបនឹងឆ្នាំមុន ដែលឆ្លុះបញ្ចាំងពីការថមថយនៃតម្រូវការក្នុងស្រុក។ ការថយចុះនៃឱនភាពពាណិជ្ជកម្ម រួមទាំងការកើនឡើងនៃការផ្ញើប្រាក់ពីបរទេស និងចំណូលពីវិស័យ ទេសចរណ៍ ជួយឱ្យតុល្យភាពនៃគណនីចរន្តកាន់តែមានភាពប្រសើរកើនឡើងដល់កម្រិតអតិរេកមិនធ្លាប់មានកន្លងមកស្មើនឹង ១,៧ ភាគរយនៃ ផ.ស.ស កាលពីឆ្នាំ ២០២៣។

**សមិទ្ធកម្មវិស័យខាងក្រៅប្រសើរជាងមុន បានជួយរក្សាស្ថិរភាពអត្រាប្តូរប្រាក់។** អត្រាប្តូរប្រាក់បន្តនៅប្រហាក់ប្រហែលនឹង ៤.១០០ រៀលក្នុង ១ ដុល្លារ អាមេរិក។ ក្នុងពេលជាមួយគ្នា ទុនបម្រុងអន្តរជាតិសរុបបានកើនឡើងដល់ ១៩,៩ ប៊ីលានដុល្លារ - ជាការកើនឡើង ១១,៧ ភាគរយធៀបនឹងឆ្នាំមុន កាលពីឆ្នាំ ២០២៣។ ទុនបម្រុងអន្តរជាតិសរុបរបស់កម្ពុជា ត្រូវបានប៉ាន់ប្រមាណថា មានកម្រិតសមមូលនឹងការនាំចូលរយៈពេល ៩ ខែ។ ខណៈពេលដែលថ្លៃទំនិញមានការថមថយដោយសារតែតម្រូវការក្នុងស្រុកថយចុះ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) របស់កម្ពុជាធ្លាក់ដល់សូន្យកាលពីខែមីនា ឆ្នាំ ២០២៤ ជាកម្រិតទាបបំផុតក្នុងរយៈពេល ១៥ ឆ្នាំកន្លងទៅនេះ។ ការបន្ធូរបន្ថយនៃថ្លៃស្បៀងអាហារ ជាពិសេសអង្ករ សាច់ ត្រី និងបន្លែ ធ្វើឱ្យអតិផរណាមានការថយចុះ ដ្បិតសមាសភាគស្បៀងអាហារ (សន្ទស្សន៍រង) ស្រូបយកមេគុណនៃសន្ទស្សន៍អតិផរណាអស់ ៤៣ ភាគរយ។

**ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ធនាគារកណ្តាលបានកាត់បន្ថយអនុបាតតម្រូវការទុនបម្រុងជារូបិយប័ណ្ណអន្តរជាតិ ២ ភាគរយមកនៅ ៧ ភាគរយកាលពីខែធ្នូ ឆ្នាំ ២០២៣ ជាការកាត់បន្ថយច្រើនជាងគេក្រោយការរាតត្បាតនៃជំងឺកូវីដ ១៩។** កាលពីពេលថ្មីៗនេះ ក៏មានការកើនឡើងនូវការផ្គត់ផ្គង់រូបិយប័ណ្ណផងដែរ ដែលបង្ហាញពីភាពល្អប្រសើរនៃលំហូរចូលនៃមូលធន។ រូបិយវត្ថុទូទៅ (Broad money) កើនឡើងវិញ ១៤,៩ ភាគរយ ធៀបនឹងឆ្នាំមុន កាលពីខែកុម្ភៈ ឆ្នាំ ២០២៤ កើនឡើងពី ៦,៨ ភាគរយក្នុងរយៈពេលដូចគ្នា កាលពីឆ្នាំ ២០២៣ ដ្បិតការដាក់ប្រាក់បញ្ញើជារូបិយប័ណ្ណអន្តរជាតិមានការកើនឡើង។

**កំណើនឥណទានក្នុងស្រុក មានការថមថយគួរកត់សម្គាល់ចាប់តាំងពីពាក់កណ្តាលឆ្នាំ ២០២៣ មក។** សកម្មភាពក្នុងវិស័យសំណង់មិនសូវសកម្មធ្វើឱ្យតម្រូវការឥណទានក្នុងស្រុកមានការថយចុះ ពោលគឺធ្វើឱ្យកំណើនថមថយមកនៅត្រឹម ៤,៦ ភាគរយធៀបនឹងឆ្នាំមុន កាលពីខែកុម្ភៈ ឆ្នាំ ២០២៤ ដែលជាកម្រិតមួយទាបបំផុតក្នុងរយៈពេល ២០ ឆ្នាំចុងក្រោយ ការថយចុះពីកំណើន ១៤,៨ ភាគរយធៀបនឹងឆ្នាំមុនក្នុងរយៈពេលដូចគ្នានេះ កាលពីឆ្នាំ ២០២៣។ សម្ពាធធ្វើឱ្យអត្រាការប្រាក់ក្នុងស្រុកមានការកើនឡើងនៅតែបន្តមាន ដោយសារតែការរឹតបន្តឹងលក្ខខណ្ឌហិរញ្ញវត្ថុនៅទូទាំងសកលលោក។ អត្រាការប្រាក់របស់កម្ពុជា នៅតែបន្តកើនឡើង ដ្បិតកម្ពុជានាំចូលការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិក ដោយសារតែវិធានការទប់ស្កាត់អតិផរណារបស់ធនាគារកណ្តាលសហរដ្ឋអាមេរិក។ ការចំណាយលើប្រភពហិរញ្ញប្បទានមានការកើនឡើងសម្រាប់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា ដោយសារតែគ្រឹះស្ថានទាំងនេះចាំបាច់ត្រូវបង្កើនអត្រាការប្រាក់លើប្រាក់បញ្ញើ ដើម្បីទាក់ទាញអ្នកដាក់ប្រាក់បញ្ញើ។ នេះអាចធ្វើឱ្យការចំណាយប្រតិបត្តិការមានការកើនឡើង និងធ្វើឱ្យកម្រិតនៃប្រាក់ចំណេញរបស់គ្រឹះស្ថានទាំងនេះ មានការថយចុះ។ កាលពីឆ្នាំ ២០២៣ ផលលើទ្រព្យសកម្មថយចុះពាក់កណ្តាលមកនៅ ០,៧ ភាគរយសម្រាប់វិស័យធនាគារ និង ១,៥ ភាគរយសម្រាប់វិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFI) ថយចុះពី ១,៤ ភាគរយសម្រាប់ធនាគារ និង ៣,០ ភាគរយសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ នៅក្នុងឆ្នាំ ២០២២។ ទន្ទឹមគ្នានេះអត្រាឥណទានមិនដំណើរការ (nonperforming loan) កើនឡើងដល់ ៥,៤ ភាគរយសម្រាប់ធនាគារ កើនឡើង ២,២ ភាគរយ និងដល់ ៦,៧ ភាគរយសម្រាប់ MFIs កើនឡើងពី ២,៦ ភាគរយ។

**ចំណូលក្នុងស្រុកដែលមួយផ្នែកបានពីកំណើននៃការចំណាយរបស់អ្នកប្រើប្រាស់ ក្រោយវិបត្តិកូវីដ ១៩ ដែលកើតឡើងតែក្នុងរយៈពេលមួយខ្លី កាលពីឆ្នាំ ២០២២ បានថមថយទៅវិញគួរឱ្យកត់សម្គាល់។** ការវិនិយោគទូទៅរបស់រដ្ឋាភិបាល (រាប់បញ្ចូលទាំងការផ្តល់ឥណទានឥតសំណង) ត្រូវបានប៉ាន់ប្រមាណថាមានកម្រិតតែត្រឹម ២១,៤ ភាគរយនៃ ផ.ស.ស កាលពីឆ្នាំ ២០២៣ ប៉ុណ្ណោះ ពោលគឺថយចុះពី ២៣,៤ ភាគរយក្នុងឆ្នាំ ២០២២។ ការយកពន្ធលើទំនិញ និងសេវាកម្ម ជាពិសេសអាករលើតម្លៃបន្ថែម ពន្ធគយ និងពន្ធនាំចូលមានការថយចុះទន្ទឹមពេលដែលតម្រូវការក្នុងស្រុកមានការថយចុះ ហើយកំណើនឥណទានមានការថមថយ។ កិច្ចខិតខំប្រឹងប្រែង ដើម្បីទប់ស្កាត់ចំណាយនៅតែបន្តអនុវត្ត បើទោះជាមានសម្ពាធលើចំណាយព្រោះតែកំណើនបៀវត្សរ៍មន្ត្រីរាជការ និងការចំណាយលើការបោះឆ្នោតក៏ដោយ។ ជាលទ្ធផល ការចំណាយទូទៅរបស់រដ្ឋាភិបាលក៏មានការថមថយ ដោយគេប៉ាន់ប្រមាណថាមានកម្រិតស្មើនឹង ២៦,៧ ភាគរយនៃ ផ.ស.ស ក្នុងឆ្នាំ ២០២៣ ថយចុះពី ២៧,៧ ភាគរយនៃ ផ.ស.ស ក្នុងឆ្នាំ ២០២២។ ឱនភាពហិរញ្ញវត្ថុ (រាប់បញ្ចូលទាំងឥណទានឥតសំណង) ត្រូវបានប៉ាន់ប្រមាណថាកើនឡើង ៥,៣ ភាគរយនៃ ផ.ស.ស ក្នុងឆ្នាំ ២០២៣ ការកើនឡើងពី ៤,៤ ភាគរយក្នុងឆ្នាំ ២០២២។ ការផ្តល់ហិរញ្ញប្បទានដល់ឱនភាពហិរញ្ញវត្ថុ ដែលមានការកើនឡើងបែបនេះ ទាមទារឱ្យមានការបង្កើនការដកថវិកាពីប្រាក់តម្កល់របស់រដ្ឋាភិបាល (ធនធានបម្រុង) ដែលថយចុះមកនៅ ១៦,៤ ភាគរយ នៃ ផ.ស.ស ក្នុងឆ្នាំ ២០២៣ ពី ១៨,១ ភាគរយក្នុងឆ្នាំ ២០២២។ ទោះជាយ៉ាងនេះក្តី បំណុលសាធារណៈនៅបន្តមានកម្រិតទាបត្រឹម ៣៥,២ ភាគរយនៃ ផ.ស.ស កាលពីឆ្នាំ ២០២៣។

**ភាពងើបឡើងវិញនៃសេដ្ឋកិច្ច ជួយឱ្យមានការបង្កើតការងារ។** ចំនួនការងារនៅក្នុងវិស័យកម្មន្តសាលមានការកើនឡើង ខណៈពេលដែលចំនួនការងារនៅក្នុងវិស័យកាត់ដេរ ទំនិញសម្រាប់ធ្វើដំណើរ និងស្បែកជើង ងើបឡើងវិញ។ ស្របគ្នានឹងកំណើនការនាំចេញទំនិញ ការងារនៅក្នុងវិស័យកម្មន្តសាលក៏មានការ

កើនឡើងផងដែរ។ ការងារនៅក្នុងវិស័យកម្មន្តសាលកើនឡើងចំនួន ៥០.៥០០ ដល់ ១,០៥៨ លានការងារ (ស្មើនឹង ១៨,១ ភាគរយនៃការងារមិនមែនកសិកម្ម) ក្នុងខែមីនា ឆ្នាំ ២០២៤ ឬកើនឡើង ៥ ភាគរយបើធៀបនឹងឆ្នាំមុន។

## ទស្សនវិស័យ

**កំណើនសេដ្ឋកិច្ចឆ្នាំនេះ ត្រូវបានព្យាករណ៍ថានឹងកើនឡើងតិចតួចដល់ ៥,៨ ភាគរយ (តារាង ES.១) ដែលកត្តាជំរុញចម្បង គឺការបន្តងើបឡើងវិញនៃការនាំចេញសេវាកម្ម និងទំនិញ។** សម្លឹងទៅមុខ ភាពល្អប្រសើរនៃតុល្យភាពគណនីចរន្ត របស់កម្ពុជា ដោយសារការសម្រេចបានជោគជ័យមួយចំនួន ក្នុងការធ្វើពិពិធកម្មផលិតផលនាំចេញក្រៅតែពីលទ្ធផល GTF (ទៅរកផលិតផលកសិកម្ម ផ្ទាំងពន្លឺព្រះអាទិត្យ និងគ្រឿងបន្លាស់អគ្គិសនី និងអេឡិចត្រូនិក) ព្រមទាំងទីផ្សារនាំចេញ ក្រៅពីទីផ្សារនៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប (ទៅរកទីផ្សារតំបន់ ជាពិសេសទីផ្សារនៅអាស៊ាន) គួរជួយឱ្យការនាំចេញទំនិញមានភាពធន់។

**តារាង ES.១. ទស្សនៈវិស័យនៅកម្រិតម៉ាក្រូ**
*(ភាគរយនៃ ផ,ស,ស លើកលែងតែមានការបញ្ជាក់ផ្សេង)*

| | ការព្យាករ | | | ការប្រែប្រួលពី ខែវិច្ឆិកា ឆ្នាំ២០២៣ | |
|---|---|---|---|---|---|
| | ២០២៤ | ២០២៥ | ២០២៦ | ២០២៤ | ២០២៥ |
| **កំណើនពិត** (ភាគរយ) | ៥.៨ | ៦.១ | ៦.៤ | 0.0 | 0.0 |
| **CPI** (មធ្យមភាគនៅក្នុងរយៈពេលនេះ ភាគរយ) | ២.៨ | ២.៧ | ៣.០ | 0.0 | 0.0 |
| **គណនីចរន្ត** | ២.៧ | ២.៦ | ១.៦ | ១៤.២ | ១២.២ |
| **ឱនភាពហិរញ្ញវត្ថុជារួម** | -៥.៥ | -៤.៤ | -៤.២ | -0.៧ | -១.២ |
| **បំណុលសាធារណៈ** | ៣៥.៦ | ៣៥.៥ | ៣៤.៨ | -0.៩ | -0.៩ |

**មានការព្យាករថា កំណើនពិតរបស់កម្ពុជាកើនឡើងដល់ ៦,១ ភាគរយក្នុងឆ្នាំ ២០២៥ និង ៦,៤ ភាគរយក្នុងឆ្នាំ ២០២៦។** គេរំពឹងថាឧស្សាហកម្មទេសចរណ៍ និងបដិសណ្ឋារកិច្ចនឹងបន្តពង្រីកខ្លួនជាមួយនឹងការព្យាករពីកំណើនចំនួនទេសចរអន្តរជាតិលើសពីកម្រិតមុនពេលមានការរាតត្បាតជាសកលនៅក្នុងឆ្នាំខាងមុខនេះ ខណៈពេលដែលការនាំចេញទំនិញ និងរំហូរចូលនៃ FDI ត្រូវបានគេរំពឹងថានឹងមានការកើនឡើង តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដែលទើបទទួលបានការផ្តល់សច្ចាប័នកាលពីពេលថ្មីៗនេះ ក៏ដូចជាការកើនឡើងយ៉ាងច្រើននូវការវិនិយោគរដ្ឋ និងឯកជន លើហេដ្ឋារចនាសម្ព័ន្ធរូបវន្តសំខាន់ៗ។

## ជម្រើសគោលនយោបាយ

**បើទោះជាសេដ្ឋកិច្ចបន្តងើបឡើងវិញក៏ដោយ ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីស្តារឡើងវិញនៅលំហហិរញ្ញវត្ថុ ខណៈពេលដែលទុនបម្រុងហិរញ្ញវត្ថុមានការរួមតូច បន្ទាប់ពីរដ្ឋាភិបាលបានអនុវត្តអន្តរាគមន៍ហិរញ្ញវត្ថុ នៅក្នុងរយៈពេលជាច្រើនឆ្នាំកន្លងទៅនេះ។** ទី ១ គួរមានការពិនិត្យឡើងវិញលើរយៈពេលលើកលែងពន្ធ និងការលើកលែងពន្ធដែលកាន់តែមានការផ្តល់ការលើកទឹកចិត្តបន្ថែម។ ទី ២ ការកែទម្រង់ពន្ធចំណូលសហគ្រាស ដើម្បីពង្រីកមូលដ្ឋានពន្ធ និងពង្រឹងភាពអនុលោម គឺជាអ្វីដែលត្រូវគេធ្វើ។ ទី ៣ ការដាក់ឱ្យអនុវត្តនូវពន្ធចំណូលបុគ្គល គួរត្រូវបានកំណត់ថាជាគោលដៅរយៈពេលមធ្យមនៃយុទ្ធសាស្ត្រកៀរគរចំណូលបន្ទាប់របស់រដ្ឋាភិបាល។

**ដោយសារតែបំណុលឯកជន មានកម្រិតខ្ពស់ ការកើនឡើងនៃឥណទានមិនដំណើរការ (NPLs) និងការថយចុះនៃផលលើទ្រព្យសកម្មនៃវិស័យធនាគារ ការការពារស្ថិរភាពហិរញ្ញវត្ថុក៏នៅតែមានសារៈសំខាន់។** កំណើនដ៏ខ្លាំងនៃឥណទានកាលពីពេលថ្មីៗនេះ នាំឱ្យបំណុលនៃវិស័យឯកជនកើនឡើងខ្ពស់ប្រមូលផ្តុំនៅក្នុងវិស័យអចលនទ្រព្យ។ ដើម្បីការពារស្ថិរភាពហិរញ្ញវត្ថុ គួរមានការយកចិត្តទុកដាក់ជាបន្ទាន់លើការពង្រឹងការត្រួតពិនិត្យលើធនាគារ៖ ការធ្វើស្ត្រេសតេស្តលើគ្រឹះស្ថាននីមួយៗ, ការចុះត្រួតពិនិត្យដល់ទីតាំងក្នុងលក្ខណៈជាប្រព័ន្ធ, ការបន្តកែសម្រួលក្របខ័ណ្ឌនិយ័តកម្មឱ្យស្របតាមស្តង់ដារអន្តរជាតិ, និងការវាយតម្លៃឱ្យបានល្អិតល្អន់លើគុណភាពនៃកម្ចី ។ល។ ចំនួនគ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជាបន្តកើនឡើងយ៉ាងគំហុក រហូតដល់ឆ្នាំ ២០២២ ដូច្នេះការពង្រឹងវិស័យហិរញ្ញវត្ថុតាមរយៈការទិញយក និងការបញ្ចូលគ្រឹះស្ថានមួយចំនួនបញ្ចូលគ្នា អាចជួយរក្សាកម្រិតនៃប្រាក់ចំណេញ តាមរយៈការបង្កើនប្រសិទ្ធភាព និងចំណែកទីផ្សារ។ ដើម្បីត្រៀមឆ្លើយតបចំពោះការកើនឡើងនៃកម្រិតឥណទានមិនដំណើរការ ជាការសំខាន់ដែលត្រូវរៀបចំនូវជម្រើសដំណោះស្រាយជាស្រេចទុកដាក់ឱ្យអនុវត្ត នៅពេលដែលចាំបាច់ និងដើម្បីពង្រឹងរបបអសាធនីយ៍របស់ប្រទេសកម្ពុជា។ កិច្ចខិតខំប្រឹងប្រែង ដើម្បីរៀបចំក្របខ័ណ្ឌគតិយុត្តស្តីពីការធានារ៉ាប់រងលើប្រាក់បញ្ញើ និងដំណោះស្រាយរបស់ធនាគារ ត្រូវតែបន្តធ្វើ។

**ចាំបាច់ត្រូវមានការអនុវត្តកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតជាបន្ទាន់ ដើម្បីការកសាងបរិយាកាសធុរកិច្ចអំណោយផលដើម្បីលើកទឹកចិត្តឱ្យក្រុមហ៊ុនអនុវត្តប្រតិបត្តិការ នវានុវត្តន៍ និងបង្កើនផលិតភាពប្រកបដោយប្រសិទ្ធភាព។** ជាការចាំបាច់

ដែលត្រូវឆ្លើយតបចំពោះឧបសគ្គធំៗចំនួន ៣ ដែលគេយល់ឃើញថាកំពុងកើតមាន ដូចជា ដំណើរការនៃវិស័យក្រៅប្រព័ន្ធអត្រាពន្ធ និងរដ្ឋបាលពន្ធ ដូចដែលត្រូវបានកំណត់នៅក្នុងការអង្កេតលើសហគ្រាស ដែលធ្វើឡើងដោយធនាគារពិភពលោកកាលពីឆ្នាំ ២០២៣ តាមរយៈការជំរុញការចុះបញ្ជីពាណិជ្ជកម្មការកាត់បន្ថយបន្ទុកលើភាពអនុលោមតាមច្បាប់ពន្ធ និងការពិនិត្យឡើងវិញលើអត្រាពន្ធជាដើម។ ការអង្កេតសហគ្រាសឆ្នាំ ២០២៣ បង្ហាញថា នៅកម្ពុជា គេត្រូវការចំណាយពេល ៨,២ ថ្ងៃ ដើម្បីសុំការអនុញ្ញាតការនាំចេញផ្ទាល់ពីគយ និង ៩ ថ្ងៃ ដើម្បីយកទំនិញនាំចូលចេញពីគយ បើធៀបនឹងរយៈពេល ៤ ថ្ងៃ និង ៨,៣ ថ្ងៃនៅក្នុងប្រទេសវៀតណាម។ ដើម្បីកាត់បន្ថយរយៈពេលដែលចាំបាច់សម្រាប់នាំចូល ការពន្លឿនការអនុវត្តនីតិវិធីពិនិត្យឯកសារតាមប្រព័ន្ធអេឡិចត្រូនិក មុនពេលដែលទំនិញមកដល់ គឺជារឿងចាំបាច់បន្ទាន់ដែលត្រូវធ្វើ ព្រមទាំងការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មទាំងស្រុង ក្នុងការអនុវត្តនីតិវិធីសុំការអនុញ្ញាតពីគយ ដើម្បីផ្តល់ការអនុញ្ញាតឱ្យមានការប្រើប្រាស់ឯកសារអេឡិចត្រូនិកជាផ្លូវការ ដើម្បីបំព្រួញពេលវេលាសម្រាប់នាំចេញ។ ការអង្កេតសហគ្រាស ឆ្នាំ ២០២៣ ក៏បង្ហាញឱ្យឃើញផងដែរថា នៅកម្ពុជា គេត្រូវការពេល ២៨ ថ្ងៃ ដើម្បីទទួលបានអាជ្ញាប័ណ្ណនាំចូល និង ៣០ ដើម្បីទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិការ បើធៀបនឹងរយៈពេល ១៣,២ ថ្ងៃ និង ១០,៧ ថ្ងៃនៅវៀតណាម និង ៩ ថ្ងៃ និង ៥ ថ្ងៃនៅឥណ្ឌូនេស៊ី។

**ដូច្នេះ ការសម្រួលលក្ខខណ្ឌដែលស្មុគស្មាញ និងរឹតត្បិតលើការចុះបញ្ជីពាណិជ្ជកម្ម រួមនឹងការកែលម្អការអនុវត្តក្របខ័ណ្ឌអសាធនីយ៍ និងជួយកាត់បន្ថយការចំណាយលើការចុះបញ្ជី និងការបិទសហគ្រាស ហើយក្នុងពេលជាមួយគ្នា បង្កើនភាពអាចព្យាករដឹងមុននៃបរិយាកាសនិយតកម្ម។** ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងឱ្យបានច្រើន ដើម្បីផ្តល់សេវាកម្មធុរកិច្ចឱ្យកាន់តែមានលក្ខណៈសាមញ្ញ និងតាមប្រព័ន្ធឌីជីថល ជាពិសេសការចេញអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាត ដើម្បីកាត់បន្ថយចំណាយដែលពាក់ព័ន្ធ។ ការពន្លឿននូវការអនុវត្តឱ្យបានពេញលេញនៅដំណាក់កាលចុងក្រោយនៃបញ្ជរជាតិតែមួយ ដើម្បីបញ្ចូលការចេញអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងឯកសារដទៃទៀត គឺជាកិច្ចការដ៏ចាំបាច់។ ការពន្លឿនការអនុវត្តប្រតិបត្តិករសេដ្ឋកិច្ច ដែលមានអាជ្ញាប័ណ្ណអនុញ្ញាត ក៏ចាំបាច់ត្រូវធ្វើផងដែរ។

**ការបង្កើនលទ្ធផលនៃការរៀនសូត្រ គឺជាមូលដ្ឋានគ្រឹះ ដើម្បីអភិវឌ្ឍន៍កម្លាំងពលកម្មដែលត្រៀមខ្លួនរួចជាស្រេច "សម្រាប់អនាគត" និងជំរុញកំណើនផលិតភាពនាពេលអនាគតកម្ពុជាខណៈពេលដែលកម្ពុជាខិតខំប្រែក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ ត្រឹមឆ្នាំ ២០៣០ និងប្រទេសចំណូលខ្ពស់ ត្រឹមឆ្នាំ ២០៥០។** កំណើនផលិតភាពនៃកម្លាំងពលកម្មមានការថយចុះយ៉ាងគំហុក នៅក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ។ មានកុមារតូចនៅកម្ពុជាតិចនាក់ប៉ុណ្ណោះ ដែលបានចូលរៀននៅកម្រិតអប់រំកុមារតូច ខណៈពេលដែលលទ្ធផលនៃការរៀនសូត្រនៅកម្រិតបឋមសិក្សាមានការថមថយ។ មានសិស្សតិចនាក់ប៉ុណ្ណោះ ដែលឆ្លងភូមិសិក្សាទៅកម្រិតមធ្យមសិក្សា ហើយអ្នកដែលបានបន្តទៅរៀននៅកម្រិតមធ្យមសិក្សា ជារឿយៗពុំបានត្រៀមខ្លួនឱ្យបានគ្រប់គ្រាន់ ហើយអត្រាបោះបង់ចោលការសិក្សាមានកម្រិតខ្ពស់។ (សូមមើលផ្នែកប្រធានបទពិសេស សម្រាប់ការពិភាក្សាស៊ីជម្រៅបន្ថែមទៀតអំពីការពង្រឹងប្រព័ន្ធអប់រំកម្ពុជា ដើម្បីកំណើននាពេលអនាគត។)

**ចំណុចសំខាន់ផងដែរនោះ គឺត្រូវបង្កើនសមិទ្ធកម្មផ្នែកភ័ស្តុភារកម្ម ជាចំណុចដៅមួយ ដែលត្រូវបានដាក់ចេញក្នុងយុទ្ធសាស្ត្របញ្ចកោណ។**[1] ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីកាត់បន្ថយចំណាយលើការដឹកជញ្ជូន និងសេវាភ័ស្តុភារកម្ម តាមរយៈការពិនិត្យតាមដានលើប្រសិទ្ធភាពនៃច្រកពាណិជ្ជកម្មធំៗ ដូចជា ផែ និងច្រកត្រួតពិនិត្យនៅតាមព្រំដែនជាដើម។ ការអង្កេតសហគ្រាសបានបង្ហាញថាបច្ចុប្បន្ននេះ ការដឹកជញ្ជូនគឺជាឧបសគ្គធំជាងគេលំដាប់ទី ៤ សម្រាប់សហគ្រាសនានា។ ចំណុចនេះ គឺស្របគ្នានឹងលទ្ធផលរកឃើញដែលត្រូវបានពិភាក្សា នៅក្នុងឯកសារគោលនយោបាយមួយដែលធ្វើការវិភាគលើបញ្ហាដែលបង្កការរំខាន ដល់ខ្សែច្រវាក់ផ្គត់ផ្គង់ ក្រោយការរាតត្បាតជាសកល។ លទ្ធផលរកឃើញទាំងនេះ បង្ហាញថាចំណាយលើសេវាភ័ស្តុភារកម្មនៅកម្ពុជាមានកម្រិតខ្ពស់ខ្លាំង បើធៀបនឹងប្រទេសនៅអាស៊ាន ដោយមានការប៉ាន់ប្រមាណថា ចំណាយនេះមានកម្រិតស្មើនឹង ២៦,៤ ភាគរយនៃ ផ.ស.ស កាលពីឆ្នាំ ២០២០។ ដើម្បីសម្រេចគោលដៅខាងលើ ជាការចាំបាច់ដែលត្រូវបង្កើតក្រុមការងារ និងចាត់តាំងអាជ្ញាធរមូលដ្ឋានឱ្យសម្រួលពាណិជ្ជកម្ម តាមរយៈការជួយសម្រួលតាមប្រព័ន្ធហតទ្បាញ ជាពិសេសសម្រាប់ការដឹកជញ្ជូនតាមផ្លូវគោក។

**ការបង្កើនកម្រិតគុណភាពនៃហេដ្ឋារចនាសម្ព័ន្ធរបស់កម្ពុជា ជាពិសេសការផ្គត់ផ្គង់អគ្គិសនី មានសារសំខាន់យ៉ាងខ្លាំង ដើម្បីរំកិលខ្លួនទៅដល់ឧស្សាហកម្មកម្មន្តសាល និងឧស្សាហកម្មកែច្នៃកសិកម្ម ដែលផ្តល់នូវតម្លៃបន្ថែមកាន់តែខ្ពស់។** ខណៈពេលដែលការទទួលបានអគ្គិសនីប្រើប្រាស់ មានភាពប្រសើរ

1 យុទ្ធសាស្ត្របញ្ចកោណ គឺជាផែនទីបង្ហាញផ្លូវ ដើម្បីធ្វើបរិវត្តកម្មកម្ពុជាឱ្យក្លាយជាប្រទេសដែលមានចំណូលខ្ពស់ ត្រឹមឆ្នាំ ២០៥០។

ជាងមុន ភាពអាចជឿទុកចិត្តបានក្នុងកម្រិតទាបនៃការផ្គត់ផ្គង់ថាមពល នៅតែជាចំណុចរាំងស្ទះមួយដ៏សំខាន់។ ការអង្កេតសហគ្រាសបង្ហាញថា មានក្រុមហ៊ុនដែលត្រូវបានសាកសួរចំនួន ៤៣ ភាគរយ ជួបប្រទះនឹងបញ្ហាដាច់ចរន្តអគ្គិសនី (ដាច់ចរន្តអគ្គិសនីចំនួន ០,៩ ដងនៅក្នុងខែធម្មតា) នៅកម្ពុជា បើធៀបនឹងអត្រា ១២,៧ ភាគរយ (ដាច់ចរន្តអគ្គិសនី ០,២ ដងក្នុងខែធម្មតា) នៅឥណ្ឌូនេស៊ី និង ២៨,៦ ភាគរយ (ដាច់ចរន្តអគ្គិសនី ០,៤ ដងនៅក្នុងខែធម្មតា) នៅក្នុងប្រទេសឥណ្ឌូនេស៊ី (២០១៩)។ ការផ្គត់ផ្គង់អគ្គិសនីពុំបានគ្រប់គ្រាន់ អាចធ្វើឱ្យចំណាយថ្លៃដើមមានការកើនឡើង បង្កការរំខានដល់ផលិតកម្ម និងកាត់បន្ថយអត្រាចំណេញ។ តាមការអង្កេតសហគ្រាសបង្ហាញថា នៅកម្ពុជាការខាតបង់ដោយសារការដាច់អគ្គិសនីកាន់តែមានការកើនឡើង ដ្បិតចំណាយដែលពាក់ព័ន្ធកើនឡើងពី ០,៣ ភាគរយនៃចំណូលពីការលក់ប្រចាំឆ្នាំនៅក្នុងឆ្នាំ ២០១៣ ដល់ ១,១ ភាគរយនៅក្នុងឆ្នាំ ២០២៣ លើសពីអត្រានៅឥណ្ឌូនេស៊ី (០,២ ភាគរយ) វៀតណាម (០,២ ភាគរយ) និងសិង្ហបុរី (០ ភាគរយ)។ ចាំបាច់ត្រូវមានការវិនិយោគធំៗក្នុងវិស័យថាមពល ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមចំនួន ២ នោះគឺឆ្លើយតបចំពោះតម្រូវការអគ្គិសនី ដែលបន្តមានការកើនឡើងយ៉ាងឆាប់រហ័សផង និងបំពេញតាមការប្តេជ្ញាចិត្ត ក្នុងការឆ្លើយតប ចំពោះការប្រែប្រួលអាកាសធាតុរបស់ប្រទេសនេះផង។ លើសពីនេះ ក៏ចាំបាច់ត្រូវមានការវិនិយោគ ដើម្បីបង្កើនកម្រិតគុណភាពនៃសេវាជាមូលដ្ឋាននៅតាមតំបន់ប្រជុំជន ដូចជាការតទឹកតាមបំពង់ សេវាអនាម័យ ការគ្រប់គ្រងសំណល់រឹង សេវាទូរគមាគមន៍ និងដឹកជញ្ជូន ទន្ទឹមគ្នានឹងការពង្រឹងការរៀបចំផែនការទីក្រុង។



*Photo: Pexels-kelly*

## រូប ES.១. សង្ខេបការអភិវឌ្ឍថ្មីៗនៅកម្ពុជា

**កំណើនសេដ្ឋកិច្ចមានការកើនឡើង...**

*អត្រាពិត (ភាគរយ)*




**...គាំទ្រដោយសារកំណើនការនាំចេញសេវា...**

*ចំនួនភ្ញៀវទេសចរអន្តរជាតិដែលចូលមកប្រទេសកម្ពុជា (លាននាក់)*




**...និងការងើបឡើងវិញនៃការនាំចេញទំនិញ...**

*ការនាំចេញទំនិញ (គិតពីដើមឆ្នាំរហូតមកដល់បច្ចុប្បន្ន បម្រែបម្រួលភាគរយធៀបនឹងឆ្នាំមុន)*




**...អត្រាអតិផរណាថយចុះមកនៅសូន្យ ក្នុងរយៈពេល ១២ ខែ គិតត្រឹមខែមីនា ឆ្នាំ ២០២៤ ដែលជាកម្រិតទាបបំផុត ក្នុងរយៈពេល ១៥ ឆ្នាំចុងក្រោយនេះ...**

*(បម្រែបម្រួលគិតជាភាគរយធៀបនឹងឆ្នាំមុន)*




**...កំណើននៃរូបិយប័ណ្ណទូទៅ (M2) មានការកើនឡើង...**

*បំណុលគិតជារូបិយប័ណ្ណ Broad money (បម្រែបម្រួលគិតជាភាគរយធៀបនឹងឆ្នាំមុន)*




**...ចំណូលក្នុងស្រុកមានការថយចុះ**

*(ភាគរយនៃ ផ.ស.ស បម្រែបម្រួលគិតជាភាគរយធៀបនឹងឆ្នាំមុន)*




*ប្រភព៖ អាជ្ញាធរកម្ពុជា, ការព្យាករដែលធ្វើឡើងដោយបុគ្គលិករបស់ធនាគារពិភពលោក។*

*សម្គាល់៖* e = ប៉ាន់ប្រមាណ, p = ព្យាករណ៍, y/y = ធៀបនឹងឆ្នាំមុន

# ការអភិវឌ្ឍថ្មីៗ

## *សកម្មភាពសេដ្ឋកិច្ចមានការកើនឡើង*

**សេដ្ឋកិច្ចសកលនឹងបន្តថមថយនៅឆ្នាំនេះ ខណៈពេលដែលផលប៉ះពាល់នៃការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ លក្ខខណ្ឌហិរញ្ញវត្ថុមានលក្ខណៈរឹតត្បិត និងសកម្មភាពពាណិជ្ជកម្ម និងការវិនិយោគនៅទូទាំងសកលលោកមានភាពទន់ខ្សោយ នៅបន្តអូសបន្លាយ។**[2] កំណើនសេដ្ឋកិច្ចសកល ត្រូវបានរំពឹងថានឹងថមថយមកនៅ ២,៤ ភាគរយនៅក្នុងឆ្នាំ ២០២៤ – ជាឆ្នាំទី ៣ នៃការថយចុះបែបនេះ – ដែលជាការឆ្លុះបញ្ចាំងពីការបន្តអូសបន្លាយនៃផលប៉ះពាល់នៃរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ ដើម្បីទប់ស្កាត់កំណើនអតិផរណាដ៏ខ្ពស់ដែលមិនធ្លាប់មានរាប់ទសវត្សរ៍មកហើយ ការរឹតត្បិតការផ្ដល់ឥណទាន និងភាពទន់ខ្សោយនៃការសកម្មភាពពាណិជ្ជកម្ម និងការវិនិយោគនៅទូទាំងសកលលោក។ ការរំពឹងទុកក្នុងរយៈពេលខ្លីមានការប្រែប្រួល ដោយកំណើនក្នុងប្រទេសមានសេដ្ឋកិច្ចធំៗមានការថមថយ តែប្រទេសដែលជាទីផ្សារកំពុងងើបឡើង និងប្រទេសមានសេដ្ឋកិច្ចកំពុងអភិវឌ្ឍដែលមានមូលដ្ឋានគ្រឹះរឹងមាំ បែរជាមានភាពល្អប្រសើរទៅវិញ (សូមមើលប្រអប់ទី ១ ស្ដីពីការអភិវឌ្ឍសេដ្ឋកិច្ច និងទស្សនវិស័យទូទាំងសកលលោក)។ ជម្លោះកាលពីពេលថ្មីៗនៅមជ្ឈិមបូព៌ា បន្ថែមលើការឈ្លានពានរបស់សហព័ន្ធរុស្ស៊ីលើប្រទេសអ៊ុយក្រែន ធ្វើឱ្យមានហានិភ័យភូមិសាស្ត្រនយោបាយកាន់តែខ្លាំងឡើង។ នៅខាងចំណុចវិជ្ជមានវិញ ទោះបីអាមេរិកកំពុងជួបប្រទះនឹងបញ្ហាធំៗក៏ដោយ សកម្មភាពសេដ្ឋកិច្ចប្រកបដោយភាពធន់ និងការថយចុះនូវអត្រាអតិផរណានៅសហរដ្ឋអាមេរិក អាចបន្តធានាបាននូវនិរន្តរភាព ប្រសិនបើការផ្គត់ផ្គង់កម្លាំងពលកម្មបន្តមានភាពប្រសើរទៀត។ កំណើនរបស់អាមេរិកអាចបន្តមានភាពរឹងមាំជាងអ្វីដែលបានព្យាករនៅពេលដែលសម្ពាធថ្លៃទំនិញមានការថមថយ ហើយគោលនយោបាយរូបិយវត្ថុត្រូវបានបន្ធូរបន្ថយ ដែលអាចជួយជំរុញសកម្មភាពនៅទូទាំងសកលលោកបន្ថែមទៀត។

**សេដ្ឋកិច្ចនៅប្រទេសកំពុងអភិវឌ្ឍភាគច្រើននៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក (EAP) មានការរីកចម្រើនលឿនជាងបណ្ដាប្រទេសដទៃទៀតនៅក្នុងសកលលោក ប៉ុន្តែមានសម្ទុះយឺតជាងមុនពេលដែលមានការរាតត្បាតជាសកល។**[3] សមិទ្ធកម្មសេដ្ឋកិច្ចនៅក្នុងតំបន់នេះ រាប់បញ្ចូលទាំងកម្ពុជាផង ត្រូវបានកំណត់រួមគ្នា ដោយកត្តាក្រៅប្រទេសផង និងក្នុងប្រទេសផង។ កំណើនសេដ្ឋកិច្ចសកលដែលមានភាពថមថយ ការបន្តរឹតត្បិតលក្ខខណ្ឌហិរញ្ញវត្ថុ និងការកើនឡើងនៃកិច្ចគាំពារពាណិជ្ជកម្ម និងការគាំទ្រឧស្សាហកម្មនៅតាមប្រទេសអ្នកមានធំៗ គឺជាទិដ្ឋភាពសំខាន់ៗនៃបរិយាកាសខាងក្រៅ។ កំណើននៃបំណុលរដ្ឋ និងឯកជន ការលំបាកក្នុងការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងកំណើនភាពមិនប្រាកដប្រជាផ្នែកនយោបាយ និងគោលនយោបាយគឺជាបញ្ហាក្នុងស្រុកសំខាន់ៗ។ ខណៈពេលដែលកត្តាក្នុងស្រុកទំនងជាមានឥទ្ធិពលខ្លាំងមកលើកំណើននៅក្នុងប្រទេសចិន កត្តាខាងក្រៅនឹងមានឥទ្ធិពលរឹតតែខ្លាំងលើកំណើននៅតាមប្រទេសដទៃជាច្រើននៅក្នុងតំបន់ រាប់បញ្ចូលទាំងប្រទេសកម្ពុជាផងដែរ។

**មានការព្យាករថា កំណើននៅក្នុងប្រទេសចិន នឹងថមថយនៅក្នុងឆ្នាំ២០២៤ ដោយសារការងើបឡើងវិញក្រោយពីការបើកសេដ្ឋកិច្ចឡើងវិញបានថមថយល្បឿន និងបញ្ហាចំពោះមុខដូចជា កើនឡើងនៅកម្រិតបំណុល និងការចុះខ្សោយនៃវិស័យអចលនទ្រព្យ ព្រមទាំងកត្តារចនាសម្ព័ន្ធក្នុងរយៈពេលវែងដូចជាប្រជាជនកាន់តែមានវ័យចំណាស់ និងការបែងចែកដាច់ពីគ្នា (decoupling) កំពុងដាក់សម្ពាធមកលើកំណើន។** ប្រទេសដទៃទៀតនៅក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ដែលរងផលប៉ះពាល់កាលពីឆ្នាំ ២០២៣ ដោយសារតែការថមថយនៃកំណើនពាណិជ្ជកម្ម និងការរឹតបន្តឹងលក្ខខណ្ឌហិរញ្ញវត្ថុ ត្រូវបានគេរំពឹងថានឹងមានកំណើន ៥,០ ភាគរយនៅក្នុងឆ្នាំ ២០២៤។ ការងើបឡើងវិញដែលទំនងជាកើតមានសម្រាប់ពាណិជ្ជកម្មទំនិញសកល និងការបន្ធូរបន្ថយលក្ខខណ្ឌហិរញ្ញវត្ថុនៅទូទាំងសកលលោក ត្រូវបានគេរំពឹងថានឹងកាត់កងផលប៉ះពាល់ដោយសារកំណើនដែលកំពុងមានការថមថយរបស់ប្រទេសចិន។

**សកម្មភាពសេដ្ឋកិច្ចដែលមានភាពធន់នៅសហរដ្ឋអាមេរិក គួរគាំទ្រដល់ការនាំចេញទំនិញរបស់កម្ពុជា ដោយហេតុថាសហរដ្ឋអាមេរិក គឺជាទីផ្សារនាំចេញធំជាងគេរបស់កម្ពុជា ខណៈពេលដែលការថយចុះនៃអត្រាអតិផរណាដែលអាចនាំឱ្យមានការបន្ធូរបន្ថយគោលនយោបាយរូបិយវត្ថុនៅសហរដ្ឋអាមេរិក គួរជួយទប់ស្កាត់អត្រាអតិផរណា និងអត្រាការប្រាក់របស់ប្រទេសកម្ពុជា ដោយសារតែកម្ពុជា ជាសេដ្ឋកិច្ចដែលមានដុល្លារូបនីយកម្មក្នុងកម្រិតមួយខ្ពស់។** ផ្ទុយទៅវិញ កំណើនថមថយនៅក្នុងប្រទេសចិន អាចបង្កផលប៉ះពាល់អវិជ្ជមានលើសេដ្ឋកិច្ចកម្ពុជា ដ្បិតប្រទេសចិន គឺជាដៃគូពាណិជ្ជកម្មធំមួយរបស់កម្ពុជា ជាពិសេសសម្រាប់ការនាំចូលទំនិញពាក់កណ្ដាលសម្រេចដែលត្រូវបានប្រើប្រាស់នៅក្នុងផលិតកម្មសម្លៀកបំពាក់ ទំនិញសម្រាប់ការធ្វើដំណើរ និងផលិតផលស្បែកជើងសម្រាប់នាំចេញ។ ប្រទេសចិន ក៏ជាប្រភពការវិនិយោគផ្ទាល់ពីបរទេស (FDI) ដ៏ធំមួយ និងចំណូលសម្រាប់វិស័យទេសចរណ៍របស់កម្ពុជាផងដែរ។ ការវិនិយោគផ្ទាល់ពីចិនបន្តមានចំនួនស្មើនឹងពាក់កណ្ដាលនៃលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសមកកម្ពុជា។ ភ្ញៀវ

2 World Bank 2024a

3 World Bank 2024b.

## ប្រអប់ទី ១.ការអភិវឌ្ឍសេដ្ឋកិច្ច និងទស្សនវិស័យសេដ្ឋកិច្ចសកល

**បើទោះជាសកម្មភាពសេដ្ឋកិច្ចនៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចធំៗមួយចំនួនកាលពីពេលថ្មីៗនេះ មានភាពធន់គួរឱ្យភ្ញាក់ផ្អើល ជាពិសេសនៅសហរដ្ឋអាមេរិក ទស្សនវិស័យសកលនៅតែមិនទាន់មានភាពប្រសើរខ្លាំងនៅឡើយ ជាមួយនឹងការព្យាករថាកំណើនសកលនឹងស្ថិតក្នុងរង្វង់ ២,៤ ភាគរយសម្រាប់ឆ្នាំ ២០២៤ និង ២,៧ ភាគរយក្នុងឆ្នាំ ២០២៥ (រូប B.១.១)។**[a] បើទោះជាមានការរំពឹងថាសេដ្ឋកិច្ចនឹងងើបឡើងវិញតិចតួចនៅឆ្នាំក្រោយក៏ដោយ កំណើននឹងបន្តមានកម្រិតក្រោមអត្រាមធ្យមនៅមុនពេលដែលមានការរាតត្បាតជាសកល ខណៈពេលដែលគោលនយោបាយរូបិយប័ណ្ណបែបរឹតបន្តឹងនៅបន្តមានឥទ្ធិពល ហើយស្ថានភាពភូមិសាស្ត្រនយោបាយកាន់តែមានភាពមិនប្រាកដប្រជា។ ព្រឹត្តិការណ៍សំខាន់ៗនៅក្នុងសកលលោក ហើយអត្រាអតិផរណាជាទូទៅបានបន្តថយចុះពីកំណើនដ៏ខ្ពស់បំផុត នៅឆ្នាំ ២០២២។ ទោះជាយ៉ាងក្តី អត្រាអតិផរណានៅបន្តលើសពីកម្រិតគោលដៅនៅតាមប្រទេសជាច្រើន ហើយមានការព្យាករថាអត្រាអតិផរណានៅទូទាំងសកលលោកនឹងបន្តស្ថិតនៅលើកម្រិតមធ្យមមុនពេលមានការរាតត្បាតជាសកលក្រោយឆ្នាំនេះ។ ការរឹតបន្តឹងគោលនយោបាយរូបិយប័ណ្ណនៅតាមប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន និងនៅតាមប្រទេសដែលមានទីផ្សារទើបរីកចម្រើន និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ (EMDEs) ហាក់បីដូចជាស្ទើរតែបញ្ចប់ទាំងស្រុង ប៉ុន្តែគេរំពឹងថាអត្រាការប្រាក់នៅតែបន្តស្ថិតនៅក្នុងកម្រិតមួយខ្ពស់មួយរយៈ នៅពេលដែលអត្រាអតិផរណាវិលមករកអត្រាគោលដៅបន្តិចម្តងៗ។ នេះធ្វើឱ្យប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿននៅប្រកាន់គោលជំហររឹតបន្តឹងគោលនយោបាយរូបិយប័ណ្ណនៅក្នុងរយៈពេលខ្លី បន្ទាប់ពីការមានការបង្កើនអត្រាគោលនយោបាយពិតរបស់សហរដ្ឋអាមេរិកក្នុងកម្រិតខ្ពស់បំផុត និងសារលឿនបំផុតមិនធ្លាប់មាន ចាប់តាំងពីដើមទសវត្សរ៍ ១៩៨០ មក។

**ក្នុងឆ្នាំ ២០២៣ ពាណិជ្ជកម្មសកលភាគច្រើននៅទ្រឹង ជាមួយនឹងលទ្ធផលដុនដាបបំផុតមិនធ្លាប់មានក្នុងរយៈពេល ៥០ ឆ្នាំចុងក្រោយនេះ លើកលែងតែពេលដែលមានឱនភាពសេដ្ឋកិច្ចទូទាំងសកលលោក ប៉ុន្តែគេរំពឹងថាស្ថានភាពនេះនឹងងើបឡើងវិញក្នុងកម្រិតមធ្យមនៅឆ្នាំនេះ។** ពាណិជ្ជកម្មទំនិញបានរួមតូចកាលពីឆ្នាំមុន ដែលជាការឆ្លុះបញ្ចាំងពីការថយចុះនៃសកម្មភាពពាណិជ្ជកម្មនៅតាមប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើន និងការថយចុះកំណើននៅក្នុងបណ្តាប្រទេស EMDEs ខណៈពេលដែលពាណិជ្ជកម្មសេវាកម្មវិញលែងកើនឡើងក្នុងសន្ទុះខ្លាំងក្លាបំផុត ដូចអ្វីដែលធ្លាប់កើតមានកន្លងមកក្រោយពេលងើបឡើងវិញដំបូងៗពីការរាតត្បាតជាសកល។ នៅក្នុងខែកុម្ភៈ ឆ្នាំ ២០២៤ ពាណិជ្ជកម្មទំនិញនៅទូទាំងសកលលោកកើនឡើងជាលើកដំបូងបង្អស់នៅក្នុងរយៈពេលមួយឆ្នាំ (រូប B.១.២)។ គេរំពឹងថាកំណើនពាណិជ្ជកម្មនៅទូទាំងសកលលោកនិងកើនឡើងនៅឆ្នាំនេះ ដោយសារការកើនឡើងនៃពាណិជ្ជកម្មទំនិញ ប៉ុន្តែនៅបន្តឋិតនៅក្នុងកម្រិតទាបជាងអត្រាមធ្យមមុនពេលដែលនៃការរាតត្បាតជាសកល។ គេរំពឹងថាការរួមចំណែកនៃវិស័យសេវាកម្មចំពោះកំណើនពាណិជ្ជកម្មសរុបនឹងមានការថយចុះ ដែលស្ទើរតែដូចគ្នានឹងសមាសភាគនៃពាណិជ្ជកម្មមុនពេលដែលមានការរាតត្បាតជាសកល។

**បើទោះជាថ្លៃស្បៀង និងថាមពល ទូទាំងសកលលោក មានការថយចុះពីអត្រាខ្ពស់បំផុត កាលពីឆ្នាំ ២០២២ ក៏ដោយ ចាប់តាំងពីដើមឆ្នាំនេះមក ការកើនឡើងនៃភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ បានដាក់សម្ពាធលើថ្លៃទំនិញសំខាន់ៗ ដែលជាពិសេសប្រេង។** ប្រសិនបើជម្លោះបច្ចុប្បន្នមិនធ្ងន់ធ្ងរជាងពេលបច្ចុប្បន្ននេះ គេព្យាករណ៍ថាថ្លៃទំនិញជារួមនឹងថយចុះតែបន្តិចបន្តួចប៉ុណ្ណោះ នៅក្នុងឆ្នាំ ២០២៤ និង ២០២៥ ហើយបន្តថានៅកម្រិតលើសពីមុនពេលមានការរាតត្បាតជាសកលប្រមាណ ៣៨ ភាគរយ។[b]

**នៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក គេរំពឹងថាកំណើននឹងថមថយនៅឆ្នាំនេះ។**[c] នេះជាការឆ្លុះបញ្ចាំងពីការថមថយកំណើននៅក្នុងប្រទេសចិន ដែលការកើនឡើងនូវតម្រូវការខុសប្រក្រតីនៅពេលដែលមានការបើកប្រទេសក្រោយការរាតត្បាតជាសកលចាប់ផ្តើមស្រាកស្រាន្តទៅវិញ។ ក្នុងពេលដែលការប្រើប្រាស់មានការថយចុះ ហើយវិស័យអចលនទ្រព្យបន្តឱនភាព ដែលនឹងការដាក់សម្ពាធលើការវិនិយោគ មានការព្យាករថាកំណើននៅក្នុងប្រទេសចិននឹងថយចុះពី ៥,២ ភាគរយកាលពីឆ្នាំមុនមក ៤,៥ ភាគរយនៅឆ្នាំនេះ។ នៅឆ្នាំក្រោយកំណើនត្រូវបានព្យាករណ៍ថានឹងបន្តថមថយមកនៅ ៤,៣ ភាគរយ។ នៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក លើកលែងតែប្រទេសចិន គេរំពឹងថាកំណើននឹងងើបឡើងវិញតិចតួចពី ៤,៤ ភាគរយក្នុងឆ្នាំ ២០២៣ ដល់ ៤,៦ ភាគរយក្នុងឆ្នាំ ២០២៤ ដោយសារតែមានការរំពឹងថាពាណិជ្ជកម្មសកលនឹងងើបឡើងវិញ ហើយបន្ទាប់មកនឹងកើនឡើងដល់ ៤,៨ ភាគរយនៅឆ្នាំក្រោយ។

**ហានិភ័យនៃទស្សនវិស័យសកលនៅបន្តតែមករកការថយចុះ។** ការកើនឡើងនៃជម្លោះប្រដាប់អាវុធអាចធ្វើឱ្យចំណង់វិនិយោគទូទាំងសកលលោកមានការថយចុះ និងធ្វើឱ្យថ្លៃទំនិញមានការកើនឡើង ជាហេតុអាចធ្វើឱ្យអត្រាអតិផរណាសកល

ដែលកំពុងនៅខ្ពស់ស្រាប់ទៅហើយ កាន់តែមានការកើនឡើង និងអូសបន្លាយពេល ការបន្ធូរបន្ថយស្ថានភាពរូបិយប័ណ្ណទូទាំងសកល។ ហានិភ័យដែលស្ថានភាពបន្តធ្លាក់ចុះមួយទៀត គឺលទ្ធភាពដែលមានការរឹតបន្តឹងលក្ខខណ្ឌហិរញ្ញវត្ថុសកលលោកជាងអ្វីដែលគេរំពឹងទុក។ ការបន្ធូរបន្ថយស្ថានភាពរូបិយប័ណ្ណនៅតាមប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន អាចអូសបន្លាយពេល ខណៈពេលដែលការវិលត្រឡប់នៃអត្រាអតិផរណាមករកអត្រាគោលដៅមានភាពយឺតយ៉ាវ ហើយការកើនឡើងនៃភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយអាចកាត់បន្ថយកម្រិតនៃការទទួលយកហានិភ័យ (risk appetite) សកល។ កំណើនយឺតជាងការរំពឹងទុកនៅក្នុងប្រទេសចិន ដោយសារតែការធ្លាក់ចុះនៃវិស័យអចលនទ្រព្យបន្តអូសបន្លាយពេល និងគ្រោះមហន្តរាយធម្មជាតិដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ជាកត្តាធ្វើឱ្យទស្សនវិស័យសកលនៅតែបន្តប្រឈមនឹងហានិភ័យធ្លាក់ចុះ។

**រូប B.១.១. កំណើនសកល**




*ប្រភព៖ ធនាគារពិភពលោក*

*សម្គាល់៖ អត្រា* ផ.ស.ស ពិតរបស់ពិភពលោក។ ឆ្នាំ ២០២៤ និង ២០២៥ គឺជាតួលេខព្យាករណ៍។

**រូប B.១.២. កំណើនពាណិជ្ជកម្មទំនិញសកល**




*ប្រភព៖ កម្មវិធីពិនិត្យតាមដានពាណិជ្ជកម្មពិភពលោក CPB*

*សម្គាល់៖ បម្រែបម្រួលធៀបនឹងឆ្នាំមុននៃពាណិជ្ជកម្មទំនិញសកលពិត។*

*ប្រភព៖ a.* World Bank 2024a, b. World Bank 2024c. c. World Bank 2024d.

*សម្គាល់៖ ប្រអប់នេះត្រូវបានរៀបចំដោយ* Samuel Christopher Hill, DECPG.

ទេសចរចិនមានចំនួនស្មើនឹង ១ ភាគ ៣ នៃចំនួនភ្ញៀវទេសចរអន្តរជាតិសរុបមកកាន់កម្ពុជា មុនពេលដែលមានការរាតត្បាតជាសកល។

## ចំនួនភ្ញៀវទេសចរអន្តរជាតិដែលមកដល់កម្ពុជាមានការកើនឡើង

**បើទោះជាស្ថានភាពខាងក្រៅបង្កការលំបាកយ៉ាងណាក៏ដោយ សេដ្ឋកិច្ចរបស់កម្ពុជាស្ទុះងើបឡើងវិញ ទោះជាកំណើននៅបន្តមានក្នុងអត្រាទាបជាងក្នុងអំឡុងមុនពេលមានជំងឺកូវីដ ១៩ (រូបទី ១)។** ការងើបឡើងវិញនេះ មួយផ្នែកធំគឺដោយសារការងើបឡើងវិញនៃការនាំចេញសេវាកម្ម និងទំនិញ។ នៅក្នុងត្រីមាសទី ១ ឆ្នាំ ២០២៤ ចំនួនភ្ញៀវទេសចរមកកម្ពុជាកើនឡើងដល់ ១,៥៨ លាននាក់ កើនឡើងពី ១,២៩ លាននាក់ ក្នុងរយៈពេលដូចគ្នានេះ កាលពីឆ្នាំ ២០២៣។ ការងើបឡើងវិញនៃកំណើនភ្ញៀវទេសចរអន្តរជាតិមកកម្ពុជា គឺស្រដៀងគ្នានឹងកំណើនភ្ញៀវទេសចរមកកាន់ប្រទេសថៃ ប៉ុន្តែតិចជាងកំណើននៅក្នុងប្រទេសវៀតណាម។ នៅក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤ ចំនួនភ្ញៀវទេសចរមកដល់កម្ពុជាកើនឡើងដល់ ៨៤,៣ ភាគរយនៃចំនួនភ្ញៀវទេសចរមកដល់កម្ពុជាក្នុងរយៈពេលដូចគ្នា កាលពីឆ្នាំ ២០១៩ (រូបទី ២) បើធៀបនឹង ៧៥,៩ ភាគរយនៅក្នុងប្រទេសថៃ និង ១០៣,១៥ ភាគរយនៅក្នុងប្រទេសវៀតណាម។ ទោះជាយ៉ាងនេះក្តី សមាសភាគនៃភ្ញៀវទេសចរដែលចូលមកមានការប្រែប្រួល ដែលបង្ហាញថាចំណូលពីវិស័យទេសចរណ៍ងើបឡើងវិញនៅក្នុងល្បឿនមួយដ៏យឺត។ ក្នុងរយៈពេលមុនមានការរាតត្បាតជាសកល ចំនួនភ្ញៀវទេសចរមកតាមជើងហោះហើរដែលជារឿយៗមានទំនាក់ទំនងនឹងការចំណាយខ្ពស់របស់ភ្ញៀវទេសចរ ស្មើនឹង ២ ភាគ ៣ ហើយចំនួនភ្ញៀវទេសចរដែលចូលមកតាមផ្លូវគោកស្មើនឹង ១ ភាគ ៣។ ក្រោយការឆ្លងរាតត្បាតនៃជំងឺកូវីដ ១៩ និន្នាការនេះបែរជាបញ្ច្រាស់ទៅវិញ។ ក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤ ចំនួនភ្ញៀវអន្តរជាតិដែលចូលមកតាមផ្លូវគោកស្មើនឹង ៦០,០ ភាគរយ (០,៩៤ លាននាក់) នៃចំនួនសរុប ខណៈពេលដែលចំនួនភ្ញៀវទេសចរដែលមកតាមផ្លូវអាកាសស្មើនឹង ៤០ ភាគរយ (០,៦៤ លាននាក់)។ លើសពីនេះ ខណៈពេលដែលភ្ញៀវទេសចរជនជាតិចិនមានភាគរយខ្ពស់ជាងគេ

ស្មើនឹងជិត ៤០ ភាគរយនៃចំនួនភ្ញៀវទេសចរសរុប ក្នុងអំឡុងមុនពេលមានការរាតត្បាតជាសកល ចំនួនភ្ញៀវទេសចរចិនមានចំនួនត្រឹមតែ ១២,០ ភាគរយប៉ុណ្ណោះ និងជាប់ចំណាត់ថ្នាក់ទី ៣ ក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤។

**បច្ចុប្បន្ននេះ ភ្ញៀវជនជាតិថៃ និងវៀតណាម គឺជាចំនួនភ្ញៀវទេសចរលំដាប់ទី ១ និងលំដាប់ទី ២ ស្មើនឹង ២៦,៥ ភាគរយសម្រាប់ជនជាតិថៃ កើនឡើងពី ៥,៦ ភាគរយ និង ១៨,៩ ភាគរយសម្រាប់ជនជាតិវៀតណាម កើនឡើងពី ១០,០ ភាគរយក្នុងឆ្នាំ ២០១៩។** ការកើនឡើងនៃចំនួនភ្ញៀវទេសចរដែលចូលមកតាមផ្លូវគោក ឆ្លុះបញ្ចាំងពីការកើនឡើងនៃចំនួនភ្ញៀវទេសចរបរទេសដែលស្នាក់នៅរយៈពេលខ្លី និងចំណាយប្រចាំថ្ងៃតិចតួច ជាពិសេសជនជាតិថៃដែលឆ្លងដែនពីតំបន់អារ៉ាញ់ប្រាថេត (ប្រទេសថៃ) ភាគច្រើនមកលេងក្រុងប៉ោយប៉ែត (ប្រទេសកម្ពុជា) ដែលមានកាស៊ីណូបម្រើភ្ញៀវទេសចរបរទេស។ ប្រទេសជិតខាងកម្ពុជា ជាពិសេសថៃ និងវៀតណាម បានទទួលជោគជ័យច្រើនក្នុងការទាក់ទាញភ្ញៀវទេសចរជនជាតិចិន។ នៅក្នុងត្រីមាសទី ១ ឆ្នាំ ២០២៤ ភ្ញៀវទេសចរចិនមានចំនួនស្មើនឹង ២១,៤ ភាគរយសម្រាប់ប្រទេសថៃ និង ១៩,១ ភាគរយសម្រាប់ប្រទេសវៀតណាម បើធៀបនឹង ១២,០ ភាគរយសម្រាប់កម្ពុជា។

## *ចំនួនភ្ញៀវទេសចរបរទេសដែលមកទស្សនាខេត្តសៀមរាប នៅតែមានចំនួនតិចជាងកាលពីមុនឆ្នាំ ២០១៩*

**ក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤ (គិតជាចំណែកនៃការមកដល់នៃចំនួនភ្ញៀវទេសចរឆ្នាំ ២០១៩) ចំនួនភ្ញៀវទេសចរអន្តរជាតិសរុបដែលមកទស្សនាខេត្តសៀមរាប មានត្រឹមតែ ២៨,៨ ភាគរយប៉ុណ្ណោះ។** ចំនួនភ្ញៀវទេសចរអន្តរជាតិដែលមកទស្សនាខេត្តសៀមរាបមានចំនួន ០,២ លាននាក់ ស្មើនឹង ១៣,០ ភាគរយនៃចំនួនភ្ញៀវទេសចរសរុបក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤ ធៀបនឹងចំនួន ០,៧១ លាននាក់ ឬ ៣៨,២ ភាគរយនៃចំនួនភ្ញៀវទេសចរសរុបក្នុងអំឡុងពេលដូចគ្នា កាលពីឆ្នាំ ២០១៩។ ដោយសារខេត្តសៀមរាបជាតំបន់ទាក់ទាញទេសចរណ៍ធំជាងគេនៅកម្ពុជា ការងើបឡើងវិញនៃវិស័យទេសចរណ៍នៅតែមានកម្រិតទាបជាងការរំពឹងទុកសម្រាប់ឧស្សាហកម្មធ្វើដំណើរ ទេសចរណ៍ និងបដិសណ្ឋារកិច្ចជាច្រើននៅក្នុងខេត្តនេះ។ បន្ថែមលើនោះ ចំនួនភ្ញៀវទេសចរដែលមកដល់ព្រលានយន្តហោះអន្តរជាតិកងកេង ក្នុងខេត្តព្រះសីហនុដែលប្រមូលផ្តុំដោយការវិនិយោគចិន (ទទួលបានលិខិតអនុញ្ញាតការអភិវឌ្ឍអចលនទ្រព្យដែលមានតម្លៃជិត ៦ ពាន់លានដុល្លារនៅអំឡុងឆ្នាំ ២០១៨-២០) បន្តធ្លាក់ចុះ គឺមានចំនួនត្រឹមតែ ៣.៦០០ នាក់ (០,២ ភាគរយនៃចំនួនភ្ញៀវទេសចរសរុប) នៅត្រីមាសទី ១ នៃឆ្នាំ ២០២៤ ថយពី ៧៥.០០០ នាក់ (៦,០ ភាគរយនៃចំនួនភ្ញៀវទេសចរសរុប) ក្នុងអំឡុងពេលដូចគ្នាកាលពីឆ្នាំ ២០១៩។

**ការប្រមូលចំណូលពីការលក់សំបុត្រចូលទស្សនាតំបន់អង្គរកើនដល់ ២២,០ លានដុល្លារ ឬស្មើនឹងកំណើន ៩៧,៨ ភាគរយធៀបនឹងឆ្នាំមុន គិតត្រឹមត្រីមាសទី ១ នៃឆ្នាំ ២០២៤។**[4] ទោះជាយ៉ាងណា ចំណូលនេះមានចំណែកស្មើនឹង ៦១,៣ ភាគរយប៉ុណ្ណោះនៃចំណូលកាលពីឆ្នាំ ២០១៩។ ទោះបីជាចំនួនភ្ញៀវទេសចរដែលចូលមកកម្ពុជាកើនឡើងវិញយ៉ាងលឿនរហ័សក្តី ប៉ុន្តែចំណូលទេសចរណ៍ពីភ្ញៀវទេសចរ អន្តរជាតិតាមផ្លូវគោកត្រូវបានប៉ាន់ស្មានថា ទាបជាងចំណូលទេសចរណ៍ពីភ្ញៀវទេសចរ

**រូប ១. សេដ្ឋកិច្ចបន្តងើបឡើង**
**ការរួមចំណែកដល់កំណើន ផសស ពិត**
*(ភាគរយ)*




*ប្រភព ៖ អាជ្ញាធរកម្ពុជា និងការព្យាករណ៍របស់បុគ្គលិកធនាគារពិភពលោក*
*ចំណាំ ៖ e=ការប៉ាន់ស្មាន, p=ការព្យាករណ៍*

**រូប ២. ការមកដល់នៃភ្ញៀវទេសចរណ៍ និងចំណូលពីទេសចរណ៍ ក្នុងរយៈពេល ៣ ខែ**
*(ភាគរយ, ២០១៩=១០០)*




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

4 Ankor Enterprise 2024

អន្តរជាតិតាមផ្លូវអាកាស។ ក្នុងឆ្នាំ ២០២៣ ចំណូលទេសចរណ៍របស់កម្ពុជាត្រូវបានអាជ្ញាធរកម្ពុជាប៉ាន់ស្មានថាមានចំណែកត្រឹមតែ ៦២,៩ ភាគរយប៉ុណ្ណោះ (៣,០៨ ពាន់លានដុល្លារ) នៃចំណូលទេសចរណ៍ក្នុងឆ្នាំ ២០១៩ (៤,៩ លានដុល្លារ)[5]។

## ការនាំចេញទំនិញស្ទុះឡើង

**ជម្រុញដោយតម្រូវការខ្លាំងខ្លាពីខាងក្រៅ ធ្វើឱ្យការនាំចេញទំនិញរបស់កម្ពុជាមានសន្ទុះកើនឡើង។** នៅត្រីមាសទី ១ នៃឆ្នាំ ២០២៤ ការនាំចេញទំនិញ (រួមទាំង មាស) កើន ១៧,២ ភាគរយធៀបនឹងឆ្នាំមុន គឺកើនដល់ ៦,៣ ពាន់លានដុល្លារ។ ការស្ទុះកើនឡើងនៃការនាំចេញទំនិញក្នុងឆ្នាំនេះ គឺមួយភាគធំរុញច្រានដោយការងើបឡើងវិញនៃការនាំចេញផលិតផលសំលៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង (GTF)។ ការនាំចេញផលិតផលមិនមែន GTF ដែលរួមបញ្ចូលផលិតផលសំខាន់ៗ ដូចជា ទំនិញកសិកម្ម គ្រឿងអេឡិចត្រូនិក គ្រឿងអគ្គិសនី ផ្ទាំងសូឡា ស្បែក គ្រឿងសង្ហារិម និងផលិតផលផ្សេងទៀត[6] នៅតែមានភាពធន់ (រូប ៣)។ ការងើបឡើងនៃការនាំចេញផលិតផលសំលៀកបំពាក់ ក៏ត្រូវបានឆ្លុះបញ្ចាំងផងដែរក្នុងការស្ទុះឡើងនៃការនាំចូលទំនិញពាក់កណ្ដាលសម្រេចសំខាន់ៗ ជាពិសេសក្រណាត់ដែលត្រូវបានប្រើប្រាស់សម្រាប់ផលិតផលិតផល GTF។ ការនាំចូលក្រណាត់ កើន ១០,០ ភាគរយធៀបនឹងឆ្នាំមុន ក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤ កើនពី -២០,៤ ភាគរយក្នុងអំឡុងពេលដូចគ្នា នៅឆ្នាំ ២០២៣។

**ក្រៅពីនេះ ការងើបឡើងវិញនៃការនាំចេញផលិតផល GTF ទៅកាន់ទីផ្សារនាំចេញសំខាន់ៗរបស់កម្ពុជា ជាពិសេសសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប (រូប ៤) ជាមូលហេតុនៅពីក្រោយកំណើននៃការនាំចេញនាពេលថ្មីៗនេះ។** ការនាំចេញទំនិញទៅកាន់សហរដ្ឋអាមេរិកដែលជាទីផ្សារនាំចេញធំជាងគេរបស់កម្ពុជា (មានចំណែកស្មើនឹង ៣១,៤ ភាគរយនៃការនាំចេញសរុប) កើនដល់ ២,០ ពាន់លានដុល្លារ ឬស្មើនឹងកំណើន ៨,៩ ភាគរយធៀបនឹងឆ្នាំមុន នៅត្រីមាសទី ១ នៃឆ្នាំ ២០២៤ ទ្រទ្រង់ដោយការនាំចេញផលិតផល GTF។ ផលិតផលសំលៀកបំពាក់ (រួមចំណែក ៧,៦ ភាគរយ) ទំនិញធ្វើដំណើរ (រួមចំណែក ១,១ ភាគរយ) ស្បែកជើង (រួមចំណែក ០,៤ ភាគរយ) និងឈើ (ក្ដារបន្ទះ និងគ្រឿងសង្ហារិម) (រួមចំណែក ០,៨ ភាគរយ) ខណៈដែលផលិតផលទៀតរួមចំណែក ៧,២ ភាគរយ នៃកំណើនការនាំចេញទំនិញទៅកាន់ទីផ្សារ។

## អាស៊ានបានក្លាយជាទីផ្សារនាំចេញធំទី ២ របស់កម្ពុជា

**តាំងពីឆ្នាំ ២០២៣ មក សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា អាស៊ាន បាននាំមុខសហភាពអឺរ៉ុប និងបានក្លាយជាទីផ្សារនាំចេញធំបំផុតទី ២ របស់កម្ពុជា។** ចំណែកនៃទីផ្សារអាស៊ាន កើនដល់ ២០,១ ភាគរយ នៃការនាំចេញសរុបក្នុងឆ្នាំ ២០២៣ កើនពី ១៤,៦ ភាគរយក្នុងឆ្នាំ ២០២២ ខណៈដែលចំណែកនៃទីផ្សារសហភាពអឺរ៉ុប ថយមកត្រឹម ១៥,៦ ភាគរយនៃការនាំចេញសរុប ថយពី ១៨,០ ភាគរយក្នុងអំឡុងពេលដូចគ្នា។ ការនាំចេញទំនិញទៅកាន់ទីផ្សារអាស៊ាន បន្តកើនឡើងដោយមានចំណែកស្មើនឹង ២៨,០ ភាគរយនៃការនាំចេញទំនិញសរុប គឺកើនដល់ ១,៨ ពាន់លានដុល្លារ ឬស្មើនឹងកំណើន

**រូប ៣. ការរួមចំណែកដល់កំណើនការនាំចេញបែងចែកតាមផលិតផល**
*(ធៀបនឹងឆ្នាំនេះ, ភាគរយ)*




*ប្រភព៖ អាជ្ញាធរកម្ពុជា*

**រូប ៤. ការរួមចំណែកដល់កំណើនការនាំចេញបែងចែកតាមទីផ្សារ**
*(ធៀបនឹងឆ្នាំនេះ, ភាគរយ)*




*ប្រភព៖ អាជ្ញាធរកម្ពុជា*

5 ក្រសួងទេសចរណ៍ ឆ្នាំ ២០២៤

6 គួរឱ្យសោកស្ដាយដែលមិនអាចធ្វើការវិភាគបន្ថែមទៀតបាន ព្រោះចំណែកដ៏ធំនៃការនាំចេញផលិតផលមិនមែន GTF ត្រូវបានធ្វើចំណាត់ថ្នាក់ជាការនាំចេញ "ទំនិញផ្សេងៗ" ក្រោមទិន្នន័យនាំចេញទំនិញរបស់កម្ពុជា។

៣៣,១ ភាគរយធៀបនឹងឆ្នាំមុន ក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤។ ការនាំចេញផលិតផលគ្រាប់ស្វាយចន្ទី ដំឡូងមី កៅស៊ូ និងស្វាយ រួមចំណែក ៦,៦ ភាគរយ, ៥,៤ ភាគរយ, ៣,៦ ភាគរយ និង ២,៦ ភាគរយរៀងគ្នា ដល់កំណើននៃការនាំចេញទំនិញទៅកាន់ទីផ្សារអាស៊ាន ខណៈដែលផលិតផលផ្សេងទៀតរួមចំណែក ១៥,០ ភាគរយ។ ខុសពីទីផ្សារសហរដ្ឋអាមេរិក (និងសហភាពអឺរ៉ុប) ដែលនាំចូលផលិតផល GTF និងកង់ភាគច្រើនរបស់កម្ពុជា ទីផ្សារអាស៊ាននាំចូលមួយភាគធំនូវទំនិញកសិកម្មរបស់កម្ពុជា ដូចជា ដំឡូងមី (២៥,០ ភាគរយ) គ្រាប់ស្វាយចន្ទី (១៤,១ ភាគរយ) កៅស៊ូ (៥,៧ ភាគរយ) និងស្វាយ (២,៤ ភាគរយ) ក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤។

**ការនាំចេញទំនិញទៅកាន់ទីផ្សារសហភាពអឺរ៉ុប ដែលជាទីផ្សារនាំចេញធំទីបីរបស់កម្ពុជា រួមចំណែក ១៤,៣ ភាគរយដល់ការនាំចេញសរុប គឺកើនដល់ ៩០៣ លានដុល្លារ ឬស្មើនឹងកំណើន ១១,៩ ភាគរយធៀបនឹងឆ្នាំមុន នៅត្រីមាសទី ១ នៃឆ្នាំ ២០២៤ ទ្រទ្រង់ជាចម្បងដោយការនាំចេញផលិតផលសំលៀកបំពាក់ និងអង្ករ។** ក្នុងចំណែកនៃកំណើនការនាំចេញទៅកាន់ទីផ្សារសហភាពអឺរ៉ុប ផលិតផលសំលៀកបំពាក់រួមចំណែក ១៧,៨ ភាគរយ ចំណែកផលិតផលអង្កររួមចំណែក ២,៤ ភាគរយ ខណៈដែលការនាំចេញកង់ ថយ ៧,៨ ភាគរយ។ គិតត្រឹមត្រីមាសទី ១ នៃឆ្នាំ ២០២៤ ជប៉ុនរួមចំណែក ៥,៨ ភាគរយ ចិនរួមចំណែក ៥,៨ ភាគរយ ចក្រភពអង់គ្លេសរួមចំណែក ៣,៣ ភាគរយ និងប្រទេសផ្សេងទៀតរួមចំណែក ១១,៣ ភាគរយ ដល់ការនាំចេញរបស់កម្ពុជា។

**នៅត្រីមាសទី ១ នៃឆ្នាំ ២០២៤ ទីផ្សារសហរដ្ឋអាមេរិករួមចំណែក ៣១,៤ ភាគរយ (ធៀបនឹង ៣៣,៨ ភាគរយក្នុងឆ្នាំ ២០២៣ និង ៤០,០ ភាគរយក្នុងឆ្នាំ ២០២២) អាស៊ានរួមចំណែក ២៨,៩ ភាគរយ (ធៀបនឹង ២៤,៧ ភាគរយក្នុងឆ្នាំ ២០២៣ និង ១៤,៧ ភាគរយក្នុងឆ្នាំ ២០២២) និងសហភាពអឺរ៉ុបរួមចំណែក ១៤,៣ ភាគរយ (ធៀបនឹង ១៥,០ ភាគរយក្នុងឆ្នាំ ២០២៣ និង ១៨ ភាគរយក្នុងឆ្នាំ ២០២២) ដល់ការនាំចេញទំនិញសរុបរបស់កម្ពុជា។** ដូច្នេះ ការកើនឡើងរហ័សនៃចំណែករបស់ទីផ្សារអាស៊ានដែលទ្រទ្រង់ជាចម្បងដោយការនាំចេញផលិតផលមិនមែន GTF ដែលកើនដល់ ២៨,០ ភាគរយនៃការនាំចេញសរុប នៅត្រីមាសទី ១ នៃឆ្នាំ ២០២៤ កើនពី ២៤,៧ ភាគរយក្នុងឆ្នាំ ២០២៣ (និង ១៤,៧ ភាគរយក្នុងឆ្នាំ ២០២២) នឹងកាត់បន្ថយការពឹងផ្អែករបស់កម្ពុជាលើទីផ្សារសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ដែលទ្រទ្រង់មួយភាគធំដោយការនាំចេញផលិតផល GTF។

## *ចំនួនការងារក្នុងវិស័យកម្មន្តសាលកើនឡើងដោយសារការពង្រីកការនាំចេញផលិតផល GTF*

**ទន្ទឹមនឹងភាពប្រសើរឡើងនៃការនាំចេញទំនិញ ចំនួនការងារក្នុងវិស័យកម្មន្តសាលក៏កើនឡើងផងដែរ។** ក្រោយមានភាពធូរស្រាលខ្លះក្នុងស្ថានភាពទីផ្សារការងារក្នុងឆមាសទី ១ នៃឆ្នាំ ២០២៣ ចំនួនការងារក្នុងវិស័យកម្មន្តសាល ចាប់ផ្តើមងើបឡើងវិញ។ វិស័យកម្មន្តសាលបានបង្កើតការងារថ្មីចំនួន ៥០.៥៧៨ ការងារ ដែលធ្វើឱ្យចំនួនការងារសរុបកើនដល់ ១,០៥៨ លានការងារ (១៨,១ ភាគរយនៃការងារក្នុងវិស័យមិនមែនកសិកម្ម) ក្នុងខែ មីនា ឆ្នាំ ២០២៤ ឬស្មើនឹងកំណើន ៥,០ ភាគរយធៀបនឹងឆ្នាំមុន ដោយសារកំណើននៃការនាំចេញទំនិញ (រូប ៥)។ កំណើនចំនួនការងារ (employment gains) ត្រូវបានកត់សម្គាល់ក្នុងឧស្សាហកម្មកម្មន្តសាលភាគច្រើន នៅត្រីមាសទី ១ នៃឆ្នាំ ២០២៤។

**ចំនួនការងារក្នុងឧស្សាហកម្មផលិតផល GTF ដែលមានចំណែក ៨៣,៣ ភាគរយនៃចំនួនការងារសរុបក្នុងវិស័យកម្មន្តសាល កើនដល់ ០,៨៨ លានការងារក្នុងខែ មីនា ឆ្នាំ ២០២៤ ឬស្មើនឹងកំណើន ៤,០ ភាគរយធៀបនឹងឆ្នាំមុន។** ក្នុងចំណោម

**រូប ៥. ចំនួនការងារ និងរោងចក្រក្នុងវិស័យកម្មន្តសាល**




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

**រូប ៦. ចំនួនការងារក្នុងឧស្សាហកម្មសំលៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង**




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

កម្មករចំនួន ០,៨៨ លាននាក់ កម្មកររោងចក្រកាត់ដេរមានចំនួន ០,៦ លាននាក់ ហើយកម្មករក្នុងវិស័យទំនិញធ្វើដំណើរ និងស្បែកជើង មានចំនួន ០,២៨ លាននាក់ (រូប ៦)។ ទោះជាយ៉ាងណា ចំនួនការងារក្នុងឧស្សាហកម្មកែច្នៃលោហធាតុដែលរួមចំណែក ៦,០ ភាគរយដល់ចំនួនការងារសរុបក្នុងវិស័យកម្មន្តសាល ថយមកត្រឹម ០,០៦ លានការងារ ឬស្មើនឹងការថយចុះ ១៣,៣ ភាគរយធៀបនឹងឆ្នាំមុន។ ចំនួនការងារក្នុងឧស្សាហកម្មផលិតសារធាតុគីមី និងផ្លាស្ទិក រួមចំណែក ២,៨ ភាគរយដល់ចំនួនការងារសរុបក្នុងវិស័យកម្មន្តសាល កើនដល់ ០,០៣ លានការងារ ឬស្មើនឹងកំណើន ៦៣,៩ ភាគរយធៀបនឹងឆ្នាំមុន។ ចំនួនការងារក្នុងឧស្សាហកម្មផលិតចំណីអាហារ ភេសជ្ជៈ និងថ្នាំជក់ ដែលរួមចំណែក ២,៧ ភាគរយដល់ចំនួនការងារសរុបក្នុងវិស័យកម្មន្តសាល កើនដល់ ០,០២៩ លានការងារ ឬស្មើនឹងកំណើន ៧,៩ ភាគរយធៀបនឹងឆ្នាំមុន។

**ជាសញ្ញានៃផលចំណេញបន្តិចម្តងៗនៃផលិតភាព ក្នុងឧស្សាហកម្មផលិត GTF របស់កម្ពុជា នៅមុន និងក្រោយវិបត្តិកូវីដ-១៩ ចំនួនការងារក្នុងឧស្សាហកម្ម GTF ថយចុះ ២,៨ ភាគរយ គឺថយមកត្រឹម ០,៨៤ លានការងារ ក្នុងឆ្នាំ ២០២៣ ថយពី ០,៨៧ លានការងារក្នុងឆ្នាំ ២០១៩ ខណៈដែលតម្លៃនៃការនាំចេញផលិតផល GTF កើន ២,៦ ភាគរយ គឺកើនដល់ ១១,១ ពាន់លានដុល្លារ ក្នុងអំឡុងពេលដូចគ្នា។** ជាសញ្ញានៃផលចំណេញមួយចំនួនក្នុងពិពិធកម្មឧស្សាហកម្ម ចំនួនការងារក្នុងឧស្សាហកម្មផលិតមិនមែន GTF កើនដល់ ០,២ លានការងារ ឬស្មើនឹងកំណើន ២៥,៩ ភាគរយ ក្នុងអំឡុងពេលដូចគ្នា។ ភាគច្រើននៃផលចំណេញទាំងនេះត្រូវបានឆ្លុះបញ្ចាំងក្នុងឧស្សាហកម្មកែច្នៃលោហធាតុ ដែលចំនួនការងារក្នុងឧស្សាហកម្មនេះមានចំណែកកើនដល់ ៧,០ ភាគរយនៃចំនួនការងារសរុបក្នុងវិស័យកម្មន្តសាល គឺកើនពី ៥,៥ ភាគរយ និងក្នុងឧស្សាហកម្មចំណីអាហារ ភេសជ្ជៈ និងថ្នាំជក់ ដែលចំនួនការងារមានចំណែកកើនដល់ ២,៧ ភាគរយ កើនពី ១,៨ ភាគរយក្នុងអំឡុងពេលដូចគ្នា។

**ចំនួនការងារក្នុងវិស័យកម្មន្តសាលមានចំណែកស្មើនឹង ៥០ ភាគរយនៃចំនួនការងារក្នុងវិស័យឧស្សាហកម្ម ១៨,១ ភាគរយនៃចំនួនការងារក្នុងវិស័យមិនមែនកសិកម្ម និង ១១,៦ ភាគរយនៃចំនួនការងារសរុប។**[7] ត្បិតឧស្សាហកម្មទាំងនេះផ្តល់ប្រាក់ឈ្នួលអប្បបរមាប្រហែល ២០០ ដុល្លារក្នុងមួយខែ ផលជះសេដ្ឋកិច្ចដោយសារផលចំណេញរបស់ប្រជាជន ៥០.៥៧៨ នាក់ដែលមានការងារធ្វើ អាចប៉ាន់ស្មានថាកើនដល់ចន្លោះពី ៦០ លានដុល្លារ ដល់ ៧០ លានដុល្លារ (គិតតែប្រាក់ឈ្នួល និងប្រាក់ឧបត្ថម្ភ) សម្រាប់អំឡុងពេលចាប់ពីខែ តុលា ឆ្នាំ ២០២៣ ដល់ខែ មីនា ឆ្នាំ ២០២៤។

## តម្លៃគម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តស្ទុះឡើង

**តម្លៃគម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត (គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តគ្រប់គ្រាន់ - QIP) កើនដល់ ៤៥៥ លានដុល្លារ ឬស្មើនឹងកំណើន ១៤៩,៨ ភាគរយធៀបនឹងឆ្នាំមុន ក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤ (រូប ៧)។**[8] ទោះជាកំពុងងើបឡើងវិញមែន ប៉ុន្តែតម្លៃគម្រោងដែលបានអនុម័តនេះ នៅតែទាបជាងតម្លៃគម្រោងហិរញ្ញប្បទានពីការ

**រូប ៧. តម្លៃគម្រោង QIP ដែលត្រូវបានអនុម័ត**
*(ពាន់លានដុល្លារ, អចលនទ្រព្យ)*




*ប្រភព ៖* អាជ្ញាធរកម្ពុជា
*ចំណាំ ៖* QIP=គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

**រូប ៨. គម្រោងទទួលបានហិរញ្ញប្បទានពីការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត បែងចែកតាមវិស័យ**
*(លានដុល្លារ, ត្រីមាសទី ១ នៃឆ្នាំ ២០២៤)*




*ប្រភព ៖* អាជ្ញាធរកម្ពុជា

7 ក្រសួងផែនការ ឆ្នាំ ២០២១
8 ទិន្នន័យនេះគ្របដណ្តប់តែគម្រោង QIP ដែលទើបត្រូវបានអនុម័ត និងមានទីតាំងស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេសប៉ុណ្ណោះ។

វិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត ក្នុងអំឡុងពេលដូចគ្នា នៅឆ្នាំ ២០១៩ ដែលមានតម្លៃ ៨៧៨ លានដុល្លារ។ ក្នុងតម្លៃសរុប ៤៥៥ លានដុល្លារនេះ ឧស្សាហកម្មកាត់ដេរទទួលបានការវិនិយោគ ១៦២,៥ លានដុល្លា ឬស្មើនឹង ៣៦,០ ភាគរយនៃតម្លៃវិនិយោគសរុប ចំណែកវិស័យកសិកម្ម និងវិស័យកែច្នៃកសិផលទទួលបានបានការវិនិយោគ ៦១,៤ លានដុល្លារ ឬស្មើនឹង ១៣,០ ភាគរយនៃតម្លៃវិនិយោគសរុប។ វិស័យកម្មន្តសាលមិនមែនកាត់ដេរ ទទួលបានការវិនិយោគ ២៣១,២ លានដុល្លារ ឬស្មើនឹង ៥១ ភាគរយនៃតម្លៃវិនិយោគសរុប (រូប ៨)។ វិស័យកសិកម្ម និងកែច្នៃកសិផល រួមបញ្ចូលគម្រោងចម្ការផ្លែឈើ និងការកែច្នៃ (៤៥,៦ លានដុល្លារ) និងគម្រោងកសិដ្ឋានចិញ្ចឹមជ្រូក និងការកែច្នៃ (១៥,៨ លានដុល្លារ) បញ្ជាក់ពីការកើនឡើងភាពទាក់ទាញការវិនិយោគក្នុងវិស័យកសិកម្ម និងកែច្នៃកសិផល។ សមាសភាគធំបំផុតនៃឧស្សាហកម្មកម្មន្តសាលមិនមែន GTF រួមបញ្ចូលគម្រោងភ្លើងដេគ័រ (lighting decoration) ដែលមានតម្លៃ ៣៦,៦ លានដុល្លារ។

**ការវិនិយោគផ្ទាល់ពីចិន មានចំណែក ៩៥,០ ភាគរយនៃគម្រោងវិនិយោគផ្ទាល់ពីបរទេសសរុបដែលត្រូវបានអនុម័ត គឺមានតម្លៃ ៤៥៥ លានដុល្លារ។** សល់ពីនេះ គឺជាគម្រោងវិនិយោគផ្ទាល់ពីវៀតណាម និងម៉ាឡេស៊ី។ ក្នុងពេលមួយទសវត្សរ៍ចុងក្រោយនេះ ភាគច្រើននៃគម្រោងហិរញ្ញប្បទានដោយការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តនៅកម្ពុជា មានប្រភពពីចិន (រួមទាំងតំបន់រដ្ឋបាលពិសេស ហុងកុង នៃប្រទេសចិន)។ ចំណែកនៃគម្រោងអនុម័តដែលទទួលបានហិរញ្ញប្បទានពីការវិនិយោគផ្ទាល់ពីចិន កើនដល់ ៩០ ភាគរយក្នុងឆ្នាំ ២០២៣ កើនពី ៥៥ ភាគរយក្នុងឆ្នាំ ២០១៤។ លើសពីនេះ មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៃសមាសភាគនៃគម្រោងវិនិយោគផ្ទាល់ពីបរទេស បើធៀបនឹងអំឡុងពេលមុនវិបត្តិកូវីដ-១៩ គឺមានការកើនឡើងនៃចំណែកគម្រោងកម្មន្តសាលមិនមែនកាត់ដេរ និងការថយចុះចំណែកនៃគម្រោងវិនិយោគអចលនទ្រព្យ។ វិស័យកម្មន្តសាលមិនមែនកាត់ដេរ រួមបញ្ចូលឧស្សាហកម្មលោហធាតុ ក្រដាស គ្រឿងសង្ហារិម និងសារធាតុគីមី ក៏ដូចជាឧស្សាហកម្មឡជីស្ទីក ថាមពល និងបដិសណ្ឋារកិច្ច។ ប្រសិនបើឧស្សាហកម្មកម្មន្តសាលថ្មីៗទាំងនេះ ទទួលបានការថែបំប៉នល្អ វានឹងជំរុញឱ្យមានពិពិធកម្មផលិតផល។

**តាមការបង្ហាញក្នុងរូប ៧ ប្រមាណ ៥០ ភាគរយនៃគម្រោង QIP ទទួលបានហិរញ្ញប្បទានក្នុងស្រុក។** ខុសពីគម្រោងដែលទទួលបានហិរញ្ញប្បទានពីការវិនិយោគផ្ទាល់ពីបរទេស គម្រោង QIP ក្នុងស្រុកមានទំហំធំជាង។ គម្រោងភាគច្រើនជាការវិនិយោគលើឧស្សាហកម្មដែលមិនអាចជួញដូរបាន ជាពិសេសហេដ្ឋារចនាសម្ព័ន្ធ និងសំណង់។ មុនវិបត្តិកូវីដ-១៩ គម្រោង QIP ក្នុងស្រុកភាគច្រើនជាការវិនិយោគលើវិស័យសណ្ឋាគារ រីសតផ្សារទំនើប ស៊ីម៉ង់ត៍ និងថាមពល។ ចាប់តាំងពីមានវិបត្តិកូវីដ-១៩ មក គម្រោង QIP ក្នុងស្រុកមួយភាគធំវិនិយោគលើផ្នែកឡជីស្ទីក និងហេដ្ឋារចនាសម្ព័ន្ធកំពង់ផែ ថាមពល កាស៊ីណូ និងកសិឧស្សាហកម្ម។

## ការអភិវឌ្ឍអចលនទ្រព្យបន្តនៅទ្រឹង

**តម្លៃគម្រោងអភិវឌ្ឍន៍អចលនទ្រព្យដែលទទួលបានលិខិតអនុញ្ញាតសាងសង់បន្តស្រុតចុះដំណាលគ្នានឹងការថយចុះនៃសកម្មភាពសាងសង់ និងការទិញលក់អចលនទ្រព្យ។** ក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤ គម្រោងអភិវឌ្ឍន៍អចលនទ្រព្យដែលត្រូវបានអនុម័តមានតម្លៃ ៧៨៦ លានដុល្លារ ឬថយចុះ ៣៨,៨ ភាគរយធៀបនឹងឆ្នាំមុន (រូប ៩)។ ក្នុងនោះ គម្រោងអភិវឌ្ឍន៍អចលនទ្រព្យដែលទទួលបានលិខិតអនុញ្ញាតក្នុងខេត្តព្រះសីហនុ ដែលធ្លាប់មានកំណើនការអភិវឌ្ឍសាងសង់

**រូប ៩. លិខិតអនុញ្ញាតគម្រោងអចលនទ្រព្យដែលត្រូវបានអនុម័ត**

*(លានដុល្លារ)*




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

**រូប ១០. ផ្ទៃក្រឡាក្នុងលិខិតអនុញ្ញាតដែលត្រូវបានអនុម័ត បែងចែកតាមប្រភេទអចលនទ្រព្យ**

*(លានម៉ែត្រការ៉េ)*




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

យ៉ាងឆាប់រហ័សបំផុតកាលពីមុនវិបត្តិកូវីដ-១៩ មានតម្លៃត្រឹមតែ ៧៧,៣ លានដុល្លារ ឬថយចុះ ៥៤,៧ ភាគរយធៀបនឹងឆ្នាំមុន។ ចំនួននៃគម្រោងអភិវឌ្ឍន៍អចលនទ្រព្យតាមម៉ែត្រការ៉េដែលទទួលបានលិខិតអនុញ្ញាត ក៏ថយចុះដូចគ្នា គឺមានតម្លៃត្រឹម ១,៨ លានដុល្លារ ឬថយចុះ ៣៤,៨ ភាគរយធៀបនឹងឆ្នាំមុន ក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤។ ក្នុងឆ្នាំ ២០២៣ ភាពទាក់ទាញវិនិយោគិន[9] ឱ្យវិនិយោគលើវិស័យអចលនទ្រព្យជាពិសេសទីផ្សារលំនៅដ្ឋាន បានងើបឡើងវិញមួយផ្នែក ឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃតម្លៃលិខិតអនុញ្ញាតដែលត្រូវបានអនុម័ត បន្ទាប់ពីវិស័យនេះរងការប៉ះទង្គិចយ៉ាងធ្ងន់ធ្ងរដោយសារវិបត្តិកូវីដ-១៩ នៅអំឡុងឆ្នាំ ២០២០-២២។ ទោះជាយ៉ាងណា ការងើបឡើងវិញនេះ គឺមានរយៈពេលខ្លី ត្បិតសកម្មភាពសាងសង់នៅបន្តស្រុតចុះដោយតម្លៃលំនៅដ្ឋាននៅមិនទាន់សមស្របនឹងទីផ្សារ ទោះបីជាមានការផ្គត់ផ្គង់តិចតួចនូវលំនៅដ្ឋានដែលមានតម្លៃសមរម្យក៏ដោយ។

**ដោយមិនគិតពីការថយចុះជារួម ផ្ទៃក្រឡាអគារឧស្សាហកម្មដែលត្រូវបានអនុម័តសាងសង់ កំពុងមាននិន្នាការកើនឡើង។** ផ្ទៃក្រឡាអគារឧស្សាហកម្មដែលត្រូវបានអនុម័តសាងសង់ កើនដល់ ០,៦៧ លានម៉ែត្រការ៉េ ឬស្មើនឹង ៣៣,៦ ភាគរយនៃផ្ទៃក្រឡាសរុបដែលត្រូវបានអនុម័តសាងសង់ ក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤ កើនពី ០,៦៥ លានម៉ែត្រការ៉េ ឬស្មើនឹង ២១,៥ ភាគរយនៃផ្ទៃក្រឡាសរុប ក្នុងអំឡុងពេលដូចគ្នា កាលពីឆ្នាំ ២០២៣ (រូប ១០)។ ផ្ទុយទៅវិញ ភាពទាញការវិនិយោគលើអគាររស់នៅ (residential property) មានតិចតួចនៅឡើយ ផ្ទៃក្រឡាអចលនទ្រព្យលំនៅដ្ឋានដែលត្រូវបានអនុម័ត ថយមកត្រឹម ០,៧៧ លានម៉ែត្រការ៉េ ឬស្មើនឹង ៣៩,១ ភាគរយនៃផ្ទៃក្រឡាសរុប ថយពី ១,៥ លានម៉ែត្រការ៉េ ឬស្មើនឹង ៤៨,៦ ភាគរយនៃផ្ទៃក្រឡាសរុបក្នុងអំឡុងពេលដូចគ្នានេះ។ ស្រដៀងគ្នានេះ ផ្ទៃក្រឡាអគារពាណិជ្ជកម្មដែលត្រូវបានអនុម័ត ថយមកត្រឹម ០,១៣ លានម៉ែត្រការ៉េ ឬស្មើនឹង ៦,៤ ភាគរយនៃផ្ទៃក្រឡាសរុប ថយពី ០,៦៨ លានម៉ែត្រការ៉េ ឬស្មើនឹង ២២,៣ ភាគរយនៃផ្ទៃក្រឡាសរុប។ ការកើនឡើងនៃផ្ទៃក្រឡាអគារឧស្សាហកម្មដែលត្រូវបានអនុម័ត តែថមថយនូវផ្ទៃក្រឡាអគារលំនៅដ្ឋាន និងផ្ទៃក្រឡាអគារពាណិជ្ជកម្ម អាចឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរភាពទាក់ទាញវិនិយោគិនដែលងាកទៅរកសកម្មភាពក្នុងវិស័យផលិតកម្ម និងកម្មន្តសាល។

## ការនាំចូលសម្ភារសំណង់ទូទៅងើបឡើង

**សមិទ្ធកម្មនៃការនាំចូលសម្ភារសំណង់ទូទៅកើនឡើង បន្ទាប់ពីមានការថយចុះយ៉ាងគំហុកកាលពីពីរបីឆ្នាំមុន ចាប់តាំងពីមានវិបត្តិកូវីដ-១៩។** នៅត្រីមាសទី ១ នៃឆ្នាំ ២០២៤ ការនាំចូលសម្ភារសាងសង់ ដែកថែប និងស៊ីម៉ង់ត៍សម្រាប់ប្រើប្រាស់ក្នុងឧស្សាហកម្មសាងសង់គ្រប់ប្រភេទបានងើបឡើង គឺ បើគិតជាតម្លៃមានកំណើន ១៩,៩ ភាគរយ ៣៣,៥ ភាគរយ និង ១៥,០ ភាគរយរៀងគ្នា ធៀបនឹងឆ្នាំមុន ហើយបើគិតជាបរិមាណ គឺមានកំណើន ១,២ ភាគរយ ៣៥,៩ ភាគរយ និង ២៤,១ ភាគរយរៀងគ្នា។ ខណៈដែលសកម្មភាពសាងសង់អចលនទ្រព្យដែលទទួលហិរញ្ញប្បទានពីវិស័យឯកជនបន្តថយចុះ ការវិនិយោគដោយវិស័យឯកជន និងវិស័យសាធារណៈលើគម្រោងអចលនទ្រព្យមិនមែនលំនៅដ្ឋាន ដែលរួមបញ្ចូលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់ ស្ពាន ឡូជីស្ទីក និងហេដ្ឋារចនាសម្ព័ន្ធកំពង់ផែនៅបន្តមាន ដែលបញ្ជាក់ដោយកើនឡើងនៃចំនួនលិខិតអនុញ្ញាតសាងសង់អគារឧស្សាហកម្ម និងគម្រោង QIP មិនមែនកាត់ដេរដែលទទួលបានហិរញ្ញប្បទានពីការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត។

**រូប ១១. ការនាំចេញផលិតផលកសិកម្មក្នុងរយៈពេល ៣ ខែ**
*(លានដុល្លារ)*




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

**រូប ១២. ចំណែកនៃការនាំចេញផលិតផលកសិកម្ម**
*(ធៀបនឹងឆ្នាំនេះ, % ចំណែកនៃការនាំចេញទំនិញសរុប)*




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

9 ទិន្នន័យលិខិតអនុញ្ញាតិសាងសង់ដែលត្រូវបានអនុម័តមានមិនបានបញ្ជាក់ពីសញ្ជាតិនៃអ្នកវិនិយោគ

### ប្រអប់ទី ២. អង្កេតសហគ្រាសឆ្នាំ ២០២៣ ដោយធនាគារពិភពលោក

**តាមការបង្ហាញក្នុងតារាង B.2.1 មានការថយចុះយ៉ាងខ្លាំងនៃភាគរយក្រុមហ៊ុននៅក្នុងចំនួនក្រុមហ៊ុនសរុបដែលត្រូវបានអង្កេត ដែលរាយការណ៍ពីរបាំងផ្សេងៗដែលបណ្តាលមកពីអស្ថិរភាពនយោបាយ និងលទ្ធភាពទទួលបានហិរញ្ញប្បទានជាដើម។** នេះបញ្ជាក់ពីភាពប្រសើរឡើងនៃបរិយាកាសធុរកិច្ចនៅកម្ពុជា ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក។ ភាពប្រសើរឡើងនៃស្ថិរភាពនយោបាយ បានជះផលវិជ្ជមានលើបរិយាកាសវិនិយោគ និងទំនុកចិត្តធុរកិច្ចនៅកម្ពុជា។ លទ្ធភាពទទួលបានហិរញ្ញប្បទាន មានការវិវត្តគួរឱ្យកត់សម្គាល់ ជាមួយនឹងការកើនឡើងនៃភាពអាចរកបានផលិតផលហិរញ្ញវត្ថុ និងការពង្រីកសេវាដែលទ្រទ្រង់ប្រតិបត្តិការ និងកំណើនធុរកិច្ច។ ក្រៅពីនេះ ហេដ្ឋារចនាសម្ព័ន្ធក៏មានភាពរីកចម្រើនផងដែរ ជាពិសេសគឺភាពប្រសើរឡើងបន្តិចម្តងៗនៃផ្លូវថ្នល់ កំពង់ផែ និងការផ្គត់ផ្គង់អគ្គិសនី ដែលបានទ្រទ្រង់សកម្មភាពធុរកិច្ច និងទាក់ទាញការវិនិយោគពីបរទេស។ កន្លងមក មានកិច្ចខិតខំប្រឹងប្រែងពន្លឿនទីផ្សារការងារតាមរយៈការបង្កើនការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ទោះជាយ៉ាងណា កម្ពុជានៅតែមានបញ្ហាប្រឈមធំៗ ៤។

**សេដ្ឋកិច្ចក្រៅប្រព័ន្ធ ៖ កម្រិតនៃភាពក្រៅប្រព័ន្ធក្នុងសេដ្ឋកិច្ចកម្ពុជា នៅតែជាបញ្ហាប្រឈមដ៏ជ្រាលជ្រៅ និងកំពុងរីកធំបើធៀបនឹងប្រទេសប្រហាក់ប្រហែលគ្នានៅក្នុងតំបន់។** លទ្ធផលនៃអង្កេតសហគ្រាសឆ្នាំ ២០២៣ សម្រាប់កម្ពុជា បានបង្ហាញថា ធុរកិច្ចខ្នាតតូច និងមធ្យមជាច្រើន ត្រូវបានរាយការណ៍ថា ធ្វើប្រតិបត្តិការដោយគ្មានការចុះបញ្ជីផ្លូវការ ឬស្ថិតនៅក្រៅប្រព័ន្ធនិយ័តកម្ម និងប្រព័ន្ធសារពើពន្ធផ្លូវការ។ ខណៈដែលភាពក្រៅប្រព័ន្ធនៅក្នុងវិស័យធុរកិច្ច អាចផ្តល់គុណសម្បត្តិច្រើនដល់ធុរកិច្ចក្រៅប្រព័ន្ធ ជាងក្រុមហ៊ុនក្នុងប្រព័ន្ធដែលអនុលោមតាមវិធាន និងបទបញ្ញត្តិទូទៅ វាក៏អាចធ្វើឱ្យសេដ្ឋកិច្ចទាំងមូលមិនសូវមានភាពប្រកួតប្រជែងផងដែរ ព្រោះជាទូទៅ ធុរកិច្ចក្រៅប្រព័ន្ធមិនសូវមានលទ្ធភាពទទួលបានបច្ចេកវិទ្យាថ្មី ទីផ្សារការងារជំនាញ និងឱកាសនាំចេញ។

**អត្រាពន្ធ ៖ ធុរកិច្ចនានាច្រើនតែលើកឡើងថា កាតព្វកិច្ចពន្ធនៅកម្ពុជាគឺជារបាំងដ៏ធំមួយ។** បន្ទុកពន្ធធ្វើឱ្យប៉ះពាល់ដល់ភាពអាចរកបានប្រាក់ចំណេញ និងជះផលមិនល្អលើសមត្ថភាពហិរញ្ញវត្ថុរបស់ធុរកិច្ចនានាក្នុងការបន្តការវិនិយោគ និងការពង្រីកខ្លួន។ អង្កេតសហគ្រាសឆ្នាំ ២០២៣ បញ្ជាក់ថា ៧១ ភាគរយនៃក្រុមហ៊ុនធំៗយល់ថា បន្ទុកពន្ធគឺជារបាំងដ៏ធំមួយសម្រាប់ប្រតិបត្តិការធុរកិច្ចនៅកម្ពុជា (រូប B.2.1)។ ការតំឡើងបន្ទុកពន្ធអាចបន្ទុចបង្អាក់ការវិនិយោគ ជាពិសេសក្នុងវិស័យដែលប្រាក់ចំណេញដុល មានតិចស្រាប់ទៅហើយនោះ។ បើធៀបនឹងប្រទេសប្រហាក់ប្រហែលគ្នាក្នុងតំបន់ អត្រាពន្ធនៅកម្ពុជាគឺខ្ពស់ជាង។ នេះអាចធ្វើឱ្យធុរកិច្ចនៅកម្ពុជា បាត់បង់ឧត្តមភាពប្រៀបធៀប។ ចំណុចនេះមានភាពពាក់ព័ន្ធបំផុតជាពិសេសសម្រាប់ការទាក់ទាញការវិនិយោគពីបរទេស ដែលក្រុមហ៊ុននានាអាចជ្រើសរើសយកទីតាំងដែលមានលក្ខខណ្ឌពន្ធអំណោយផលជាងនេះ។

**រដ្ឋបាលពន្ធ ៖ ទន្ទឹមនឹងអត្រាពន្ធ របៀបចាត់ចែងពន្ធ គឺរបៀបនៃការប្រមូល ដំណើរការ និងពង្រឹងការអនុវត្តពន្ធ គឺជាបញ្ហាប្រឈមដ៏ធំមួយដែរ។** នេះបើយោងតាមការលើកឡើងដោយក្រុមហ៊ុនធំៗជាច្រើន។ ការពិនិត្យឡើងវិញលើចំណាយសាធារណៈរបស់កម្ពុជាដោយធនាគារពិភពលោក គូសបញ្ជាក់ថា រដ្ឋបាលពន្ធនៅកម្ពុជាត្រូវបានសន្មតថា មានលក្ខណៈស្មុគស្មាញ។ អប្រសិទ្ធភាព និងភាពមិនច្បាស់លាស់ក្នុងប្រព័ន្ធរដ្ឋបាលពន្ធ អាចបង្កភាពមិនប្រាកដប្រជា និងបង្កើនចំណាយលើអនុលោមភាពសម្រាប់ធុរកិច្ចនានា។ ក្រៅពីនេះ អន្តរកម្មញឹកញាប់ជាមួយមន្ត្រីពន្ធដែលតម្រូវដោយភាពស្មុគស្មាញទាំងនេះ បានបង្កើនចំណាយជារួមលើការធ្វើធុរកិច្ច។

**ការដឹកជញ្ជូន ៖ ទោះបីជាសម្រេចបានវឌ្ឍនភាពយ៉ាងច្រើនក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកក៏ដោយ ប៉ុន្តែការដឹកជញ្ជូនត្រូវបានកំណត់ជារបាំងធំបំផុតទី ៤ ដោយធុរកិច្ចខ្នាតតូច និងមធ្យមនៅកម្ពុជា។** ថ្វីបើភាគរយក្រុមហ៊ុនដែលលើកឡើងថា នេះជាឧបសគ្គធំមួយ គឺប្រហាក់ប្រហែលគ្នានឹងបណ្តាប្រទេសក្នុងតំបន់ក្តី ប៉ុន្តែគុណភាព និងវិសាលភាពនៃហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននៅកម្ពុជា នៅយឺតខ្លាំងជាងបណ្តាប្រទេសក្នុងតំបន់។ យោងតាមការចាត់កម្រិតភាពប្រកួតប្រជែងដោយវេទិកាសេដ្ឋកិច្ចពិភពលោក ក្នុងឆ្នាំ ២០១៩ កម្ពុជាមានពិន្ទុ ៣,៦/៧ សម្រាប់គុណភាពផ្លូវ ដែលជាពិន្ទុទាបបំផុតទី ២ នៅក្នុងតំបន់។ ក្នុងការប្រៀបធៀប ប្រទេស ដូចជា សិង្ហបុរី នាំមុខគេ ជាមួយនឹងពិន្ទុ ៦,៥ បន្ទាប់មកគឺម៉ាឡេស៊ី (ពិន្ទុ ៥,៣) ថៃ (ពិន្ទុ ៤,៤) វៀតណាម (ពិន្ទុ ៣,៤) និងឡាវ (ពិន្ទុ ៣,៧)។ ផ្លូវថ្នល់មិនគ្រប់គ្រាន់ ភាពមានកម្រិតនៃការដឹកជញ្ជូនតាមផ្លូវដែក និងហេដ្ឋារចនាសម្ព័ន្ធកំពង់ផែអន់ថយ បានរួមចំណែកធ្វើឱ្យមានចំណាយខ្ពស់ផ្នែកឡូជីស្ទីក និងអប្រសិទ្ធភាពក្នុងខ្សែច្រវាក់ផ្គត់ផ្គង់។ នេះមិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់ធុរកិច្ចក្នុងស្រុកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកាត់បន្ថយភាពទាក់ទាញរបស់កម្ពុជា ក្នុងនាមជាគោលដៅសម្រាប់ការវិនិយោគពីបរទេសទៀតផង។

## តារាង B.២.១. លទ្ធផលរកឃើញពីអង្កេតសហគ្រាស
*(% នៃក្រុមហ៊ុន)*

| របាំង | KH13 | KH16 | KH23 | SG23 | VN23 | EAP23 |
|---|---|---|---|---|---|---|
| លទ្ធភាពទទួលបានហិរញ្ញវត្ថុ | 1 | 8 | 0 | 3 | 21 | 21 |
| លទ្ធភាពទទួលបានដីធ្លី | 4 | 5 | 1 | 1 | 3 | 4 |
| អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាត | 0 | 3 | 1 | 7 | 5 | 3 |
| អំពើពុករលួយ | 13 | 7 | 0 | 1 | 0 | 3 |
| តុលាការ | 6 | 1 | 1 | 0 | 0 | 1 |
| បទល្មើស ចោរកម្ម និងអសណ្តាប់ធ្នាប់ | 2 | 2 | 4 | 0 | 3 | 3 |
| គយ និងបទបញ្ញត្តិពាណិជ្ជកម្ម | 1 | 0 | 2 | 8 | 5 | 3 |
| អគ្គិសនី | 28 | 2 | 3 | 2 | 4 | 5 |
| កម្លាំងពលកម្មគ្មានជំនាញ | 6 | 12 | 0 | 24 | 12 | 9 |
| បទបញ្ញត្តិការងារ | 3 | 1 | 0 | 38 | 2 | 4 |
| អស្ថិរភាពនយោបាយ | 9 | 16 | 0 | 0 | 4 | 5 |
| ភាពក្រៅប្រព័ន្ធ | 13 | 28 | 42 | 4 | 22 | 19 |
| ការគ្រប់គ្រងពន្ធ | 0 | 1 | 9 | 2 | 5 | 3 |
| អត្រាពន្ធ | 12 | 6 | 32 | 5 | 9 | 11 |
| ការដឹកជញ្ជូន | 2 | 7 | 6 | 6 | 6 | 6 |

*ប្រភព ៖* អង្កេតសហគ្រាស ធនាគារពិភពលោក

*ចំណាំ ៖* EAP= អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក, KH=កម្ពុជា, SG=សិង្ហបុរី, VN=វៀតណាម

## រូប B.២.១. របាំងធំៗទាំង ៥ ក្នុងឆ្នាំ ២០២៣
*(% នៃក្រុមហ៊ុន)*




## ផលិតកម្មដំណាំកើនឡើង

**ទោះបីជាលក្ខខណ្ឌធាតុអាកាសមិនសូវអំណោយផល ដោយសារការកើតមានគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតក្តី ប៉ុន្តែផលិតកម្មកសិកម្មមានភាពប្រសើរឡើង។** ផលិតកម្មដំណាំ ដែលមានចំណែក ៥៧,១ ភាគរយនៃ ផសស សម្រាប់វិស័យកសិកម្ម គឺកើនដល់ ៣៦,៨ លានតោន ឬស្មើនឹងកំណើន ៦ ភាគរយធៀបនឹងឆ្នាំមុន ក្នុងឆ្នាំ ២០២៣។10 ផលិតកម្មស្រូវ កើនដល់ ១២,៥ លានតោន ឬស្មើនឹងកំណើន ៧,៥ ភាគរយ ធៀបនឹងឆ្នាំមុន។ ក្នុងកំណើន ៧,៥ ភាគរយនេះ ការពង្រីកផ្ទៃដីដាំដុះរួមចំណែក ៣,២ ភាគរយ ហើយការបង្កើនទិន្នផល រួមចំណែក ៤,៣ ភាគរយ។ ទិន្នផលស្រូវជាមធ្យម កើនដល់ ៣,៥៦ តោនក្នុងមួយហិចតា ក្នុងឆ្នាំ ២០២៣ កើនពី ៣,៤២ តោនក្នុងមួយហិចតា ក្នុងឆ្នាំ ២០២២។ ក្នុងឆ្នាំ២០២៣ ផលិតកម្មស្រូវវស្សាកើនដល់ ៩,៣៥ លានតោន ចំណែកផលិតកម្មស្រូវប្រាំងកើនដល់ ៣,១៤ លានតោន គឺកើនពី ៨,៧១ លានតោន និង ២,៩២ លានតោនរៀងគ្នា ក្នុងឆ្នាំ ២០២២។ ចំណែកនៃស្រូវប្រាំងធៀបនឹងផលិតកម្មស្រូវសរុប កើនដល់ ២៥,១ ភាគរយក្នុងឆ្នាំ ២០២៣ កើនពី ២៣,៣ ភាគរយ កាលពីមួយទសវត្សរ៍មុន បញ្ជាក់ពីភាពប្រសើរឡើងតិចតួចនៃបច្ចេកទេសស្រោចស្រពដំណាំស្រូវ។

**ការដាំដុះ និងផលិតកម្មដំណាំឧស្សាហកម្ម មានលក្ខណៈចម្រុះ។** ក្នុងឆ្នាំ ២០២៣ ផលិតកម្មកៅស៊ូ កើនដល់ ៣៩១.៨០០ តោន ឬស្មើនឹងកំណើន ៥,១ ភាគរយធៀបនឹងឆ្នាំមុន។ ប៉ុន្តែផលិតកម្មដំឡូងមី ថយមកត្រឹម ១៤,២ លានតោន ស្មើនឹងការថយចុះ ០,៥ ភាគរយធៀបនឹងឆ្នាំមុន។ ផលិតកម្មផ្លែឈើ ដែលរួមបញ្ចូលចេក និងស្វាយ កើនរៀងគ្នាដល់ ០,៩ លានតោន ឬស្មើនឹងកំណើន ៥,០ ភាគរយធៀបនឹងឆ្នាំមុន និង ២,២ លានតោន ឬស្មើនឹងកំណើន ១៤,៦ ភាគរយធៀបនឹងឆ្នាំមុន។

## កម្ពុជាកំពុងប្រែក្លាយទៅជាប្រទេសនាំចេញកសិផលដ៏សំខាន់មួយ

**ការនាំចេញកសិផលរបស់កម្ពុជា បន្តកើនឡើង គឺកើនដល់ ៤,០ ពាន់លានដុល្លារក្នុងឆ្នាំ ២០២៣ (រូប ១១)។** ការនាំចេញកសិផលកើនជិត ៤ ដងក្នុងរយៈពេល ១ ទសវត្សរ៍កន្លងមកនេះ។ ខុសពីវិស័យសេដ្ឋកិច្ចផ្សេងទៀត កសិកម្មនៅតែមានភាពធន់ ក្នុងអំឡុងវិបត្តិកូវីដ-១៩។ ក្នុងឆ្នាំ ២០២២ កម្ពុជាស្ថិតក្នុងចំណោមប្រទេសផលិតស្រូវឈានមុខគេទាំង ៩ ក្នុងពិភពលោក។11 ទ្រទ្រង់មួយផ្នែកដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីមួយចំនួនដែលទើបត្រូវបានចុះហត្ថលេខា បច្ចុប្បន្ន កម្ពុជាកំពុងប្រែក្លាយជាប្រទេសនាំចេញផលិតផលកសិកម្មដ៏សំខាន់មួយ។ បើគិតជាចំណែកនៃការនាំចេញទំនិញសរុប ការនាំចេញកសិផលកើនដល់ ២០,៤ ភាគរយ ក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤ កើនពី ៦,៣ ភាគរយក្នុងខែ ធ្នូ ឆ្នាំ ២០១៣ (រូប ១២)។ នៅត្រីមាសទី ១ នៃឆ្នាំ ២០២៤ ការនាំចេញទំនិញកសិកម្មរបស់កម្ពុជា កើន ២៨,១ ភាគរយធៀបនឹងឆ្នាំមុន គឺកើនដល់ ១,១ ពាន់លានដុល្លារ និងរួមចំណែក ១៧,៤ ភាគរយដល់ការនាំចេញទំនិញសរុប គឺនៅលេខរៀងបន្ទាប់ពីការនាំចេញសំលៀកបំពាក់ ដែលមានតម្លៃ ២,០ ពាន់លានដុល្លារ។ ផលិតផលកសិកម្មបែបប្រពៃណីសំខាន់ៗ គឺស្រូវអង្ករ ដំឡូងមី កៅស៊ូ និងផលិតផលឈើ។ ផលិតផលកសិកម្មទាំងនេះរួមបញ្ចូល

10 Ministry of Agriculture, Forestry & Fisheries 2023

11 Food and Agriculture Organization 2022

គ្នា មានចំណែក ៨០ ភាគរយនៃការនាំចេញកសិផលសរុប។ ក្រៅពីការនាំចេញផលិតផលកសិកម្មបែបប្រពៃណី ការនាំចេញគ្រាប់ស្វាយចន្ទី និងផ្លែឈើស្រស់ ជាពិសេសចេក និងស្វាយក៏កំពុងកើនឡើងផងដែរ ដោយរួមចំណែកប្រមាណ ១៦,០ ភាគរយដល់ការនាំចេញកសិផលសរុប ទោះបីជានៅកម្ពុជាមានការចំណាយខ្ពស់លើការដឹកជញ្ជូន និងឡូជីស្ទិកក៏ដោយ។

**ថ្វីបើសម្រេចបានវឌ្ឍនភាពមែន ប៉ុន្តែកសិកម្មចិញ្ចឹមក្រពះនៅតែតំណាងឲ្យមួយភាគធំនៅក្នុងវិស័យកសិកម្មរបស់កម្ពុជា។** យោងតាមអង្កេតកសិកម្មកម្ពុជា ឆ្នាំ ២០២១ គេប៉ាន់ស្មានថា ៦៣ ភាគរយនៃគ្រួសារទាំងអស់ប្រកបរបរកសិកម្ម។ ៥៨ ភាគរយនៃគ្រួសារដែលធ្វើកសិកម្មប្រើប្រាស់កសិផលសម្រាប់ការបរិភោគក្នុងគ្រួសារ ចំណែកផលិតកម្មកសិកម្មរបស់គ្រួសារដែលធ្វើកសិកម្ម ៤២ ភាគរយទៀតគឺភាគច្រើនសម្រាប់លក់ដូរ។ ប្រមាណ ៩៤ ភាគរយនៃគ្រួសារធ្វើកសិកម្មទាំង ២ លានគ្រួសារ ដាំដុះដំណាំ បានន័យថា វឌ្ឍនភាពមានតិចតួចសម្រាប់ផលិតកម្មបសុសត្វដែលមានតម្លៃបន្ថែមខ្ពស់។[12] ខណៈដែលអង្ករក្រអូប (aromatic rice) មានចំណែក ៨០ ភាគរយនៃការនាំចេញអង្ករសរុបរបស់កម្ពុជា ប្រជាជនកម្ពុជាដាំដុះស្រូវដែលមិនមែនជាស្រូវក្រអូប ដែលមានចំណែក ៥៩,១ ភាគរយ (២,១ លានហិចតា) នៃផ្ទៃដីបង្កបង្កើនផលសរុប និង ៥៩,២ ភាគរយ (២,០៨ លានហិចតា) នៃផ្ទៃដីប្រមូលផលសរុបក្នុងឆ្នាំ ២០២៣ ព្រោះការផលិតពូជស្រូវដែលមានគុណភាពខ្ពស់នៅតែជាបញ្ហាប្រឈមមួយ។

**ក្រៅពីនេះ ក្រុមហ៊ុននាំចេញទំនិញកសិកម្មបានលើកឡើងពីបញ្ហាប្រឈមក្នុងការនាំចេញទំនិញកសិកម្មរបស់កម្ពុជា ជាពិសេសផ្លែឈើស្រស់ ដោយសារកង្វះខ្សែច្រវាក់ត្រជាក់ (cold chain)។** ការអភិវឌ្ឍខ្សែច្រវាក់ត្រជាក់ នឹងអាចឱ្យកម្ពុជាប្រឡូកក្នុងទីផ្សារផលិតផលងាយរលួយក្នុងពិភពលោក (global perishable products) ក្នុងនាមជាប្រទេសនាំចេញ។ កង្វះប្រព័ន្ធធ្វើឱ្យត្រជាក់ កន្លែងស្តុកទុកត្រជាក់ និងការដឹកជញ្ជូនដោយត្រជាក់ ធ្វើឱ្យការដឹកជញ្ជូនផលិតផលដែលងាយខូចគុណភាពដោយសារសីតុណ្ហភាព នៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់តាមរយៈវិធីវេចខ្ចប់ដោយកម្តៅ និងក្លាសេ ក្លាយជាបញ្ហាប្រឈមដ៏ធំមួយ។ កង្វះឡូជីស្ទិកខ្សែច្រវាក់ត្រជាក់នៅកម្ពុជា ត្រូវបានគោយការណ៍ថាធ្វើឱ្យផលិតផលស្អុយរលួយចោល ហើយដែលបង្កផលជះអវិជ្ជមានលើប្រាក់ចំណូលរបស់កសិករដាំដុះឈើហូបផ្លែ និងក្រុមហ៊ុននាំចេញ។

## *ចាំបាច់ត្រូវកែលម្អបរិយាកាសធុរកិច្ចឱ្យកាន់តែប្រសើរឡើង*

**អង្កេតសហគ្រាសឆ្នាំ ២០២៣[13] គូសបញ្ជាក់ថា គេត្រូវរងចាំ ២៨ ថ្ងៃ ដើម្បីទទួលបានអាជ្ញាប័ណ្ណនាំចូល ក្នុងប្រទេសកម្ពុជា ធៀបនឹងរយៈពេល ១១ ថ្ងៃក្នុងប្រទេសវៀតណាម រយៈពេល ៩ ថ្ងៃក្នុងប្រទេសឥណ្ឌូនេស៊ី និងរយៈពេល ៧ ថ្ងៃក្នុងប្រទេសសិង្ហបុរី។** ស្រដៀងគ្នានេះ គេត្រូវចំណាយពេល ៣០ ថ្ងៃដើម្បីទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិការធុរកិច្ចក្នុងប្រទេសកម្ពុជា ធៀបនឹងរយៈពេល ១៣ ថ្ងៃក្នុងប្រទេសវៀតណាម រយៈពេល ៩ ថ្ងៃក្នុងប្រទេសឥណ្ឌូនេស៊ី និងរយៈពេល ១៧ ថ្ងៃក្នុងប្រទេសសិង្ហបុរី (រូប ១៣)។ ការអូសបន្លាយពេលក្នុងការទទួលបានអាជ្ញាប័ណ្ណ អាចធ្វើឱ្យសហគ្រិនត្រូវចំណាយច្រើនត្បិតវាបានបន្ថែមភាពមិនប្រាកដប្រជា និងចំណាយផ្សេងទៀតលើប្រតិបត្តិការធុរកិច្ចដែលចាំបាច់ជាង។ អង្កេតសហគ្រាសឆ្នាំ ២០២៣ គូសបញ្ជាក់ថា របាំងបរិយាកាសធុរកិច្ចធំបំផុត

**រូប ១៣. អង្កេតសហគ្រាសឆ្នាំ ២០២៣-ការប្រៀបធៀបក្នុងតំបន់**




*ប្រភព ៖ អង្កេតសហគ្រាស ធនាគារពិភពលោក*

**រូប ១៤. អង្កេតសហគ្រាសសម្រាប់កម្ពុជារបាំងធំៗ ១០ ក្នុងបរិយាកាសធុរកិច្ច**
*(% នៃក្រុមហ៊ុន)*




*ប្រភព ៖ អង្កេតសហគ្រាស ធនាគារពិភពលោក*

12 Ministry of Planning 2021.

13 ធនាគារពិភពលោក ២០២៣a, https://www.enterprisesurveys.org/en/data/exploreeconomies/2023/cambodia.

៣ គឺការអនុវត្តរបស់វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ[14] អត្រាពន្ធ និងរដ្ឋបាលពន្ធ (រូប ១៤)។ ខណៈការកែលម្អរដ្ឋបាលពន្ធ បានជួយបង្កើនការប្រមូលពន្ធក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក វាក៏អាចនាំឱ្យមានការបង្កើនបន្ទុករដ្ឋបាលពន្ធលើវិស័យឯកជន ជាពិសេសសហគ្រាសក្នុងប្រព័ន្ធ។ ជាផ្លូវការអត្រាពន្ធមិនត្រូវបានកែប្រែនោះទេចាប់តាំងពីឆ្នាំ ២០១៣ មក។ អត្រាពន្ធដែលត្រូវបានសន្មតជារបាំងមួយក្នុងចំណោមរបាំងធំបំផុត ២ អាចបណ្តាលមកពីការបង្កើនអនុលោមភាព ដោយអាជ្ញាធរកម្ពុជាបានពង្រឹងរដ្ឋបាលពន្ធដើម្បីទប់ស្កាត់ការគេចពន្ធ។

**របាំងធំបំផុតទី ៤ លើធុរកិច្ច ដែលបានលើកឡើងក្នុងអង្កេតសហគ្រាសនៅកម្ពុជា២០២៣ គឺការដឹកជញ្ជូន។** ចំណុចនេះមានការប្រែប្រួលតិចតួចប៉ុណ្ណោះ ដោយក្នុងឆ្នាំ ២០១៦ គេរកឃើញថា ការដឹកជញ្ជូនជារបាំងមួយក្នុងចំណោមរបាំងធំបំផុត ២។ បញ្ហាពាក់ព័ន្ធនឹងការដឹកជញ្ជូន ដែលនៅតែត្រូវបានសន្មតជាឧបសគ្គមួយសម្រាប់ប្រតិបត្តិការក្រុមហ៊ុន អាចមានដូចជាចំណាយខ្ពស់ និងទំនុកចិត្តលើសមិទ្ធកម្មឡូជីស្ទីករបស់កម្ពុជា។ ក្រៅពីនេះ ទំនុកចិត្តលើការផ្គត់ផ្គង់អគ្គិសនីនៅតែជារបាំងចម្បងមួយ ដោយក្រុមហ៊ុន ៤៣ ភាគរយក្នុងការអង្កេតនេះ លើកឡើងថា ធ្លាប់ប្រឈមនឹងការដាច់ភ្លើង។ ការខាតបង់មានកាន់តែច្រើនដោយសារការដាច់ភ្លើង ព្រោះចំណាយពាក់ព័ន្ធកើនពី ០,៣ ភាគរយនៃការលក់ប្រចាំឆ្នាំ ក្នុងឆ្នាំ ២០១៣ ដល់ ១,១ ភាគរយក្នុងឆ្នាំ ២០២៣ គឺខ្ពស់ជាងតណ្ឌេនេស៊ី (០,២ ភាគរយ) វៀតណាម (០,២ ភាគរយ) និងសិង្ហបុរី (០ ភាគរយ)។ ទំនុកចិត្តទាប (និងចំណាយខ្ពស់) លើការផ្គត់ផ្គង់អគ្គិសនី ធ្លាប់ត្រូវបានលើកឡើងដោយក្រុមហ៊ុននានាថាជាមូលហេតុមួយដែលធ្វើឱ្យកម្ពុជាមិនអាចធ្វើអន្តរកាលឆ្ពោះទៅរក និងប្រឡូកក្នុងខ្សែច្រវាក់តម្លៃសកលកម្រិតខ្ពស់ដែលមានដូចជា គ្រឿងបន្លាស់ និងគ្រឿងបង្គុំយានយន្ត ការផ្គុំដំឡើងគ្រឿងអេឡិចត្រូនិកនិងការផលិតឧបករណ៍វេជ្ជសាស្ត្រ។[15] សូមមើលប្រអប់ទី ២ សម្រាប់ព័ត៌មានលម្អិតស្តីពីលទ្ធផលរកឃើញក្នុងអង្កេតសហគ្រាសឆ្នាំ ២០២៣។

## *ការប្រើប្រាស់ដោយវិស័យឯកជនមានភាពប្រសើរឡើងបន្តិច*

**ការប្រើប្រាស់ដោយវិស័យឯកជនបានកើនឡើងបន្តិចក្នុងឆ្នាំ ២០២៤ ដែលមានការថយចុះយ៉ាងខ្លាំងក្នុងឆ្នាំ ២០២៣ នៅពេលដែលការទប់តម្រូវការក្នុងស្រុកដែលធ្វើឡើងតែម្តង (one-off pent-up) លែងអាចធ្វើទៅបាន។** តាមការពិភាក្សាការនាំចេញផលិតផលកម្មន្តសាលរបស់កម្ពុជាបានចាប់ផ្តើមងើបឡើងវិញ ចាប់តាំងពីត្រីមាសទី ៤ នៃឆ្នាំ ២០២៣ ដោយបានបង្កើនចំនួនការងារ និងចំណូល។ វិស័យកម្មន្តសាលតែម្យ៉ាងបានបង្កើតការងារថ្មីសរុប ៥០.៥០០ ការងារ ឬស្មើនឹងកំណើន ៥ ភាគរយធៀបនឹងឆ្នាំមុន។ ករណីនេះបានគាំទ្រការចំណាយរបស់អ្នកប្រើប្រាស់។ ការបន្ធូរបន្ថយគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ធ្វើឱ្យប្រសើរឡើងនូវសន្ទនីយភាពទីផ្សារ

**រូប ១៥. ការនាំចូលទំនិញប្រើប្រាស់ មានភាពប្រសើរឡើង** *(ប្រែប្រួលជាភាគរយធៀបនឹងឆ្នាំនេះ)*




*ប្រភព ៖* អាជ្ញាធរកម្ពុជា

**រូប ១៦. អតិផរណា ថយចុះការរួមចំណែកដល់អតិផរណា រយៈពេល ១២ ខែ** *(ភាគរយ)*




*ប្រភព ៖* អាជ្ញាធរកម្ពុជា

14 សហគ្រាសចុះបញ្ជីផ្លូវការត្រូវគោរពច្បាប់ និងបញ្ញត្តិរបស់រាជរដ្ឋាភិបាល។ ការបង់ពន្ធជាបច្ច័យមួយនៃការចុះបញ្ជីផ្លូវ។សហគ្រាសខ្លះគេចវេសមិនបង់ពន្ធដោយមិនចុះបញ្ជីពាណិជ្ជកម្ម ហើយនៅបន្តស្ថិតក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដ៏ធំមួយជាឧបសគ្គសម្រាប់ការប្រកួតប្រជែងរបស់សហគ្រាសចុះបញ្ជីផ្លូវការ ដោយហេតុថាសហគ្រាសមិនចុះបញ្ជីអាចអនុវត្តសកម្មភាពដែលផ្តល់ផលប្រយោជន៍មិនស្មើភាពចំពោះសហគ្រាសចុះបញ្ជីដែលត្រូវអនុលោមតាមបញ្ញត្តិប្រកួតប្រជែងនានា។

15 World Bank 2019; https://www.worldbank.org/en/country/cambodia/publication/cambodia-economic-update-december-2019-upgrading-cambodia-in-global-value-chains

ទោះបីជាមានការដំឡើងអត្រាការប្រាក់ក៏ដោយ (សូមមើលការពិភាក្សា ក្រោមផ្នែកស្ដីពីរូបិយវត្ថុ ខាងក្រោម)។ បន្ថែមលើនេះ ការនាំចេញសេវាកម្ម ជាពិសេសចំណូលពីទេសចរណ៍កើនឡើងដោយសារកំណើននៃចំនួនភ្ញៀវទេសចរណ៍ដែលចូលមកទស្សនាកម្ពុជា។ ដោយការប្រើប្រាស់ក្នុងស្រុកមានចំណែកប្រមាណ ២ ភាគ ៣ នៃ ផសស ការងើបឡើងវិញមួយផ្នែកនៃអនុវិស័យនេះ បានចាប់ផ្ដើមគាំទ្រសកម្មភាពលក់រាយ និងលក់ដុំ ដែលឆ្លុះបញ្ចាំងក្នុងកំណើននៃការនាំចូលទំនិញប្រើប្រាស់។

**ជាលទ្ធផល ការនាំចូលទំនិញប្រើប្រាស់មិនជាប់ធន់កើនបន្តិច។** ក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤ មុខទំនិញប្រើប្រាស់មិនជាប់ធន់សំខាន់ៗដែលបាននាំចូល មានដូចជា ប្រេងម៉ាស៊ូត គ្រឿងអេឡិចត្រូនិក សាំង គ្រឿងឧបភោគបរិភោគ សំលៀកបំពាក់ និងភេសជ្ជៈមានហ្គាស កើនរៀងគ្នា ១៧,១ ភាគរយ ៤២,៥ ភាគរយ ២៨,៧ ភាគរយ ៦,១ ភាគរយ ៨,៤ ភាគរយ និង ២៦,៩ ភាគរយ (រូប ១៥)។ ទោះជាយ៉ាងណា ការងើបឡើងវិញដំណាក់កាលដំបូងនៃតម្រូវការក្នុងស្រុក ដែលបានជួយជំរុញការនាំចូលទំនិញ ទំនងជាមិនមាននិរន្តរភាពឡើង ត្បិតកំណើនឥណទានក្នុងស្រុកមានការស្រុតចុះគួរឱ្យកត់សម្គាល់។

**ខណៈដែលការនាំចូលទំនិញប្រើប្រាស់មិនជាប់ធន់ងើបឡើងវិញ ការនាំចេញទំនិញប្រើប្រាស់ជាប់ធន់នៅតែថយចុះ។** ក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤ ការនាំចូលយានយន្តគ្រប់ប្រភេទ ដូចជា ម៉ូតូ រថយន្តដឹកអ្នកដំណើរ រថយន្តធុនធំ រថយន្តក្រុង ត្រាក់ទ័រ និងយានយន្តផ្សេងទៀត ថយចុះ ៣,៥ ភាគរយ ធៀបនឹងឆ្នាំមុន។ ទោះជាមានកំណើនការងារក្នុងវិស័យកម្មន្តសាលមែន ប៉ុន្តែគ្រួសារនៅតែប្រឈមនឹងកំណើនប្រាក់ឈ្នួលយឺត ដោយកំណើនប្រាក់ឈ្នួលអប្បបរមានៅក្នុងវិស័យកម្មន្តសាលនាំចេញមានត្រឹមតែ ២ ភាគរយ និងកំណើនយឺតក្នុងទីផ្សារការងារ ដែលមួយភាគធំបណ្ដាលមកពីភាពនៅទ្រឹងនៃសកម្មភាពសាងសង់ ការពិចារណាល្អិតល្អន់មុននឹងទិញទំនិញប្រើប្រាស់ជាប់ធុន ជាពិសេសចំពេលដែលចំណាយលើការខ្ចីប្រាក់នៅតែខ្ពស់ដដែល។ យើងមិនអាចធ្វើការវាយតម្លៃស៊ីជម្រៅបានទេ ព្រោះគ្មានទិន្នន័យជាក់ស្ដែងស្ដីពីចំណាយបុគ្គលលើទំនិញជាប់ធន់ និងទំនិញមិនជាប់ធន់ និងសេវាកម្មនានា ជាពិសេសទិន្នន័យការលក់រាយ ដើម្បីវាស់ស្ទង់តម្រូវការទំនិញសម្រេចរបស់អ្នកប្រើប្រាស់។

## អតិផរណាធ្លាក់ដល់ 0 ក្នុងរយៈពេល ១២ ខែ គិតត្រឹមដំណាច់ខែ មីនា ឆ្នាំ ២០២៤

**នៅពេលដែលថ្លៃម្ហូបអាហារថមថយ ដោយសារការធ្លាក់ចុះតម្រូវការក្នុងស្រុក សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់របស់កម្ពុជា (CPI) បានធ្លាក់ចុះយ៉ាងគំហុកក្នុងខែ មីនា ឆ្នាំ ២០២៤ គឺធ្លាក់ដល់ 0,0 ភាគរយធៀបនឹងឆ្នាំមុន ដែលជាអត្រាទាបបំផុតក្នុងរយៈពេល ១៥ ឆ្នាំមកនេះ (រូប ១៦) ថយពី 0,៧ ភាគរយ ក្នុងអំឡុងពេលដូចគ្នា នៅឆ្នាំ ២០២៣។** ក្រោយវិបត្តិកូវីដ-១៩ អតិផរណាឡើងខ្ពស់បំផុតក្នុងខែ មិថុនា ឆ្នាំ ២០២២ គឺឡើងដល់ ៧,៨ ភាគរយ ដែលជាអត្រាខ្ពស់បំផុតក្នុងរយៈពេល ១៣ ឆ្នាំ មួយភាគធំគឺដោយសារការហក់ឡើងនៃថ្លៃម្ហូបអាហារ និងផលិតផលប្រេងកាត ដែលបណ្ដាលមកពីការអង្រួនថ្លៃស្បៀងអាហារ និងប្រេងក្នុងពិភពលោក។ ការថយចុះនៃថ្លៃម្ហូបអាហារ ជាពិសេសថ្លៃស្រូវអង្ករ ត្រី សាច់ និងបន្លែ បានទាញទម្លាក់អតិផរណា ត្បិតសមាសភាគ (សន្ទស្សន៍រង) នៃម្ហូបអាហារ មានចំណែក ៤៣ ភាគរយនៃកន្ត្រកអតិផរណា។

**ការរួមចំណែកនៃសន្ទស្សន៍រងម្ហូបអាហារដល់អតិផរណាធ្លាក់ដល់ 0 ក្នុងខែ មីនា ឆ្នាំ ២០២៤ ថយពី ១,៣ ភាគរយ ក្នុងអំឡុងពេលដូចគ្នា នៅឆ្នាំ ២០២៣ ដោយសារការធ្លាក់ថ្លៃស្រូវអង្ករ ត្រី សាច់ និងបន្លែ។** ក្នុងអំឡុងពេលដូចគ្នានេះ ការរួមចំណែកនៃសន្ទស្សន៍រងលំនៅដ្ឋាន និងទឹកភ្លើង នៅតែមាន

**រូប ១៧. អតិរេកគណនីចរន្ត គឺខ្ពស់មិនធ្លាប់មាន**
*(ភាគរយនៃ ផសស)*




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

**រូប ១៨. ប្រាក់រៀលឡើងថ្លៃ ធៀបនឹងរូបិយវត្ថុក្នុងតំបន់**




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

## ប្រអប់ទី ៣. អតិរេកគណនីចរន្ត ឆ្នាំ ២០២៣

**ភាគរយដែលបានកត់ត្រាក្នុងឆ្នាំ នៅអំឡុងឆ្នាំ ២០១០-២០១៩ កម្ពុជាមានឱនភាពគណនីចរន្តយ៉ាងធំ ដែលជាមធ្យមស្មើនឹង ៩,០ ភាគរយនៃ ផសស ក្នុងមួយឆ្នាំ (រូប ខ.៣.១)។** ទោះបីជាឱនភាពគណនីចរន្តមិនមែនជាបច្ច័យល្អ ហើយក៏មិនមែនជាបច្ច័យអាក្រក់ ប៉ុន្តែវាប្រហែលជាគ្មាននិរន្តរភាព និងនាំទៅរកផលវិបាកមិនល្អ នៅពេលដែលមានវាទំហំធំ ជំរុញការប្រើប្រាស់ជាជាងការវិនិយោគ កើតឡើងទន្ទឹមនឹងគ្នានឹងកំណើនខ្លាំងជ្រុលនៃឥណទានក្នុងស្រុក អនុវត្តតាមអត្រាប្តូរប្រាក់ដែលមានតម្លៃខ្ពស់ពេក ឬកើតឡើងដំណាលគ្នានឹងឱនភាពសារពើពន្ធដែលគ្មានការទប់ស្កាត់a។ ក្នុងរយៈពេលជាច្រើនឆ្នាំមុនវិបត្តិកូវីដ-១៩ គណនីចរន្តរបស់កម្ពុជាកាន់តែងាយប្រែប្រួលដោយសារអតុល្យភាពពាណិជ្ជកម្ម ដែលមួយភាគធំជំរុញដោយកំណើននៃការនាំចូលសម្ភារសាងសង់ និងទំនិញប្រើប្រាស់ ជាពិសេសយានយន្ត ប្រេងកាត និងគ្រឿងអេឡិចត្រូនិកដែលជំរុញដោយសន្ទុះនៃសកម្មភាពសាងសង់ និងការប្រើប្រាស់។ ឱនភាពនេះទទួលបានហិរញ្ញប្បទានមួយភាគធំពីលំហូរចូលមូលធន ជាពិសេសការវិនិយោគផ្ទាល់ពីបរទេស និងកំណើនយ៉ាងលឿនរហ័សនៃឥណទានក្នុងស្រុក។ តើគេអាចធានានិរន្តរភាពនៃឱនភាពដ៏ធំនៃគណនីចរន្តរបស់កម្ពុជា បានដែរ ឬទេ? ទេ! ឯកសារពាក់ព័ន្ធពិចារណាថា ឱនភាពដែលបន្តលើស ៥ ភាគរយនៃ ផសស នឹងគ្មាននិរន្តរភាពក្នុងរយៈពេលវែងb។ ឱនភាពក្នុងគណនីចរន្តខាងក្រៅ បណ្តាលមកពីការបង្គរបំណុលសុទ្ធសាធរបស់ជនបរទេសលើពលរដ្ឋខ្មែរ (accumulation of net claims of foreigners on residents)។

**ចាប់តាំងពីការផ្ទុះឡើងនៃវិបត្តិកូវីដ-១៩ ក្នុងឆ្នាំ ២០២០ មាសហាក់ត្រូវបានពាណិជ្ជករប្រើប្រាស់ជាខែលទប់ទល់អតិផរណា ហើយការជួញដូរមាស បានក្លាយជាកត្តាចម្បងមួយដែលរួមចំណែកបង្កើនភាពឆាប់ប្រែប្រួលនៃជញ្ជីងពាណិជ្ជកម្ម និងគណនីចរន្ត ខណៈដែលការនាំចូលសម្ភារសាងសង់ (និងទំនិញប្រើប្រាស់) ថយចុះ ដោយសារភាពនៅទ្រឹងនៃសកម្មភាពអចលនទ្រព្យ និងការសាងសង់ (និងការស្រុតចុះយ៉ាងគំហុកនៃកំណើនឥណទាន)។** ចាប់ពីពេលនោះមក ការជួញដូរមាស មានទំហំធំធេង និងមិនអាចព្យាករណ៍បាន។ យោងតាម Observatory of Economic Complexity ក្នុងឆ្នាំ ២០២២ កម្ពុជាបានក្លាយជាប្រទេសនាំចូលមាសច្រើនជាងគេទី ១២ ក្នុងពិភពលោក និងជួញដូរមាសជាចម្បងជាមួយប្រទេសសិង្ហបុរី ថៃ ស៊ុយអែត តំបន់រដ្ឋបាលពិសេសហុងកុង (ចិន) អូស្ត្រាលី និងជប៉ុន។ ទំហំសរុបនៃការជួញដូរមាស (ការនាំចេញមាស ដក ការនាំចូលមាស) រីកធំយ៉ាងឆាប់រហ័ស គឺកើនពី -៣,៨ ភាគរយនៃ ផសស ក្នុងឆ្នាំ ២០២០ និងកើនខ្ពស់បំផុតដល់ -២១,៥ ភាគរយនៃ ផសស ក្នុងឆ្នាំ ២០២១ មុននឹងថយបន្តិចមកត្រឹម -១៤,៣ ភាគរយនៃ ផសស ក្នុងឆ្នាំ ២០២២ (រូប B.3.2)។ ដូច្នេះ ឱនភាពគណនីចរន្តកើនដល់ ៤០,៤ ភាគរយនៃ ផសស ក្នុងឆ្នាំ ២០២១ និង ២៦,០ ភាគរយនៃ ផសស ក្នុងឆ្នាំ ២០២២។ តាមការរៀបរាប់ក្នុងរូប B.3.1 ខណៈដែលនៅតែមានលំហូរចូលយ៉ាងច្រើននៃការវិនិយោគផ្ទាល់ពីបរទេស ការផ្តល់ហិរញ្ញប្បទានដល់ឱនភាពដ៏ធំនៃគណនីចរន្ត មិនពាក់ព័ន្ធនឹងការថយចុះទុនបម្រុងអន្តរជាតិដុលឡើយ។ នៅអំឡុងឆ្នាំ ២០២០-២០២២ ឱនភាពទាំងនេះកាន់តែរីកធំ មួយផ្នែកដោយសារការស្រុតចុះខ្លាំងនៃចំណូលពីទេសចរណ៍ និងចំនួនប្រាក់បញ្ញើរបស់កម្មករ ដោយសារផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរនៃវិបត្តិកូវីដ-១៩ ដែលបានបង្កឱ្យមានផលវិបាកអវិជ្ជមានលើគណនីសេវាកម្ម និងគណនីប្រាក់ចំណូលបន្ទាប់បន្សំ។

**ការវិនិយោគច្រើនជ្រុលលើវិស័យអចលនទ្រព្យ បានបញ្ចប់ការរីកប៉ោងនៃសកម្មភាពអចលនទ្រព្យ និងការសាងសង់ អមជាមួយនឹងការកែតម្រូវទីផ្សារអចលនទ្រព្យ (property market correction)។** ជាលទ្ធផល វាបានធ្វើឱ្យ ការប្រើប្រាស់ក្នុងវិស័យឯកជនថយចុះគួរឱ្យកត់សម្គាល់។ ក្នុងឆ្នាំ ២០២៣ ទិន្នន័យគយ បង្ហាញថា ការនាំចូលទំនិញថយ ១៨,៥ ភាគរយ ខណៈដែលទិន្នន័យធនាគារកណ្តាលគូសបញ្ជាក់ពីការធ្លាក់ចុះយ៉ាងខ្លាំងនៃកំណើនឥណទានក្នុងស្រុក មកត្រឹម ៤,១ ភាគរយ ថយពី ១៨,៩ ភាគរយក្នុងឆ្នាំ ២០២២។ ហេតុនេះ ជញ្ជីងគណនីចរន្តបានបង្ហាញអតិរេកខ្ពស់មិនធ្លាប់មាន គឺ ១,៧ ភាគរយនៃ ផសស ក្នុងឆ្នាំ ២០២៣។ ក្រៅពីការថមថយការនាំចូលទំនិញ ភាពធន់នៃការនាំចេញទំនិញក៏ជាបច្ច័យល្អផងដែរ។ កិច្ចខិតខំប្រឹងប្រែងជាយុទ្ធសាស្ត្ររបស់កម្ពុជា ដើម្បីធ្វើពិពិធកម្មផលបត្រការនាំចេញរបស់ខ្លួន ក្រៅពីវិស័យបែបប្រពៃណី ដូចជា វាយនភណ្ឌ និងទេសចរណ៍ បានផ្តល់លទ្ធផលសមប្រកប។ កម្ពុជាអាចពង្រីកវិសាលភាពពាណិជ្ជកម្មរបស់ខ្លួន តាមរយៈការបំពាក់បំប៉នឧស្សាហកម្ម ដូចជា គ្រឿងអេឡិចត្រូនិក កង់ និងផលិតផលកសិកម្ម ដោយបានរួមចំណែកដល់ការប៉ះប៉ូវឱនភាពពាណិជ្ជកម្មរបស់កម្ពុជា ដែលរងផលប៉ះពាល់ដោយសារការស្រុតចុះនៃការនាំចេញផលិតផល GTF។ បន្ថែមលើនោះ ជញ្ជីងសេវាកម្មសុទ្ធក៏បានបង្ហាញផងដែរនូវអតិរេក ៤,១ ភាគរយនៃ ផសស ក្នុងឆ្នាំ ២០២៣។ នេះជាភាពប្រសើរឡើងយ៉ាងខ្លាំងពីឱនភាព ១,៥ ២០២២។ ការផ្លាស់ប្តូរជាវិជ្ជមាននេះអាចបណ្តាលមកពីភាព

រីកចម្រើននៃវិស័យទេសចរណ៍ ដែលរំលេចដោយការកើនឡើងយ៉ាងគំហុកនៃចំនួនភ្ញៀវទេសចរណ៍ដែលចូលមកទស្សនាកម្ពុជា ដែលកើនពី ២,៣ លាននាក់ក្នុងឆ្នាំ ២០២២ ដល់ ៥,៤ លាននាក់ក្នុងឆ្នាំ ២០២៣។ ភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ក៏លេចឡើងក្នុងគណនីប្រាក់ចំណូលបឋមផងដែរ ដោយបានងាកចេញពីឱនភាព ៥,៣ ភាគរយនៃ ផសស ក្នុងឆ្នាំ ២០២២ ទៅរកឱនភាពត្រឹម ៣,០ ភាគរយក្នុងឆ្នាំ ២០២៣ ជាចម្បងគឺដោយសារការថយចុះចំណូលដែលត្រូវបានវិនិយោគឡើងវិញ នៅក្នុងវិស័យហិរញ្ញវត្ថុ។ ក្រៅពីនេះ គណនីប្រាក់ចំណូលបន្ទាប់បន្សំ បានបង្ហាញពីអតិរេក ១០,០ ភាគរយនៃ ផសស ក្នុងឆ្នាំ ២០២៣ ដែលជំរុញជាចម្បងដោយលំហូរចូលយ៉ាងច្រើននៃប្រាក់បញ្ញើពីបរទេស។

*ប្រភព ៖* a. Devadas and Loayza 2018. B. Carranza 2022.

**រូប B.៣.១. គណនីចរន្ត**
*(% នៃ ផសស)*




**រូប B.៣.២. ការជួញដូរមាសសរុប**
*(% នៃ ផសស)*




អត្រាទាប ត្រឹម ០ ភាគរយ គឺកើនពី -០,៤ ភាគរយ ដោយសារការថយចុះចំណាយលើការជួសជុលថែទាំលំនៅដ្ឋាន ខណៈដែលការរួមចំណែកនៃសន្ទស្សន៍រងដឹកជញ្ជូន ក៏មានអត្រា ០ ភាគរយផងដែរ គឺកើនពី -០,៥ ភាគរយ។ CPI របស់កម្ពុជា (មិនគិតម្ហូបអាហារ) កើនដល់ ០ ភាគរយធៀបនឹងឆ្នាំមុន ក្នុងខែ មីនា ឆ្នាំ ២០២៤ កើនពី -០,៦ ភាគរយ ក្នុងអំឡុងពេលដូចគ្នា នៅឆ្នាំ ២០២៣។ ទោះបីជាថ្លៃស្រូវអង្ករពិភពលោកកើនបន្តិចក្ដី ប៉ុន្តែថ្លៃស្រូវអង្ករក្នុងស្រុក នៅតែអាចគ្រប់គ្រងបាន ព្រោះកម្ពុជាកំពុងប្រែក្លាយទៅជាប្រទេសនាំចេញសំខាន់មួយនូវទំនិញកសិកម្មផ្សេងទៀតក្រៅពីស្រូវអង្ករ។ ការណ៍នេះ គួបផ្សំនឹងសេដ្ឋកិច្ចដែលប្រើប្រាស់ប្រាក់ដុល្លារក្នុងកម្រិតខ្ពស់ ហាក់គូសបញ្ជាក់ថា អតិផរណាក្នុងរយៈពេលខ្លីដល់រយៈពេលវែងនឹងនៅតែអាចរក្សាបានស្ថិរភាពល្អ។

**ការថមថយអតិផរណាក្នុងចំណោមប្រទេសដៃគូនាំចូលសំខាន់ៗរបស់កម្ពុជា ដូចជា ថៃ វៀណាម និងចិន ដែលមានចំណែករៀងគ្នា -០,៨ ភាគរយ, ៤,០ ភាគរយ និង ០,៧ ភាគរយធៀបនឹងឆ្នាំមុន ក្នុងខែ កុម្ភៈ ឆ្នាំ ២០២៤ បានជួយទប់សម្ពាធថ្លៃក្នុងស្រុក។** ក្នុងចំណោមរដ្ឋសមាជិកអាស៊ានផ្សេងទៀត មានតែប្រទេសឡាវទេ (មិនមែនជាដៃគូនាំចូលសំខាន់របស់កម្ពុជា) ដែលនៅតែមានអត្រាអតិផរណាខ្ពស់រហូតដល់ ២៥,៤ ភាគរយក្នុងខែ កុម្ភៈ ឆ្នាំ ២០២៤។ អត្រាអតិផរណានៅម៉ាឡេស៊ី គឺ ១៨ ភាគរយធៀបនឹងឆ្នាំមុន ហើយនៅសិង្ហបុរីគឺ ៣,៤ ភាគរយធៀបនឹងឆ្នាំមុន នៅខែ កុម្ភៈ ឆ្នាំ ២០២៤។ ក្រៅពីនេះ ធនាគារកណ្ដាល ខិតខំរក្សាស្ថិរភាពអត្រាប្ដូរប្រាក់រៀល-ប្រាក់ដុល្លារអាមេរិក ដែលបានជួយបង្កើនស្ថិរភាពថ្លៃជារួម។

## ២០២៣ជាឆ្នាំដែលមានអតិរេកគណនីចរន្តខ្ពស់មិនធ្លាប់មាន

**ការថយចុះឱនភាពពាណិជ្ជកម្ម បូករួមនឹងការកើនឡើងនៃទំហំការផ្ញើប្រាក់ពីបរទេស និងចំណូលពីទេសចរណ៍ បានជួយឱ្យជញ្ជីងគណនីចរន្តមានភាពប្រសើរឡើង ដែលក្នុងឆ្នាំ ២០២៣ ដោយមានអតិរេកខ្ពស់មិនធ្លាប់មាន រហូតដល់ ១,៧ ភាគរយនៃ ផសស (រូប ១៧)។**[16] ខណៈការនាំចេញផលិតផលសំលៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង (GTF) ថយចុះ ដោយសារតម្រូវការសកលថមថយ ការនាំចេញផលិតផលមិនមែន GTF ដែលរួមបញ្ចូលគ្រឿងបង្គុំអគ្គិសនី និងគ្រឿងបង្គុំយានយន្ត កង់ និងផលិតផលកសិកម្ម មានសន្ទុះកើនឡើង។ ជាលទ្ធផល ការនាំចេញទំនិញកើន ៥ ភាគរយធៀបនឹងឆ្នាំមុន ក្នុងឆ្នាំ ២០២៣ ខណៈដែលការនាំចូលទំនិញថយចុះ គឺថយ ១៨,៥ ភាគរយធៀបនឹងឆ្នាំមុន ដោយសារការប្រើប្រាស់ក្នុង

16 ធនាគារជាតិនៃកម្ពុជា ឆ្នាំ ២០២៤, www.nbc.gov.kh/english/economic_research/monetary_and_financial_statistics_data.php.

វិស័យឯកជនថមថយ បណ្ដាលមកពីការស្រុតចុះនៃកំណើនឥណទានក្នុងស្រុក ជាមួយនឹងភាពជាប់គាំងនៃសកម្មភាពសាងសង់ (សូមមើលផងដែរ ប្រអប់ទី ៣ សម្រាប់ការពិភាក្សាបន្ថែមស្ដីពីគណនីចរន្ត)។ លើសពីនេះ ផលិតផលជំនួសការនាំចូល (import substitution) កំពុងកើនឡើង ដោយក្រុមហ៊ុនម៉ាករថយន្តល្បីៗជាច្រើន ដូចជា Ford, Toyota និង Isuzu កំពុងបង្កើតរោងចក្រផ្គុំតម្លើង និងផលិតយានយន្តនៅកម្ពុជា។

**អតិរេកខ្ពស់បំផុតនៃគណនីចរន្តកាលពីឆ្នាំមុន គូសបញ្ជាក់ពីភាពប្រសើរឡើងគួរឱ្យកត់សម្គាល់នៃសមិទ្ធកម្មវិស័យខាងក្រៅរបស់កម្ពុជា បន្ទាប់ពីឱនភាពគណនីចរន្តធ្លាក់ទាបបំផុតដល់ ៤០,៤ ភាគរយនៃ ផសស ក្នុងឆ្នាំ ២០២១។** ជំរុញដោយចំណូលពីការធ្វើដំណើរកំសាន្ត និងទេសចរណ៍ សេវាកម្មសុទ្ធ (net services) មានភាពប្រសើរឡើង គឺស្មើនឹង ៤,១ ភាគរយនៃ ផសស ក្នុងឆ្នាំ ២០២៣ ខណៈដែលប្រាក់ចំណូលសុទ្ធ (net income) កើនដល់ ៧,០ ភាគរយនៃ ផសស (យោងតាមទិន្នន័យជញ្ជីងទូទាត់ប្រចាំត្រីមាសរបស់ធនាគារកណ្ដាល)។ សេវាកម្មសុទ្ធចាប់ផ្ដើមមានអតិរេកក្នុងឆ្នាំ ២០២៣ ដោយសារការកើនឡើងនៃចំណូលពីការធ្វើដំណើរកំសាន្ត និងទេសចរណ៍ ក្រោយការងើបឡើងវិញនៃចំនួនភ្ញៀវទេសចរអន្តរជាតិ នៅក្រោយវិបត្តិកូវីដ-១៩។ ប្រាក់ចំណូលសុទ្ធ ក៏កើនឡើងដូចគ្នា ដោយសារកំណើនចំណូលពីការវិនិយោគ និងភាពរឹងមាំនៃទំហំការផ្ញើប្រាក់ពីបរទេសរបស់កម្មករ ដែលនៅតែមានចំណែក ៧,៥ ភាគរយនៃ ផសស គឺកើនដល់ ២,៥ ពាន់លានដុល្លារ ក្នុងឆ្នាំ ២០២៣។ ទំហំសុទ្ធនៃការវិនិយោគផ្ទាល់ពីបរទេស កើនដល់ ១២,០ ភាគរយនៃ ផសស (៣,៨ ពាន់លានដុល្លារ) ក្នុងឆ្នាំ ២០២៣ កើនពី ១១,៦ ភាគរយ (៣,៤ ពាន់លានដុល្លារ) ក្នុងឆ្នាំ ២០២២។ ជាលទ្ធផល វាបានធ្វើឲ្យទុនបម្រុងអន្តរជាតិសរុប កើនដល់ ១៩,៩ ពាន់លានដុល្លារ ស្មើនឹងកំណើន ១១,៧ ភាគរយធៀបនឹងឆ្នាំមុន ក្នុងឆ្នាំ ២០២៣។ ទុនបម្រុងអន្តរជាតិសរុបរបស់កម្ពុជា ត្រូវបានប៉ាន់ស្មានថា នឹងមានទំហំស្មើនឹងការនាំចូលប្រហែល ៧ ខែ។ ការណ៍នេះបានជួយសម្រាលសម្ពាធលើអត្រាប្ដូរប្រាក់ ខណៈដែលអតិផរណានៅតែអាចគ្រប់គ្រងបាន ដោយសារថ្លៃម្ហូបអាហារ និងប្រេង ថយចុះ។ ការបន្តហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស និងហិរញ្ញប្បទានសម្បទាន គ្របដណ្ដប់មួយភាគធំលើតម្រូវការហិរញ្ញប្បទានខាងក្រៅ (សូមមើលការពិភាក្សាបន្ថែមស្ដីពីការផ្ដល់បំណុលហិរញ្ញប្បទានសម្បទាន ក្រោមផ្នែកស្ដីពីសារពើពន្ធខាងក្រោម)។

## *ប្រាក់រៀលឡើងថ្លៃធៀបនឹងរូបិយប័ណ្ណក្នុងតំបន់*

**ជញ្ជីងគណនីចរន្តដែលមានភាពប្រសើរឡើង ដែលមូលហេតុចម្បងគឺឱនភាពពាណិជ្ជកម្មរួមតូច បានជួយសម្រាលសម្ពាធលើប្រាក់រៀល។** នៅពេលដែលធនាគារកណ្ដាលសហរដ្ឋអាមេរិក (Fed) បានរក្សាអត្រាមូលនិធិសហព័ន្ធក្នុងចន្លោះ ៥$^{១/៤}$ ដល់ ៥$^{១/២}$ ភាគរយ[17] ដែលជាអត្រាខ្ពស់បំផុតក្នុងរយៈពេល ២៣ ឆ្នាំ សម្រាប់វដ្តនៃការរឹតបន្តឹងរូបិយវត្ថុបច្ចុប្បន្នចាប់តាំងពីខែ កក្កដា ឆ្នាំ ២០២៣ ប្រាក់ដុល្លារអាមេរិកបានឡើងថ្លៃធៀបនឹងរូបិយប័ណ្ណសំខាន់ៗដ៏ទៃទៀត។ ប្រាក់ដុល្លារឡើងថ្លៃធៀបនឹងប្រាក់យ៉េនជប៉ុន ប្រាក់វុនកូរ៉េ ប្រាក់យ័នចិន ប្រាក់ដុល្លារតៃវ៉ាន់ និងប្រាក់ដុល្លារអូស្ត្រាលី។[18] ជាលទ្ធផល ប្រាក់រៀលដែលផ្អែកតាមប្រាក់ដុល្លារអាមេរិក ក៏ឡើងថ្លៃធៀបនឹងរូបិយប័ណ្ណក្នុងតំបន់ផងដែរ ជាពិសេសប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម (រូប ១៨)។ ខណៈដែលប្រទេសថៃ វៀតណាម ចិន និងជប៉ុន គឺជាទីផ្សារនាំចេញសំខាន់ៗរបស់កម្ពុជា នៅក្រៅទីផ្សារសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប អត្រាប្ដូរប្រាក់រៀល-បាត អត្រាប្ដូរប្រាក់រៀល-ដុង អត្រាប្ដូរប្រាក់រៀល-យ័ន និងអត្រាប្ដូរប្រាក់រៀល-យ៉េន កើនឡើងដល់ ១១៣ រៀលក្នុងមួយបាត ០,១៦៥ រៀលក្នុងមួយដុង, ៥៦៥ រៀលក្នុងមួយយ័ន និង ២៦,៩៩ រៀលក្នុងមួយយ៉េន ក្នុងខែ កុម្ភៈ ឆ្នាំ ២០២៤ កើនពី ១១៥ រៀលក្នុងមួយបាត ០,១៧ រៀលក្នុងមួយដុង ៥៨១ រៀលក្នុងមួយយ័ន និង ២៩,៦៩ រៀលក្នុងមួយយ៉េន ក្នុងអំឡុងពេលដូចគ្នា នៅឆ្នាំ ២០២៣។ ដូច្នេះ ការដាក់ឱ្យប្រាក់រៀលពឹងផ្អែកលើប្រាក់ដុល្លារអាមេរិកដ៏រឹងមាំ បានធ្វើឱ្យប៉ះពាល់ដល់ភាពប្រកួតប្រជែងក្នុងការនាំចេញទំនិញ និងសេវាកម្ម (ទេសចរណ៍) របស់កម្ពុជា។

**អត្រាប្ដូរប្រាក់រៀល-ដុល្លារអាមេរិក បានឡើងថ្លៃបន្តិច គឺ ៤.០៦២ រៀលក្នុងមួយដុល្លារ នៅខែ មេសា ឆ្នាំ ២០២៤ ថយពី ៤.១១៥ រៀលក្នុងមួយដុល្លារ ក្នុងអំឡុងពេលដូចគ្នា នៅឆ្នាំ ២០២៣។** ធនាគារជាតិនៃកម្ពុជា បានកំណត់អត្រាប្ដូរប្រាក់សម្រាប់ប្រាក់រៀលត្រឹម ៤.០០០ រៀលក្នុងមួយដុល្លារ។ គោលនយោបាយអត្រាប្ដូរប្រាក់នេះគឺជាឧបករណ៍គន្លឹះមួយ នៅក្នុងគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្ដាល។ គោលនយោបាយនេះ មានគោលបំណងសម្រេចឲ្យបានស្ថិរភាពថ្លៃ។[19] ចាប់តាំងពីធនាគារកណ្ដាលអាមេរិកចាប់ផ្ដើមដំឡើងអត្រាការប្រាក់ដើម្បីទប់អតិផរណាដែលឡើងលឿន (សូមមើលផ្នែកស្ដីពីរូបិយវត្ថុខាងក្រោម សម្រាប់ការពិភាក្សាបន្ថែមស្ដីពីការដំឡើងអត្រាការប្រាក់) អត្រាប្ដូរប្រាក់រៀល-ដុល្លារ រងសម្ពាធកាន់តែខ្លាំង។ ដោយសារតែសេដ្ឋកិច្ចកម្ពុជាប្រើប្រាស់ប្រាក់ដុល្លារក្នុងកម្រិតខ្ពស់ ការដាក់គោលដៅរក្សាស្ថិរភាពអត្រាប្ដូរប្រាក់ បានជួយរក្សាអំណាចទិញ

17 United States Federal Reserve 2024.

18 See https://www.nbc.gov.kh/english/economic_research/monetary_and_financial_statistics_data.php

19 The National Bank of Cambodia’s Exchange Rate Policy; https://www.nbc.gov.kh/english/monetary_policy/exchange_rate_policy.php.

របស់អ្នកដែលរកបានចំណូលជាប្រាក់រៀល ហើយក៏បានទប់ស្កាត់ការប្រើប្រាស់ប្រាក់ដុល្លារទាំងស្រុង។

## *ការផ្គត់ផ្គង់រូបិយវត្ថុកើនឡើងបន្តិច*

**ថ្មីៗនេះ មានការកើនឡើងបន្តិចនៃការផ្គត់ផ្គង់រូបិយវត្ថុ។** ទិន្នន័យដែលទទួលបានបង្ហាញថា កំណើនរូបិយវត្ថុទូទៅងើបឡើង ដោយសារកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស។ ជាសញ្ញានៃភាពប្រសើរឡើងនៃលំហូរចូលមូលធន រូបិយវត្ថុទូទៅបានកើនឡើងជាថ្មី គឺកើន ១៤,៩ ភាគរយក្នុងរយៈពេល ១២ ខែ ត្រឹមដំណាច់ខែ កុម្ភៈ ឆ្នាំ ២០២៤ កើនពី ៦,៨ ភាគរយក្នុងអំឡុងពេលដូចគ្នា នៅឆ្នាំ ២០២៣ ដោយសារកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស (រូប ១៩)។ ដោយសារសេដ្ឋកិច្ចកម្ពុជាប្រើប្រាស់ប្រាក់ដុល្លារក្នុងកម្រិតខ្ពស់ ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសបានរួមចំណែកច្រើនបំផុតដល់កំណើនរូបិយវត្ថុទូទៅ។ ក្នុងកំណើន ១៤,៩ ភាគរយនៃរូបិយវត្ថុទូទៅ ការរួមចំណែកនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស (និងប្រាក់បញ្ញើផ្សេងទៀត) មានចំនួន ១៣,៣ ភាគរយ ប្រាក់បញ្ញើដែលអាចផ្ទេរបានរួមចំណែក ១,២ ភាគរយ និងរូបិយវត្ថុដែលកំពុងចរាចរណ៍រួមចំណែក ០,៤ ភាគរយ ក្នុងខែ កុម្ភៈ ឆ្នាំ ២០២៤ កើនរៀងគ្នាពី ៩,១ ភាគរយ, -២,៣ ភាគរយ និង -០,១ ភាគរយ ក្នុងអំឡុងពេលដូចគ្នា នៅឆ្នាំ ២០២៣។ កំណើនវិជ្ជមាននៃរូបិយវត្ថុដែលកំពុងចរាចរណ៍ឆ្លុះបញ្ចាំងពីការចាក់បញ្ចូលរូបិយវត្ថុក្នុងស្រុកដោយធនាគារកណ្តាលទៅក្នុងទីផ្សារ។ ទោះបីជាសេដ្ឋកិច្ចដែលប្រើប្រាស់ប្រាក់ដុល្លារក្នុងកម្រិតខ្ពស់របស់កម្ពុជា រឹតត្បិតសមត្ថភាពរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការជះឥទ្ធិពលលើរូបិយវត្ថុសរុប (money aggregate) ក៏ដោយ ក៏ការកើនឡើងអនុបាតតម្រូវការទុនបម្រុងនាពេលថ្មីៗនេះ (ដែលជាឧបករណ៍គោលនយោបាយរូបិយវត្ថុមួយ ដែលមានឥទ្ធិពលលើការផ្គត់ផ្គង់សាច់ប្រាក់) អាចគាំទ្រដោយផ្នែកដល់សន្ទនីយភាពទីផ្សារ។ ធនាគារកណ្តាលបានអនុវត្តឡើងវិញនូវការបន្ធូរបន្ថយគោលនយោបាយរូបិយវត្ថុរបស់ខ្លួន តាមរយៈការបន្ទាបអនុបាតតម្រូវការទុនបម្រុង ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច។ ធនាគារកណ្តាលបានបន្ថយអនុបាតតម្រូវការទុនបម្រុង ជារូបិយប័ណ្ណបរទេស ចំនួន ២ ភាគរយ (ដែលជាការបន្ថយច្រើនបំផុតនៅអំឡុងក្រោយវិបត្តិកូវីដ-១៩) មកត្រឹម ៧ ភាគរយ ក្នុងខែ ធ្នូ ឆ្នាំ ២០២៣។[20]

## *អត្រាការប្រាក់ក្នុងស្រុកនៅតែខ្ពស់*

**ការដំឡើងអត្រាការប្រាក់នៅសហរដ្ឋអាមេរិកជាសម្ពាធរុញអត្រាការប្រាក់ក្នុងស្រុកកើនឡើងបន្ត។** កម្ពុជា “យកលំនាំតាម” គោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិក ព្រោះសេដ្ឋកិច្ចកម្ពុជាប្រើប្រាស់ប្រាក់ដុល្លារក្នុងកម្រិតខ្ពស់។ ចាប់តាំងពីដើមវដ្តនៃការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ ដែលចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ ២០២២ (វិធានការរបស់ធនាគារកណ្តាលសហរដ្ឋអាមេរិកដើម្បីទប់អតិផរណា) បានដាក់សម្ពាធលើអត្រាការប្រាក់ក្នុងស្រុកដែលនៅតែខ្ពស់ដដែល (រូប ២០)។ មានការកើនឡើងការចំណាយលើមូលនិធិសម្រាប់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដោយសារគ្រឹះស្ថានទាំងនេះត្រូវដំឡើងអត្រាការប្រាក់លើប្រាក់បញ្ញើដើម្បីទាក់ទាញអ្នកដាក់ប្រាក់បញ្ញើ។

**ការណ៍នេះបានធ្វើឱ្យមានការកើនឡើងចំណាយប្រតិបត្តិការ ដែលបង្រួមគម្លាតប្រាក់ចំណេញ។** អត្រាការប្រាក់ខ្ពស់បានកាត់បន្ថយផលចំណេញធៀបនឹងទ្រព្យសកម្មរបស់វិស័យធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFI) ដែលថយចុះពាក់កណ្តាលមកត្រឹម ០,៧ ភាគរយ និង ១,៥ ភាគរយរៀងគ្នាក្នុងឆ្នាំ ២០២៣

**រូប ១៩. កំណើនរូបិយវត្ថុទូទៅ ងើបឡើងវិញការរួមចំណែកដល់កំណើនរូបិយវត្ថុទូទៅ**

*(ភាគរយ)*




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

**រូប ២០. អត្រាការប្រាក់នៅតែខ្ពស់អត្រាការប្រាក់ក្នុងស្រុក**

*(ភាគរយក្នុងមួយឆ្នាំ)*




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

20 ធនាគារជាតិនៃកម្ពុជា ឆ្នាំ ២០២៣

ថយពី ១,៤ ភាគរយ និង ៣,០ ភាគរយរៀងគ្នាក្នុងឆ្នាំ ២០២២។ ស្រដៀងគ្នានេះ ផលចំណេញធៀបនឹងទ្រព្យម្ចាស់ (equity) របស់វិស័យធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុថយមកត្រឹម ៣,៨ ភាគរយ និង ៦,០ ភាគរយរៀងគ្នា ក្នុងឆ្នាំ ២០២៣ ថយពី ៧,០ ភាគរយ និង ១៣,៦ ភាគរយរៀងគ្នា ក្នុងឆ្នាំ ២០២២។ ទន្ទឹមនឹងនេះ អនុបាតកម្ចីមិនដំណើរការ កើនដល់ ៥,៤ ភាគរយ (កើនពី ២,២ ភាគរយ) សម្រាប់ធនាគារ និងកើនដល់ ៦,៧ ភាគរយ (កើនពី ២,៦ ភាគរយ) សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មួយផ្នែកឆ្លុះបញ្ចាំងពីការបញ្ចប់វិធានការទ្រាំទ្រ (forbearance measures) ដែលបានដាក់ចេញក្នុងអំឡុង វិបត្តិកូវីដ-១៩ និងការថយចុះកំណើនឥណទានក្នុងស្រុក។ ក្នុង ខែ មករា ឆ្នាំ ២០២៤ អត្រាការប្រាក់មធ្យមក្នុងមួយឆ្នាំសម្រាប់ប្រាក់បញ្ញើមានកាលកំណត់ជាប្រាក់ដុល្លារអាមេរិក កើនដល់ ៥,៨៣ ភាគរយ កើនពី ៤,១ ភាគរយ នៅខែ មិថុនា ឆ្នាំ ២០២២។ ស្រដៀងគ្នានេះ អត្រាការប្រាក់មធ្យមក្នុងមួយឆ្នាំសម្រាប់កម្ចីមានកាលកំណត់ជាប្រាក់ដុល្លារអាមេរិក បានកើនដល់ ១០,៣៤ ភាគរយ កើនពី ៨,៤ ភាគរយ សម្រាប់អំឡុងពេលដូចគ្នានេះ។ អត្រាការប្រាក់ខ្ពស់កាត់បន្ថយកម្រិតជារួមនៃតម្រូវការក្នុងស្រុក ក៏ដូចជាជំរុញការដាក់ប្រាក់សន្សំក្នុងស្រុក ព្រោះអតិថិជនអាចទទួលបានការប្រាក់ខ្ពស់ពីប្រាក់សន្សំរបស់ពួកគេ។ ផលជះអវិជ្ជមានលើសកម្មភាពសេដ្ឋកិច្ចដោយសាររដ្ឋរឹតបន្តឹងនៃគោលនយោបាយរូបិយវត្ថុបច្ចុប្បន្នបានចាប់ផ្តើមស្តែងឡើង។ ដូចការពិភាក្សាខាងលើ តម្រូវការទំនិញប្រើប្រាស់ដែលជាប់ធន់បន្តថយចុះ ហើយកំណើនឥណទានក្នុងស្រុក ថមថយជាខ្លាំង ដែលបញ្ជាក់ថា ការវិនិយោគ និងចំណាយរបស់អ្នកប្រើប្រាស់កំពុងរងផលអាក្រក់ពីរដ្ឋរឹតបន្តឹងនៃគោលនយោបាយរូបិយវត្ថុបច្ចុប្បន្ន (សូមមើលផ្នែកស្តីពីឥណទានក្នុងស្រុកខាងក្រោម)។

## ឥណទានស្រុតចុះយ៉ាងគំហុក ដោយសារភាពជាប់គាំងនៃសកម្មភាពអភិវឌ្ឍន៍លំនៅដ្ឋាន

**កំណើនឥណទានក្នុងស្រុក មានការស្រុតចុះជាខ្លាំង ចាប់តាំងពីពាក់កណ្តាលឆ្នាំ ២០២៣ មក។** ខណៈដែលការរឹតបន្តឹងលក្ខខណ្ឌឥណទាន ដែលបណ្តាលមកពីការដំឡើងអត្រាការប្រាក់ ការថមថយតម្រូវការឥណទានក៏អាចជាកត្តារួមចំណែកមួយភាគធំដល់ការស្រុតចុះនេះ។ ទីមួយ តម្រូវការឥណទានក្នុងស្រុក ដោយវិស័យអចលនទ្រព្យ និងសាងសង់ ស្រុតចុះយ៉ាងខ្លាំង។ ដោយសារការវិនិយោគច្រើនជ្រុលលើទីផ្សារអចលនទ្រព្យការកែតម្រូវទីផ្សារលំនៅឋាននៅតែបន្ត ដែលនាំឱ្យមានការថយចុះតម្រូវការឥណទានធនាគារ។ ទីពីរ អត្រាការប្រាក់កាន់តែខ្ពស់ ការថមថយទំនុកចិត្តអ្នកប្រើប្រាស់ និងការថយចុះប្រាក់ចំណូលពិត (ក្រោយការកាត់ពន្ធ) (real disposal income) ដែលបណ្តាលមកពីផលប៉ះពាល់យូរអង្វែងនៃវិបត្តិកូវីដ-១៩[21] ក៏បានរួមចំណែកធ្វើឱ្យតម្រូវការឥណទានរបស់គ្រួសារ និងក្រុមហ៊ុនថយចុះផងដែរ។ ជាលទ្ធផល ឥណទានបានធ្លាក់ចុះយ៉ាងគំហុកមកត្រឹម ៤,៦ ភាគរយ ធៀបនឹងឆ្នាំមុន ដែលជាការធ្លាក់ចុះទាបបំផុតក្នុងរយៈពេល ១៤ ឆ្នាំ ក្នុងខែ កុម្ភៈ ឆ្នាំ ២០២៤ ថយពី ១៤,៨ ភាគរយ ក្នុងអំឡុងពេលដូចគ្នានៅឆ្នាំ ២០២៣ (រូប ២១)។ អត្រាកំណើនឥណទានគឺទាបបំផុត ចាប់តាំងពីចុងឆ្នាំ ២០០៩ នៅពេលសេដ្ឋកិច្ចកម្ពុជារងផលប៉ះពាល់ដោយសារវិបត្តិហិរញ្ញវត្ថុសកល។

## ឥណទានកំពុងងាកចេញពីវិស័យអចលនទ្រព្យ ឆ្ពោះទៅកាន់វិស័យពាណិជ្ជកម្ម និងកសិកម្ម

**ទោះបីជាមានការស្រុតចុះជារួមនៃកំណើនឥណទានក្តី ប៉ុន្តែចំណែកនៃឥណទានក្នុងស្រុកដែលផ្តល់ហិរញ្ញប្បទានដល់វិស័យលក់រាយ វិស័យលក់ដុំ និងវិស័យកសិកម្មបញ្ចូលគ្នាបានកើនឡើង គឺកើនដល់ ៣៥,៥ ភាគរយនៃឥណទានមិនទាន់សងសរុប (៥២ ពាន់លានដុល្លារ) ក្នុងខែ កុម្ភៈ ឆ្នាំ ២០២៤ កើនពី ៣៤,៧ ភាគរយក្នុងអំឡុងពេលដូចគ្នានៃឆ្នាំ ២០២៣ (រូប ២២)។** ជាលទ្ធផល ចាប់តាំងពីខែ កញ្ញា ឆ្នាំ ២០២៣ មក ចំណែកនៃឥណទានក្នុងស្រុកដែលផ្តល់ហិរញ្ញប្បទានដល់វិស័យលក់រាយ វិស័យលក់ដុំ និងវិស័យកសិកម្មបញ្ចូលគ្នា កើនលើសចំណែកនៃឥណទានក្នុងស្រុកដែលផ្តល់ហិរញ្ញប្បទានដល់វិស័យសាងសង់ វិស័យអចលនទ្រព្យ និងវិស័យបញ្ចាំ។ ការណ៍នេះគូសបញ្ជាក់ពីការបង្វែរបន្តិចម្តងៗនៃការផ្តល់ឥណទានក្នុងស្រុកចេញពីវិស័យអចលនទ្រព្យ ទៅវិស័យផលិតកម្មសំខាន់ៗរបស់សេដ្ឋកិច្ចកម្ពុជា (សេវាកម្ម និងកសិកម្ម)។ ចំណែកនៃឥណទានក្នុងស្រុកដែលផ្តល់ហិរញ្ញប្បទានដល់វិស័យសាងសង់ វិស័យអចលនទ្រព្យ និងវិស័យបញ្ចាំ ថយមកត្រឹម ៣៣,៣ ភាគរយនៃឥណទានក្នុងស្រុកសរុប ក្នុងខែ កុម្ភៈ ឆ្នាំ ២០២៤ ថយពី ៣៤,៦ ភាគរយក្នុងអំឡុងពេលដូចគ្នា នៅឆ្នាំ ២០២៣ ដែលបណ្តាលមកពីការថមថយតម្រូវការឥណទាន ដែលបង្កឡើងដោយការវិនិយោគច្រើនជ្រុលលើទីផ្សារអចលនទ្រព្យ។

**ការថមថយនៃកំណើនឥណទានក្នុងស្រុក បាននាំឱ្យ អនុបាតឥណទាន-ផសសរួមតូច ដែលថយមកត្រឹម ១៦៦,២ ភាគរយ ក្នុងខែ កុម្ភៈ ឆ្នាំ ២០២៤ ថយពី ១៧១,៨ ភាគរយក្នុងអំឡុងពេលដូចគ្នានៅឆ្នាំ ២០២៣។** ទោះជាយ៉ាងណា កំណើនប្រាក់បញ្ញើក្នុងវិស័យឯកជន ស្ទុះឡើងដល់ ១៥,៧ ភាគរយធៀបនឹងឆ្នាំមុន ក្នុងខែ កុម្ភៈ ឆ្នាំ ២០២៣។ ការណ៍នេះទំនងជាបញ្ជាក់ពីទំនុកចិត្តជាងមុនលើវិស័យហិរញ្ញវត្ថុ ទាក់ទាញដោយការដំឡើងអត្រាការប្រាក់លើប្រាក់បញ្ញើ ក៏ដូចជាសមត្ថភាពសន្សំប្រាក់របស់គ្រួសារ និងអាជីវកម្ម។ ការថមថយកំណើនឥណទាន និងការកើនឡើងនៃកំណើនប្រាក់បញ្ញើបានជួយកាត់បន្ថយអនុបាត

21 ធនាគារពិភពលោក ឆ្នាំ ២០២០

កម្ចី-ប្រាក់បញ្ញើ ដែលមានអត្រា ១២៧,៩ ភាគរយ ក្នុងខែ កុម្ភៈ ឆ្នាំ ២០២៤ ថយពី ១៤១,៥ភាគរយក្នុងអំឡុងពេលដូចគ្នានៅឆ្នាំ ២០២៣។

## *ការប្រមូលចំណូលក្នុងស្រុកនៅតែថមថយ*

**ទិន្នន័យដែលទទួលបានបង្ហាញថា ក្នុងខែ មករា ឆ្នាំ ២០២៤ ការប្រមូលចំណូលក្នុងស្រុកកើនតិចតួច គឺកើន ០,២ ភាគរយ ធៀបនឹងឆ្នាំមុន ថយពី ១១,៣ ភាគរយក្នុងអំឡុងពេលដូចគ្នាកាលពីឆ្នាំ ២០២៣។** ក្រោយការងើបឡើងវិញយ៉ាងលឿនរហ័សក្នុងឆ្នាំ ២០២២ ដែលមួយផ្នែកឆ្លុះបញ្ចាំងពីការស្ទុះឡើងការប្រើប្រាស់ក្នុងរយៈពេលខ្លី ក្រោយការលុបចោលការបំរាមពាក់ព័ន្ធនឹងវិបត្តិកូវីដ-១៩ ក្នុងការចល័តរបស់ប្រជាជនដែលកំណើននៃការប្រមូលចំណូលរបស់រដ្ឋាភិបាលបានថមថយ។ កម្ពុជានៅតែពឹងផ្អែកលើពន្ធលើទំនិញ និងសេវាកម្ម (ចំណូលប្រយោល) (រូប ២៣)។ ចំណូលផ្ទាល់របស់កម្ពុជា ដែលរួមបញ្ចូលមួយភាគធំ ពន្ធលើប្រាក់ចំណេញ និងប្រាក់ចំណូល នៅតែមានទំហំតូច ដោយមានចំណែកត្រឹមតែ ១ ភាគ ៣ នៃចំណូលពន្ធសរុប ព្រោះកម្ពុជាមិនទាន់បានដាក់ចេញពន្ធលើប្រាក់ចំណូលបុគ្គល។

**ចាប់តាំងពីឆ្នាំ ២០២៣ មក ចំណូលប្រយោលរបស់កម្ពុជាដែលរួមមានពន្ធលើការប្រើប្រាស់ ដូចជា អាករលើតម្លៃបន្ថែម និងពន្ធអាករ រងផលប៉ះពាល់ដោយសារការថមថយការប្រើប្រាស់ក្នុងវិស័យឯកជន ដោយសារការស្រុតចុះយ៉ាងខ្លាំងនៃកំណើនឥណទានក្នុងស្រុក។** ក្រៅពីនេះ ពន្ធលើពាណិជ្ជកម្មអន្តរជាតិដែលរួមបញ្ចូលភាគច្រើននៃចំណូលពីពន្ធនាំចូល ក៏កំពុងរងផលប៉ះពាល់ដោយសារការថមថយការនាំចូល និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលទើបត្រូវបានចុះហត្ថលេខា។ ជាលទ្ធផលពន្ធលើទំនិញ និងសេវាកម្ម បានថយមកត្រឹម ៨,៨ ភាគរយនៃផសស ហើយពន្ធលើពាណិជ្ជកម្មអន្តរជាតិបានថយមកត្រឹម ២,០ ភាគរយនៃផសស ក្នុងឆ្នាំ ២០២៣ ថយពី ១០,៥ ភាគរយ និង ២,១ ភាគរយរៀងគ្នា ក្នុងឆ្នាំ ២០២២។ ខណៈដែលការស្តារឡើងវិញទ្រទ្រង់ដោយការងើបឡើងនៃវិស័យទេសចរណ៍ ចំណូលមិនមែនពន្ធ មានចំណែក ១,៩ ភាគរយនៃផសស ក្នុងឆ្នាំ ២០២៣ ដែលជាកម្រិតទាបខ្លាំងជាងកម្រិត ៣,០ ភាគរយកាលពីមុនវិបត្តិកូវីដ-១៩។

**ក្រៅពីនេះ ពន្ធលើចំណូលសាជីវកម្ម ត្រូវជួបឧបសគ្គកាន់តែខ្លាំងដោយការអនុគ្រោះពន្ធ ក្រោមច្បាប់ស្តីពីវិនិយោគ។** ទោះជាយ៉ាងណា ដោយសារកិច្ចខិតខំប្រឹងប្រែងពង្រឹងរដ្ឋបាលចំណូលពន្ធ កម្ពុជានៅតែសម្រេចបានផលបន្តិចម្តងៗក្នុងការបង្កើនការប្រមូលចំណូលផ្ទាល់។ យុទ្ធសាស្ត្រកៀរគរចំណូលថ្មី ២០២៤-២៨ នឹងត្រូវដាក់ចេញក្នុងឆ្នាំនេះ។

## *ចំណាយថវិកាកើនក្នុងកម្រិតសមរម្យ*

**ក្នុងឆ្នាំ ២០២៣ ដោយសារកិច្ចខិតខំប្រឹងប្រែងត្បិតត្បៀតថវិកា (budget consolidation) ចំណាយរបស់រដ្ឋាភិបាលនៅមានកម្រិត ដោយការប៉ាន់ស្មាន ចំណាយមូលធនមានការថមថយ ទោះបីជាចំណាយចរន្តមានការកើនឡើង ដែលបណ្តាលមកពីការដាក់ចេញជាថ្មីនូវវិធានការដំឡើងប្រាក់ឈ្នួលក្នុងវិស័យ សាធារណៈជារួមក៏ដោយ (ត្រូវបានផ្អាកនៅអំឡុងឆ្នាំ ២០២១-២២ ដើម្បីសន្សំសំចៃធនធានថវិកាសម្រាប់ផ្តល់ហិរញ្ញប្បទានដល់ចំណាយដែលពាក់ព័ន្ធនឹងវិបត្តិកូវីដ-១៩) ការដាក់ចេញនូវអត្ថប្រយោជន៍សន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ការរៀបចំព្រឹត្តិការណ៍ស៊ីហ្គេមលើកទី ៣២ និងការចំណាយដែលពាក់ព័ន្ធនឹងការបោះ**

**រូប ២១. កំណើនឥណទានក្នុងស្រុក ថយចុះ**
*(ប្រែប្រួលភាគរយធៀបនឹងឆ្នាំមុន)*




*ប្រភព ៖* អាជ្ញាធរកម្ពុជា
*ចំណាំ ៖* CRM=សំណង់ អចលនទ្រព្យ និងកម្ចីទិញផ្ទះ

**រូប ២២. វិភាជឥណទានក្នុងស្រុកងាកទៅផ្តល់ហិរញ្ញប្បទានដល់វិស័យពាណិជ្ជកម្ម និងកសិកម្ម**
*(ភាគរយនៃសរុប)*




*ប្រភព ៖* ច្បាប់ទូទាត់ថវិកា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក
*ចំណាំ ៖* CRM=សំណង់ អចលនទ្រព្យ និងកម្ចីទិញផ្ទះ, RWA=លក់រាយ លក់ដុំ និងកសិកម្ម

**ឆ្នោត។** ដោយសារការថយចុះការវិនិយោគមូលធនសាធារណៈ ដែលផ្តល់ហិរញ្ញប្បទានពីក្នុងស្រុក ចំណាយមូលធនត្រូវបាន ប៉ាន់ស្មានថានឹងថយមកត្រឹម ៧,៤ ភាគរយនៃផសស ក្នុងឆ្នាំ ២០២៣ ថយពី ៨,៧ ភាគរយក្នុងឆ្នាំ ២០២២ (រូប ២៤) ដោយសារការដកចេញវិធានការជំរុញការវិនិយោគសាធារណៈ (countercyclical public investment boost) ដើម្បី កាត់បន្ថយផលជះអវិជ្ជមាននៃវិបត្តិកូវីដ-១៩។ ទោះជាយ៉ាងណា ចំណាយសាធារណៈលើប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ និងលើទំនិញ និងសេវាកម្ម ត្រូវបានប៉ាន់ស្មានថាកើនឡើង បន្តិច គឺកើនរៀងគ្នាដល់ ៦,៨ ភាគរយនៃផសស និង ៨,១ ភាគរយនៃផសស ក្នុងឆ្នាំ ២០២៣ កើនពី ៦,៧ ភាគរយ និង ៨,០ ភាគរយរៀងគ្នា ក្នុងឆ្នាំ ២០២២។ ចំណាយផ្សេងទៀត ដែលគ្របដណ្តប់លើចំណាយថវិកាថ្នាក់ក្រោមជាតិ ក៏កើនឡើង តិចតួចផងដែរ និងត្រូវបានប៉ាន់ស្មានថា កើនដល់ ៤,០ ភាគរយ នៃផសស ក្នុងឆ្នាំ ២០២៣ ដោយកើនពី ៣,៨ ភាគរយក្នុងឆ្នាំ ២០២២។ ទោះជាយ៉ាងណា សម្ពាធការចំណាយរបស់រដ្ឋាភិបាល នៅតែបន្ត។ ក្នុងខែ មករា ឆ្នាំ ២០២៤ ចំណាយរបស់រដ្ឋាភិបាល ស្ទុះឡើងយ៉ាងឆាប់រហ័ស គឺកើន ៦២,៦ ភាគរយធៀបនឹងឆ្នាំមុន កើនពី -១៣,០ ភាគរយ ក្នុងអំឡុងពេលដូចគ្នានៃឆ្នាំ ២០២៣ ដែលនេះឆ្លុះបញ្ចាំងពីភាពងាយប្រែប្រួលនៃចំណាយថវិកា។ កម្ពុជាបន្តអនុវត្តការដំឡើងប្រាក់ឈ្នួលក្នុងវិស័យសាធារណៈ និងកម្មវិធីជំនួយសង្គម។ កម្ពុជាក៏កំពុងជំរុញការអប់រំបណ្តុះ បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) និងការថែទាំសុខភាព ផងដែរ។ យុទ្ធសាស្ត្របញ្ចកោណ ឆ្នាំ ២០២៣-២០២៨ មានគោលបំណងបណ្តុះបណ្តាលសិក្ខាកាម TVET ឱ្យបាន ១,៥ លាននាក់ ផ្តោតគោលដៅលើភាពគ្របដណ្តប់សុខភាព ជាសកល និងបង្កើនសកម្មភាពប្រឹក្សាអប់រំក្នុងវិស័យកសិកម្ម ជាដើម។

## ឱនភាពសារពើពន្ធជារួមរីកធំ

**ផ្អែកមួយភាគធំលើការថយចុះចំណូលក្នុងស្រុក ឱនភាព សារពើពន្ធត្រូវបានប៉ាន់ស្មានថានឹងរីកធំ។** ក្នុងឆ្នាំ ២០២៣ គម្លាត រវាងចំណូលសរុប (រួមទាំងជំនួយឥតសំណង) និងចំណាយ ក្រោមប្រតិបត្តិការទូទៅរបស់រដ្ឋាភិបាល ត្រូវបានប៉ាន់ស្មានថា កើនដល់ ៥,៣ ភាគរយនៃផសស ធៀបនឹង ៤,៤ ភាគរយក្នុង ឆ្នាំ ២០២២ (រូប ២៥)។ ចំណូល (រួមទាំងជំនួយឥតសំណង) ត្រូវបានប៉ាន់ស្មានថាស្មើនឹង ២១,៤ ភាគរយនៃផសស ថយពី ២៣,៤ ភាគរយនៃផសស សម្រាប់ចំណូលដែលបានប្រមូល ក្នុងឆ្នាំ ២០២២ ខណៈដែលចំណាយថយចុះបន្តិចមកត្រឹម ២៦,៧ ភាគរយនៃផសស ថយពី ២៧,៧ ភាគរយនៃផសស ក្នុងអំឡុងពេលដូចគ្នា ដោយសារកិច្ចខិតខំប្រឹងប្រែងរឹតត្បិត ថវិកា (budget consolidation)។

**មូលនិធិខាងក្រៅនៅតែដើរតួនាទីសំខាន់ក្នុងការផ្តល់ ហិរញ្ញប្បទានដល់ឱនភាពសារពើពន្ធ។** ចាប់តាំងពីការផ្ទុះឡើង នៃវិបត្តិកូវីដ-១៩ ក្នុងឆ្នាំ ២០២០ អាជ្ញាធរកម្ពុជាបានខិតខំលុប បំបាត់គម្លាតហិរញ្ញប្បទានដែលរីកធំដោយការវិបត្តិកូវីដ-១៩ ជាចម្បងគឺតាមរយៈការបង្កើនប្រាក់ចំណូលពីការផ្តល់កម្ចី (loan disbursement) បំពេញបន្ថែមដោយការដកប្រាក់បញ្ញើរបស់ រដ្ឋាភិបាល (ទុនបម្រុងសារពើពន្ធ) (សម្រាប់ខ្លឹមសារលម្អិត សូមមើលផ្នែកស្តីពីបំណុលសាធារណៈ)។ ហិរញ្ញប្បទានខាងក្រៅ ដែលរួមបញ្ចូលការគាំទ្រគម្រោង និងថវិកា ត្រូវបានប៉ាន់ស្មាន ថានឹងរួមចំណែក ៣ ភាគ ៤ (រូប ២៦) ដើម្បីផ្តល់ហិរញ្ញប្បទាន ដល់ឱនភាពសារពើពន្ធជារួមដែលត្រូវបានប៉ាន់ស្មានថាស្មើនឹង ៥,៣ ភាគរយនៃផសស ខណៈដែល ១ ភាគ ៤ ទៀតត្រូវបាន ប៉ាន់ស្មានថាទទួលបានហិរញ្ញប្បទានពីការដកប្រាក់បញ្ញើរបស់ រដ្ឋាភិបាល (ទុនបម្រុងសារពើពន្ធ) ដែលមានចំនួនស្មើនឹង ១៥,៤ ភាគរយនៃផសស (២០,១ ទ្រីលានរៀល) គិតត្រឹមខែ កុម្ភៈ

**រូប ២៣. ចំណូលក្នុងស្រុក ថយចុះចំណូលក្នុងស្រុកទូទៅ របស់រដ្ឋាភិបាល**

*(ភាគរយនៃ ផសស)*




*ប្រភព ៖ ច្បាប់ទូទាត់ថវិកា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក*

*ចំណាំ ៖ e=ការប៉ាន់ស្មាន*

**រូប ២៤. ចំណាយនៅតែរឹតត្បិតចំណាយទូទៅ របស់រដ្ឋាភិបាល**

*(ភាគរយនៃ ផសស)*




*ប្រភព ៖ ច្បាប់ទូទាត់ថវិកា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក*

*ចំណាំ ៖ e=ការប៉ាន់ស្មាន*

ឆ្នាំ ២០២៤ ថយពី ១៦,៣ ភាគរយនៃ ផសស ក្នុងអំឡុងពេលដូចគ្នានៅឆ្នាំ ២០២៣។

## ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់នៅបន្ត

**កម្មវិធីឧបត្ថម្ភសាច់ប្រាក់ក្នុងអំឡុងវិបត្តិកូវីដ-១៩ ដែលជាសមាសភាគធំជាងគេនៃអន្តរាគមន៍សារពើពន្ធរបស់រដ្ឋាភិបាល កាលពីអំឡុងវិបត្តិកូវីដ-១៩ បានបញ្ចប់នៅខែ មីនា ឆ្នាំ ២០២៤ ដោយចំណាយសរុបមានចំនួន ១.៣២៤ ពាន់លានដុល្លារ ក្រោយដាក់ឲ្យអនុវត្តក្នុងខែ មិថុនា ឆ្នាំ ២០២០។** ដើម្បីបន្តផ្តល់ជំនួយសង្គមដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តកម្មវិធីកញ្ចប់គ្រួសារ (FP) ដែលជាកម្មវិធីអចិន្ត្រៃយ៍មួយ កាលពីខែ ធ្នូ ឆ្នាំ ២០២៣។ កម្មវិធីកញ្ចប់គ្រួសារច្របាច់បញ្ចូលកម្មវិធីទាំង ៤ ដែលមានស្រាប់ គឺ ១) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ ឆ្នាំ ២) កម្មវិធីអាហារូបករណ៍សម្រាប់សិស្សបឋមសិក្សា និងមធ្យមសិក្សា ៣) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព និង ៤) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនចាស់ជរាអាយុចាប់ពី ៦០ ឆ្នាំឡើង (តារាង ១)។

**កម្មវិធីកញ្ចប់គ្រួសារដែលត្រូវបានអនុវត្តជាផ្លូវការក្នុងខែ មេសា ឆ្នាំ ២០២៤ បង្ហាញពីរបត់គោលនយោបាយដ៏សំខាន់មួយឆ្ពោះទៅរកការបង្កើន និងការធ្វើឱ្យប្រសើរឡើងនៃភាពគ្របដណ្តប់នៃកម្មវិធីជំនួយសង្គមសម្រាប់គ្រួសារក្រីក្រ និងងាយរងគ្រោះជាអចិន្ត្រៃយ៍។** កម្មវិធីនេះមានគោលបំណងបង្កើនភាពគ្រប់គ្រាន់នៃជំនួយសង្គម តាមរយៈការផ្តល់ការឧបត្ថម្ភសាច់ប្រាក់ដោយគ្មានលក្ខខណ្ឌក្រោមអត្រាថេរ រួមជាមួយនឹងការឧបត្ថម្ភសាច់ប្រាក់ក្រោមលក្ខខណ្ឌ ដែលកែសម្រួលទៅតាមសមាជិកគ្រួសារម្នាក់ៗដែលមានលក្ខណៈសម្បត្តិ (ស្ត្រីមានផ្ទៃពោះ កុមារអាយុក្រោម ២ ឆ្នាំ កុមារគ្រប់អាយុចូលរៀន ជនមានពិការភាព និងចាស់ជរាអាយុ ៦០ ឆ្នាំឡើង)។ កម្មវិធីកញ្ចប់គ្រួសារ ត្រូវបានរំពឹងថានឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណ ៦៥៤.០០០ គ្រួសារ (ស្មើនឹង ២,៨ លាននាក់ ឬប្រមាណ ១៨ ភាគរយនៃចំនួនប្រជាជនសរុប) ដែលត្រូវបានកំណត់អត្តសញ្ញាណក្រោមកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (IDPoor)។ ក្នុងន័យនេះ កញ្ចប់ថវិកាចំនួន ៤៣៤.៦០០ លានរៀល (១០០ លានដុល្លារ) ត្រូវបានរៀបចំឡើងសម្រាប់កម្មវិធីកញ្ចប់គ្រួសារសម្រាប់ឆ្នាំ ២០២៤ និង ៧០១.៣២០ លានរៀល (១៧០ លានដុល្លារ) សម្រាប់ឆ្នាំ ២០២៥។

**អត្រាភាពក្រីក្រក្រោមបន្ទាត់ភាពក្រីក្រជាតិ គឺ ១៧,៨ ភាគរយក្នុងឆ្នាំ ២០១៩/២០ ប៉ុន្តែត្រូវបានប៉ាន់ស្មានថា អត្រាភាពក្រីក្រដែលកើនឡើងក្នុងឆ្នាំ ២០២១ គឺដោយសារផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ លើសេដ្ឋកិច្ច និងការបិទខ្ទប់ដែលពាក់ព័ន្ធ។** ទោះជាយ៉ាងណា តាមរយៈការព្យាករណ៍ការងើបឡើងវិញនៃសេដ្ឋកិច្ច និងការថមថយអតិផរណា អត្រាភាពក្រីក្រត្រូវបានប៉ាន់ស្មានថា បានថយចុះក្នុងឆ្នាំ ២០២៣។

## ទំហំបំណុលសាធារណៈកើនដល់ ៣៩,៥ ភាគរយនៃផសស

**គិតត្រឹមចុងឆ្នាំ ២០២៣ អនុបាតបំណុលសាធារណៈ-ផសសរបស់កម្ពុជា កើនដល់ ៣៩,៥ ភាគរយ ឬស្មើនឹងបំណុលមិនទាន់សង ១១,២ ពាន់លានដុល្លារ ក្នុងនោះ ៩៩,៥ ភាគរយ ឬស្មើនឹង ១១,១៩ ពាន់លានដុល្លារ ជាបំណុលសាធារណៈក្រៅប្រទេស ខណៈដែលបំណុលសាធារណៈក្នុងប្រទេសមានចំនួន ០,៥ ភាគរយ ឬ ៥២,៣៩ លានដុល្លារ។**[22] ក្នុងបំណុលសាធារណៈក្រៅប្រទេសចំនួន ១១,១៩ ពាន់លានដុល្លារ ៦៤,០ ភាគរយជាបំណុលដែលជំពាក់ឥណទាយកទ្វេភាគី និង ៣៦,០ ភាគរយជាបំណុលជំពាក់ឥណទាយកពហុភាគី ធៀបនឹង ៦៧,៥

**រូប ២៥. ប្រតិបត្តិការទូទៅរបស់រដ្ឋាភិបាល**
*(ភាគរយនៃ ផសស)*




*ប្រភព ៖* ច្បាប់ទូទាត់ថវិកា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក
*ចំណាំ ៖* e=ការប៉ាន់ស្មាន

**រូប ២៦. អតិរេក/ឱនភាពទូទៅរបស់រដ្ឋាភិបាល និងហិរញ្ញប្បទាន**
*(ភាគរយនៃ ផសស)*




*ប្រភព ៖* ច្បាប់ទូទាត់ថវិកា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក
*ចំណាំ ៖* p=ការព្យាករ

22 ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០២៤a

ភាគរយ និង ៣២,៤ ភាគរយរៀងគ្នាក្នុងឆ្នាំ ២០២២។ ដោយសារវិបត្តិកូវីដ-១៩ ការបង្គរបំណុលរបស់កម្ពុជាកើនចំពេលមានការថយចុះការប្រមូលចំណូល និងការកើនឡើងនៃតម្រូវការចំណាយលើផ្នែកសុខភាព និងជំនួយសង្គម ដែលធ្វើឱ្យគម្លាតហិរញ្ញប្បទានរីកធំ។ ដើម្បីផ្តល់ហិរញ្ញប្បទានបំពេញគម្លាតនេះ បំណុលសាធារណៈរបស់កម្ពុជា ដែលស្ទើរតែជាបំណុលខាងក្រៅទាំងស្រុង កើន ៧,៣ ភាគរយនៃផសស កើនដល់ ៣៥,៥ ភាគរយនៃ ផសស នៅឆ្នាំ ២០២៣ កើនពី ២៨,២ ភាគរយក្នុងឆ្នាំ ២០១៩។ កម្ចីខាងក្រៅនៅតែមានលក្ខណៈសម្បទានខ្លាំង ដោយទំហំជំនួយឥតសំណងមាន ៤៤,៧ ភាគរយក្នុងឆ្នាំ ២០២៣។ អត្រាការប្រាក់មធ្យមនៃកម្ចីជាប់កិច្ចសន្យា (contracted loan) គឺ ០,៩៦ ភាគរយក្នុងមួយឆ្នាំ ក្នុងឆ្នាំ ២០២៣ ថយពី ១,១១ ភាគរយក្នុងឆ្នាំ ២០២២ ខណៈដែលកាលវសានមធ្យមថយមកត្រឹម ២៤,១ ឆ្នាំ ថយពី ២៦,៩ ឆ្នាំ។

**តារាង ១. សមាសភាគនៃកម្មវិធីកញ្ចប់គ្រួសារ**

| ប្រភេទតាវកាលិក | លក្ខខណ្ឌ | # នៃការទូទាត់ | ចំនួនប្រាក់ (រៀល) |
|---|---|---|---|
| ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ ឆ្នាំ | ការពិនិត្យផ្ទៃពោះមុនពេលសម្រាល ក្នុងពេលមានគភ៌ | ៤ | ៨០.០០០ |
| | សម្រាលកូននៅមូលដ្ឋានសុខាភិបាលសាធារណៈ | ១ | ៤០០.០០០ |
| | ការពិនិត្យសុខភាពក្រោយពេលសម្រាល | ៣ | ៨០.០០០ |
| | ការពិនិត្យសុខភាព ការផ្តល់ថ្នាំបង្ការ និងការចាក់វ៉ាក់សាំងសម្រាប់កុមារ | ៧ | ៨០.០០០ |
| អាហារូបករណ៍ | កុមារចូលរៀនបឋមសិក្សា | ១២/ឆ្នាំ | ២០.០០០ |
| | កុមារចូលរៀនអនុវិទ្យាល័យ | ១២/ឆ្នាំ | ២០.០០០ |
| | | កុមារចូលរៀនវិទ្យាល័យ | ១២/ឆ្នាំ |
| ចាស់ជរាអាយុ ៦០ ឆ្នាំឡើង | ចាស់ជរាអាយុ ៦០ ឆ្នាំឡើង | ១២/ឆ្នាំ | ២៨.០០០ |
| ពិការភាព | ប័ណ្ណជនពិការ | ១២/ឆ្នាំ | ២៨.០០០ |
| ផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ | ប័ណ្ណសមធម៌ | ១២/ឆ្នាំ | ២៨.០០០ |
| ប្រាក់ឧបត្ថម្ភមូលដ្ឋាន | ប័ណ្ណសមធម៌ | ១២/ឆ្នាំ | ៣៤.០០០ |

*ប្រភព ៖ អាជ្ញាធរកម្ពុជា*

**ចិននៅតែជាឥណទាយកផ្លូវការធំជាងគេរបស់កម្ពុជា។** បំណុលសរុបដែលកម្ពុជាជំពាក់ចិនកើនដល់ ៤,១១ ពាន់លានដុល្លារ។ បើគិតជាចំណែកនៃបំណុលសាធារណៈខាងក្រៅសរុប បំណុលដែលកម្ពុជាជំពាក់ចិនថយមកត្រឹម ៣៦,៧ ភាគរយក្នុងឆ្នាំ ២០២៣ ថយពី ៤០,១ ភាគរយក្នុងឆ្នាំ ២០២២ ដោយសារកើនឡើងនៃបំណុលពហុភាគី។ ឥណទាយកធំជាងគេទីពីររបស់កម្ពុជា គឺធនាគារអភិវឌ្ឍន៍អាស៊ី ដែលកម្ពុជាជំពាក់២,៣ ពាន់លានដុល្លារ ឬស្មើនឹង ២៣,៦ ភាគរយនៃបំណុលសាធារណៈខាងក្រៅសរុប។

**ធនាគារពិភពលោកគឺជាឥណទាយកធំជាងគេទី ៣ របស់កម្ពុជា ដែលកម្ពុជាជំពាក់ ១,៣ ពាន់លានដុល្លារ ឬស្មើនឹង ១១,៨ ភាគរយនៃបំណុលសាធារណៈខាងក្រៅសរុប (គិតត្រឹម ដំណាច់ឆ្នាំ ២០២៣)។** ក្នុងឆ្នាំ ២០២៣ ចំនួនកម្ចីដែលបានចុះហត្ថលេខារវាងកម្ពុជា និងធនាគារពិភពលោក មានចំនួនច្រើនបំផុត គឺកើនដល់ ៥០១,៣ លានដុល្លារ ឬស្មើនឹង ២៧,៧ ភាគរយនៃបំណុលសាធារណៈខាងក្រៅសរុបដែលបានចុះកិច្ចសន្យា ក្នុងឆ្នាំ ២០២៣។ ស្រដៀងគ្នានេះ ចំនួនកម្ចីដែលធនាគារពិភពលោកផ្តល់ឱ្យកម្ពុជាក៏មានចំនួនច្រើនជាងគេផងដែរ គឺ ៣៩៣,៦ លានដុល្លារ ឬស្មើនឹង ២២,៣ ភាគរយនៃកម្ចីសាធារណៈខាងក្រៅសរុប ក្នុងឆ្នាំ ២០២៣។ កម្ចីរបស់ធនាគារពិភពលោក កើនយ៉ាងលឿនរហ័ស គឺកើនពី ១៥,៨ លានដុល្លារក្នុងមួយឆ្នាំ ក្នុងឆ្នាំ ២០១៧ ដើម្បីបំពេញការកើនឡើងនៃតម្រូវការផ្តល់ហិរញ្ញប្បទានដល់វិស័យអាទិភាព។ ផ្នែកដ៏ធំនៃវិស័យអាទិភាពដែលទទួលបានហិរញ្ញប្បទានពីធនាគារពិភពលោក មានដូចជាហិរញ្ញប្បទានដល់ការអភិវឌ្ឍគោលនយោបាយ ការអប់រំចំណេះទូទៅ និងឧត្តមសិក្សា សម្បទានដីសង្គមកិច្ច និងសម្បទានដីសេដ្ឋកិច្ច ពិពិធកម្មកសិកម្ម ការធ្វើឱ្យប្រសើរឡើងសមធម៌ និងគុណភាពសុខភាព និងតភ្ជាប់ផ្លូវថ្នល់ ការលើកកម្ពស់របរចិញ្ចឹមជីវិត ការផ្គត់ផ្គង់ទឹក និងការគ្រប់គ្រងគ្រោះមហន្តរាយ។[23] ក្រៅពីនេះ ជប៉ុន (១១,២ ភាគរយ) និងសាធារណរដ្ឋកូរ៉េ (៥,១) គឺជាឥណទាយកធំជាងគេទី ៤ និងទី ៥ របស់កម្ពុជា។ បំណុលចាស់មានចំនួន ៥,៦ ភាគរយនៃបំណុលសរុប។

**ការកើនឡើងនៃហិរញ្ញប្បទានខាងក្រៅដោយឥណទាយកផ្លូវការរបស់កម្ពុជា បានជួយលុបបំបាត់គម្លាតហិរញ្ញប្បទានដែលរីកធំដោយសារវិបត្តិកូវីដ-១៩។** ចំណាយកម្ចីកើនឡើងយ៉ាងឆាប់រហ័ស គឺកើនពី ៨២៩ លានដុល្លារ (២០១៩) ដល់ ១.២១៣ លានដុល្លារ (២០២០) ១.១៦៨ លានដុល្លារ (២០២១) ១.៣៤៥ លានដុល្លារ (២០២២) និង ១.៥២៣ លានដុល្លារ (២០២៣)។ ក្នុងចំណាយកម្ចីសរុប ១.៥២៣ លានដុល្លារ ក្នុងឆ្នាំ ២០២៣ ចំណាយកម្ចី ៦៣,១ ភាគរយផ្តល់ហិរញ្ញប្បទានដល់វិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈរបស់កម្ពុជា (ដឹកជញ្ជូន

23 សម្រាប់ព័ត៌មានលម្អិតស្តីពីវិស័យ និងគម្រោងនានា សូមមើល https://projects.worldbank.org/en/projects-operations/projects-list?lang=en&countrycode_exact=KH&os=0.

ថាមពល ធារាសាស្ត្រ ផ្គត់ផ្គង់ទឹក។ល។) និង ៣៦,៩ ភាគរយ ផ្តល់ហិរញ្ញប្បទានដល់វិស័យអាទិភាពមិនមែនហេដ្ឋារចនាសម្ព័ន្ធ (កសិកម្ម សុខាភិបាល ការអប់រំ និងអាទិភាពផ្សេងទៀត)។ ការណ៍នេះគូសបញ្ជាក់ពីការផ្លាស់ប្តូរដ៏សំខាន់នៃអាទិភាពរបស់រដ្ឋាភិបាល ត្បិតមួយទសវត្សរ៍មុន កម្ចីស្ទើរតែទាំងស្រុងត្រូវយកទៅផ្តល់ហិរញ្ញប្បទានដល់អាទិភាពហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។ ក្នុងឆ្នាំ ២០១៣ អាទិភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ទទួលបាន ៩៦,៦ ភាគរយនៃកម្ចីសរុប ហើយសល់ពីនេះគឺសម្រាប់អាទិភាពមិនមែនហេដ្ឋារចនាសម្ព័ន្ធ។

**បំណុលសាធារណៈខាងក្រៅដែលជាប្រាក់ដុល្លារអាមេរិក នៅតែមានចំនួនច្រើនជាងគេ គឺកើនដល់ ៥៦,០ ភាគរយនៃបំណុលសរុប ក្នុងឆ្នាំ ២០២៣ បន្ទាប់មកគឺបំណុលដែលជាសិទ្ធិដកប្រាក់ពិសេស (SDR) ដែលមានចំនួន ១៩,២ ភាគរយ។** ទោះបីចិនជាឥណទាយកធំជាងគេរបស់កម្ពុជាមែន ប៉ុន្តែបំណុលសាធារណៈខាងក្រៅរបស់កម្ពុជាដែលជាប្រាក់យ័ន មានចំនួនត្រឹមតែ ១១,៣ ភាគរយប៉ុណ្ណោះនៃទំហំបំណុលសរុប។ បំណុលសាធារណៈខាងក្រៅដែលជាប្រាក់យ៉េន ប្រាក់អឺរ៉ូ និងរូបិយវត្ថុផ្សេងទៀត មានចំនួន ១១,២ ភាគរយ, ៦,៩ ភាគរយ និង ៥,៤ ភាគរយរៀងគ្នា។ ចំណែកនៃបំណុលសាធារណៈខាងក្រៅដែលជារូបិយវត្ថុទាំងនេះ គឺមិនប្រែប្រួលឡើយក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ។

### *កម្ពុជានៅតែមានហានិភ័យទាបនៃសម្ពាធបំណុលខាងក្រៅ និងជារួម*

**ក្រោមក្របខណ្ឌនិរន្តរភាពបំណុលរបស់ប្រទេសមានប្រាក់ចំណូលទាប កម្ពុជានៅតែមានហានិភ័យទាបនៃសម្ពាធបំណុលខាងក្រៅ។** នេះបើយោងតាមការវិភាគនិរន្តរភាពបំណុលដោយធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងឆ្នាំ ២០២៣។ សមត្ថភាពគ្រប់គ្រងបំណុលបច្ចុប្បន្ន (current debt-carrying capacity) នៅតែស៊ីសង្វាក់គ្នានឹងការធ្វើចំណាត់ថ្នាក់រយៈពេលមធ្យម។ សេណារីយ៉ូដើមគ្រាសន្មតថាសេដ្ឋកិច្ចងើបឡើងវិញបន្តិចម្តងៗ មួយភាគធំជំរុញដោយការងើបឡើងនៃវិស័យទេសចរណ៍ និងការនាំចេញទំនិញកម្មន្តសាល។ អនុបាតបំណុលសាធារណៈសរុប និងបំណុលដែលមានការធានាជាសាធារណៈធៀបនឹង ផសស ត្រូវបានព្យាករណ៍ថានឹងកើនដល់ប្រមាណ ៤ ភាគរយនៃ ផសស នៅមួយទសវត្សរ៍ក្រោយ ប៉ុន្តែកម្រិតនេះត្រូវបានកំណត់ថានឹងនៅថេរ។ លើសពីនេះ សូចនាករបន្ទុកបំណុលត្រូវបានព្យាករណ៍ថានឹងនៅតែទាបជាងកម្រិតក្រោមសេណារីយ៉ូដើមគ្រា និងសេណារីយ៉ូវិបត្តិ។ ទោះជាយ៉ាងណា ការធ្វើតេស្តស្ត្រេស (stress test) បង្ហាញថា និរន្តរភាពបំណុលនៅតែងាយរងគ្រោះដោយសារវិបត្តិក្នុងការនាំចេញ និងកំណើន។

## ចក្ខុវិស័យ

**កំណើនសេដ្ឋកិច្ចឆ្នាំនេះត្រូវបានព្យាករណ៍ថានឹងកើនឡើងបន្តិចដល់ ៥,៨ ភាគរយ (សូមមើលតារាង ២) ដែលជំរុញជាចម្បងដោយការបន្តងើបឡើងវិញនៃការនាំចេញសេវាកម្ម និងទំនិញ។** បើសំឡឹងទៅមុខ ភាពប្រសើរឡើងនៃជញ្ជីងគណនីចរន្តរបស់កម្ពុជា ដែលគាំទ្រដោយភាពជោគជ័យមួយចំនួនក្នុងការធ្វើពិពិធកម្មផលិតផលនាំចេញរបស់ខ្លួន ក្រៅពីផលិតផល GTF (ឆ្ពោះទៅរកទំនិញកសិកម្ម ផ្ទាំងសូឡា និងគ្រឿងអេឡិចត្រូនិក និងគ្រឿងបង្កុំអគ្គិសនី) និងការពង្រីកទីផ្សារនាំចេញ ក្រៅពីសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប (ឆ្ពោះទៅរកទីផ្សារក្នុងតំបន់ ជាពិសេសទីផ្សារអាស៊ាន) គួរគាំទ្រដល់ភាពធន់នៃការនាំចេញទំនិញ។ ការងើបឡើងនៃសេដ្ឋកិច្ច រួមជាមួយនឹងការបន្តអនុវត្តកម្មវិធីជំនួយសង្គម គួរតែនាំឱ្យថយចុះអត្រាភាពក្រីក្រ ដែលជាផ្នែកបញ្ច្រាស់នៃកំណើនភាពក្រីក្រដែលទំនងជាលេចឡើងក្នុងឆ្នាំ ២០២០ និង ២០២១។ ការថយចុះភាពក្រីក្រ ត្រូវបានព្យាករណ៍ថានឹងមានសន្ទុះកើនឡើងក្នុងឆ្នាំនេះ។

**កំណើនពិតរបស់កម្ពុជាត្រូវបានព្យាករណ៍ថានឹងកើនថែមទៀតក្នុងរយៈពេលខ្លី។** កំណើនពិតរបស់កម្ពុជាត្រូវបានព្យាករណ៍ថានឹងកើនដល់ ៦,១ ភាគរយក្នុងឆ្នាំ ២០២៥ និងកើនដល់ ៦,៤ ភាគរយក្នុងឆ្នាំ ២០២៦។ឧស្សាហកម្មទេសចរណ៍ និងបដិសណ្ឋារកិច្ចត្រូវបានប៉ាន់ប្រមាណថានឹងបន្តរីកចម្រើន ជាមួយនឹងការព្យាករណ៍ថានឹងមានកំណើននៃចំនួនភ្ញៀវទេសចរណ៍ដែលចូលមកទស្សនាកម្ពុជា ដែលនឹងកើនលើសកម្រិតកាលពីមុនវិបត្តិកូវីដ-១៩ ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ខណៈដែលការនាំចេញទំនិញ និងលំហូរចូលការវិនិយោគផ្ទាល់ពីបរទេសត្រូវបានរំពឹងថានឹងកើនឡើងបន្ថែមទៀត តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីថ្មីដែលទើបត្រូវបានផ្តល់សច្ចាប័ន និងការកើនឡើងយ៉ាងខ្លាំងនៃការវិនិយោគរបស់វិស័យសាធារណៈ និងវិស័យឯកជនលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តសំខាន់ៗ។

## បញ្ហាប្រឈម និងហានិភ័យ

**ចក្ខុវិស័យនេះអាចប្រឈមនឹងហានិភ័យធ្លាក់ចុះខ្លាំងដែលរួមបញ្ចូលតម្រូវការសកលដែលថយចុះខ្លាំងជាងការរំពឹងទុក ភាពតឹងរ៉ឹងនៃលក្ខខណ្ឌហិរញ្ញវត្ថុសកល និងការកើនឡើងនៃបំណុល និងចំណាយខ្ពស់លើការខ្ចីប្រាក់ និងការងើបឡើងនៃសេដ្ឋកិច្ចក្នុងប្រទេសចិនដែលយឺតជាងការប៉ាន់ស្មាន។** សេដ្ឋកិច្ចកម្ពុជាដែលប្រើប្រាស់ប្រាក់ដុល្លារខ្លាំងរងផលប៉ះពាល់ដោយសាររដ្ឋរឹងបន្តឹងនៃគោលនយោបាយរូបិយវត្ថុសហរដ្ឋអាមេរិក ខណៈដែលការនាំចេញផលិតផល

GTF របស់កម្ពុជាប្រែប្រួលទៅតាមតម្រូវការអ្នកប្រើប្រាស់នៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប។ក្រៅពីនេះ កម្ពុជាពឹងផ្អែកលើលំហូរចូលការវិនិយោគផ្ទាល់ពីចិន។ នៅចិន ការថមថយបន្ថែមទៀតនៃទំនុកចិត្តរបស់អ្នកប្រើប្រាស់ អាចធ្វើឱ្យការចំណាយថយចុះ និងដាក់សម្ពាធលើកំណើន ជាពិសេសដោយសារតែវិស័យអចលនទ្រព្យរបស់ចិនបន្តដាំក្បាលចុះនៅឡើយ។ នៅក្នុងប្រទេស ការកើនឡើងលឿនជាងការរំពឹងទុកនៃឥណទានមិនដំណើរការ អាចធ្វើឱ្យប៉ះពាល់ដល់ស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុ ដោយសារការកែតម្រូវទីផ្សារលំនៅឋាននៅតែបន្ត។ អត្រាការប្រាក់ខ្ពស់នៅទូទាំងពិភពលោក និងការថយចុះកំណើនឥណទានបន្តជះឥទ្ធិពលលើវិស័យហិរញ្ញវត្ថុរបស់កម្ពុជា។ នេះជាសញ្ញានៃការលក់ទ្រព្យសកម្មដើម្បីសងបំណុល (deleveraging)។

# ជម្រើសគោលនយោបាយ

**ធៀបនឹងមូលដ្ឋាននៃការងើបឡើងវិញជាបន្តបន្ទាប់នេះ ចាំបាច់ត្រូវបង្កើនកិច្ចខិតខំប្រឹងប្រែងស្តារលំហសារពើពន្ធឡើងវិញ ក្នុងពេលដែលមូលដ្ឋានសារពើពន្ធរបស់កម្ពុជារួមតូច បន្ទាប់ពីកិច្ចអន្តរាគមន៍ជាច្រើនរបស់រដ្ឋាភិបាល។** ទីមួយ គួរមានការពិនិត្យឡើងវិញលើការបង្កើនលក្ខខណ្ឌអនុគ្រោះពន្ធ និងការលើកលែងពន្ធ។ ទីពីរ ចាំបាច់ត្រូវមានការកែទម្រង់ពន្ធចំណូលពីសាជីវកម្ម (corporate income tax) ដើម្បីពង្រីកមូលដ្ឋានពន្ធ និងពង្រឹងអនុលោមភាព។ ទីបី ការដាក់ចេញពន្ធចំណូលបុគ្គល គួរតែជាគោលបំណងរយៈពេលមធ្យមនៃយុទ្ធសាស្ត្រកៀរគរចំណូលនៅពេលបន្ទាប់។

**ផ្អែកតាមកម្រិតខ្ពស់នៃបំណុលឯកជន ការកើនឡើងនៃឥណទានមិនដំណើរការ និងការថយចុះចំណូលសម្រាប់ទ្រព្យសកម្មនៃវិស័យធនាគារ វិធានការធានាស្ថិរភាពហិរញ្ញវត្ថុ ក៏សំខាន់ផងដែរ។** ការកើនឡើងឥណទានយ៉ាងគំហុកនាពេល ថ្មីៗនេះ បានជំរុញឱ្យមានបំណុលវិស័យឯកជនក្នុងកម្រិតខ្ពស់ ដែលប្រមូលផ្តុំក្នុងវិស័យអចលនទ្រព្យ (real-estate exposures)។ ដើម្បីធានាស្ថិរភាពហិរញ្ញវត្ថុ គួរផ្តោតការយកចិត្តទុកដាក់ភ្លាមៗលើការបង្កើនការត្រួតពិនិត្យធនាគារ ៖ ការធ្វើតេស្តស្ត្រេសរបស់គ្រឹះស្ថាននីមួយៗ អធិការកិច្ចជាប្រព័ន្ធនៅទីតាំងផ្ទាល់ ការបង្កើនភាពបន្សុីគ្នានៃក្របខណ្ឌបទបញ្ញត្តិទៅនឹងស្តង់ដារអន្តរជាតិ និងការវាយតម្លៃល្អិតល្អន់លើគុណភាពនៃផលបត្រកម្ចី (loan portfolio) ជាដើម។ គិតត្រឹមឆ្នាំ ២០២២ មានកើនឡើងយ៉ាងលឿនរហ័សនៃចំនួនគ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជា។ ដូច្នេះ ការបង្រួបបង្រួមវិស័យហិរញ្ញវត្ថុតាមរយៈការរួមបញ្ចូលគ្នា (merger) និងការទិញយក (acquisition) គួរតែអាចជួយរក្សាកម្រិតប្រាក់ចំណេញ តាមរយៈការបង្កើនប្រសិទ្ធភាព និងចំណែកទីផ្សារ។ ដើម្បីត្រៀមខ្លួនសម្រាប់ការកើនឡើងនៃកម្ចីមិនដំណើរការ ចាំបាច់ត្រូវធានាថា ជម្រើសនៃការរំលាយចោល (resolution) មានត្រៀមជាស្រេចសម្រាប់ការអនុវត្តទៅតាមភាពចាំបាច់ និងពង្រឹងរបបអសោធនភាពរបស់កម្ពុជា។ ចាំបាច់ត្រូវបន្តកិច្ចខិតខំប្រឹងប្រែងរៀបចំច្បាប់ស្តីពីការធានារ៉ាប់រងប្រាក់បញ្ញើ និងការរំលាយធនាគារ។

**នៅចំពោះមុខ ចាំបាច់ត្រូវបង្កើនកិច្ចខិតខំប្រឹងប្រែងបង្កបរិយាកាសធុរកិច្ចអំណោយផល តាមរយៈការលើកទឹកចិត្តឱ្យក្រុមហ៊ុននានាធ្វើប្រតិបត្តិការ បង្កើតថ្មី និងបង្កើនផលិតភាពប្រកបដោយប្រសិទ្ធភាព។** ចាំបាច់ត្រូវដោះស្រាយរបាំងធំៗទាំង ៣ ដែលបានសន្មត គឺការអនុវត្តវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធអត្រាពន្ធ និងរដ្ឋបាលពន្ធ ដែលកត់សម្គាល់ដោយអង្កេតសហគ្រាសឆ្នាំ ២០២៣ ដោយធនាគារពិភពលោក។ ដំណោះស្រាយគឺការបង្កើនការចុះបញ្ជីអាជីវកម្ម ការកាត់បន្ថយបន្ទុកអនុលោមភាពផ្នែកពន្ធ និងការពិនិត្យឡើងវិញលើអត្រាពន្ធដែលមានប្រសិទ្ធភាព។ អង្កេតសហគ្រាសឆ្នាំ ២០២៣ គូសបញ្ជាក់ថា នៅកម្ពុជា គេត្រូវការពេល ៨,២ ថ្ងៃដើម្បីរត់ឯកសារនាំចេញផ្ទាល់ តាមរយៈគយ និងរយៈពេល ៩ ថ្ងៃដើម្បីរត់ឯកសារនាំចូល ធៀបនឹងរយៈពេល ៤ ថ្ងៃ និង ៨,៣ ថ្ងៃរៀងគ្នា នៅវៀតណាម។ ដើម្បីកាត់បន្ថយរយៈពេលចាំបាច់ក្នុងការរត់ឯកសារដើម្បីអាចនាំចូលបាន ចាំបាច់ត្រូវពន្លឿនការអនុវត្តការដំណើរការឯកសារតាមប្រព័ន្ធអេឡិចត្រូនិកមុនពេលមកដល់ ទន្ទឹមនឹងការអនុវត្តនីតិវិធីរត់ឯកសារគយដោយស្វ័យប្រវត្តិទាំងស្រុងដើម្បីអាចឱ្យមានការប្រើប្រាស់ជាផ្លូវការនូវឯកសារអេឡិចត្រូនិកដើម្បីកាត់បន្ថយរយៈពេលរត់ឯកសារនាំចេញ។ ក្រៅពីនេះ អង្កេតសហគ្រាសឆ្នាំ ២០២៣ បានបង្ហាញថា នៅកម្ពុជា គេត្រូវការពេល ២៨ ថ្ងៃដើម្បីទទួលបានអាជ្ញាប័ណ្ណនាំចូល និងរយៈពេល ៣០ ថ្ងៃដើម្បីទទួលបានអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការ ធៀបនឹងរយៈពេល ១៣,២ ថ្ងៃ និង ១០,៧ ថ្ងៃរៀងគ្នា នៅវៀតណាម និងរយៈពេល ៩ ថ្ងៃ និង ៥ ថ្ងៃរៀងគ្នា នៅឥណ្ឌូនេស៊ី។

**ដូច្នេះ ការសម្របសម្រួលលក្ខខណ្ឌតម្រូវស្មុគស្មាញ និងរឹតត្បិតក្នុងការចុះបញ្ជីអាជីវកម្ម បូករួមនឹងការធ្វើឱ្យប្រសើរឡើងនូវការបំពេញមុខងារនៃក្របខណ្ឌអសោធនភាព នឹងជួយកាត់បន្ថយចំណាយនៃការចុះបញ្ជី និងការបិទក្រុមហ៊ុន ទន្ទឹមនឹងការបង្កើនភាពអាចរកបានប្រាក់ចំណេញក្នុងបរិយាកាសនិយ័តកម្ម។** ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងយ៉ាងច្រើនក្នុងការធ្វើឱ្យសេវាអាជីវកម្មមានលក្ខណៈសាមញ្ញ និងដំណើរការតាមប្រព័ន្ធឌីជីថល ជាពិសេសការចេញអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាត ដើម្បីកាត់បន្ថយចំណាយពាក់ព័ន្ធ។ ការពន្លឿនការអនុវត្តពេញលេញនូវដំណាក់កាលចុងក្រោយនៃប្រព័ន្ធបញ្ជរតែមួយជាតិ ដែលរួមបញ្ចូលអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងឯកសារផ្សេងទៀត គឺជាការចាំបាច់។ ការតាមដានរហ័សលើការអនុវត្តប្រតិបត្តិករសេដ្ឋកិច្ចដែលទទួលបានអាជ្ញាប័ណ្ណ ក៏ជាការចាំបាច់មួយផងដែរ។

**តារាង ២. ចក្ខុវិស័យម៉ាក្រូបញ្ជាក់ពីការបន្តងើបឡើងនៃសេដ្ឋកិច្ច**

| | 2019 | 2020 | 2021 | 2022 | 2023e | 2024p | 2025p | 2026p |
|---|---|---|---|---|---|---|---|---|
| **គណនីជាតិ និងតម្លៃ** | | | | | | | | |
| ផសស គិតតាមតម្លៃទីផ្សារថេរ (ការប្រែប្រួល %) | 7.1 | -3.1 | 3.0 | 5.2 | 5.4 | 5.8 | 6.1 | 6.4 |
| កសិកម្ម | -0.5 | 0.6 | 1.2 | 0.7 | 1.4 | 1.4 | 1.4 | 1.5 |
| ឧស្សាហកម្ម | 11.3 | -1.4 | 9.4 | 8.3 | 4.8 | 7.4 | 7.7 | 8.1 |
| សេវា | 6.2 | -6.3 | -2.7 | 3.5 | 8.0 | 6.1 | 6.3 | 6.4 |
| សន្ទស្សន៍តម្លៃអ្នកប្រើប្រាស់ | 1.9 | 2.9 | 2.8 | 5.5 | 2.1 | 2.8 | 2.7 | 3.0 |
| **រដ្ឋាភិបាលទូទៅ (% នៃ ផសស)** | | | | | | | | |
| ចំណូល និងជំនួយឥតសំណង | 27.0 | 24.1 | 22.0 | 23.4 | 21.4 | 20.7 | 20.6 | 20.3 |
| ចំណាយ និងការផ្តល់កម្ចីសុទ្ធ | 25.5 | 28.8 | 29.2 | 27.7 | 26.7 | 26.2 | 25.0 | 24.5 |
| សមតុល្យរួម (រួមទាំងជំនួយឥតសំណង) | 1.5 | -4.7 | -7.2 | -4.4 | -5.3 | -5.5 | -4.4 | -4.2 |
| ហិរញ្ញប្បទានពីបរទេស | 3.1 | 4.7 | 4.2 | 5.3 | 5.3 | 4.3 | 3.7 | 3.6 |
| ហិរញ្ញប្បទានក្នុងស្រុកសរុប (ពីប្រាក់សន្សំចរន្ត) | -3.8 | 1.1 | 4.0 | 0.3 | 1.2 | 2.6 | 2.2 | 2.2 |
| ការសងរំលស់បំណុល | -0.8 | -1.0 | -1.1 | -1.2 | -1.3 | -1.4 | -1.5 | -1.6 |
| **រូបិយវត្ថុ និងឥណទាន** | | | | | | | | |
| រូបិយវត្ថុទូទៅ (ការប្រែប្រួល %) | 18.2 | 15.3 | 20.0 | 8.2 | 12.5 | 13.0 | 15.1 | 17.0 |
| ការផ្តល់ឥណទានដល់វិស័យឯកជន (ការប្រែប្រួល %) | 27.0 | 17.7 | 23.2 | 18.9 | 4.1 | 7.6 | 10.8 | 12.6 |
| **វិស័យខាងក្រៅ (លានដុល្លារអាមេរិក លុះត្រាតែមានការបញ្ជាក់ផ្សេងពីនេះ)** | | | | | | | | |
| ការនាំចេញ (មាស និងសេវា) | 16,351 | 16,692 | 18,566 | 24,494.7 | 29,149.5 | 35,679.0 | 45,186.1 | 58,646.5 |
| ការនាំចូល (ទំនិញ និងសេវា) | 18,198 | 19,955 | 29,489 | 40,467.1 | 32,125.3 | 35,953.8 | 44,126.2 | 57,068.3 |
| លំហូរចូលសរុបនៃការវិនិយោគផ្ទាល់ពីបរទេស | 3,561 | 3,498 | 3,391 | 3,425 | 3,639 | 4,080 | 4,351 | 4,620 |
| ទុនបម្រុងផ្លូវការសុទ្ធ | 18,763 | 21,334 | 20,272 | 17,816.0 | 19,895.6 | 23,550.4 | 26,135.4 | 28,785.9 |
| (ចំនួនខែនៃការនាំចូល) | 9.7 | 10.4 | 8.1 | 7.0 | 6.0 | 5.5 | 5.0 | 5.0 |
| គណនីចរន្ត (ភាគរយនៃ ផសស) | -8.0 | -7.5 | -39.7 | -25.5 | 1.7 | 2.7 | 2.6 | 1.6 |
| អត្រាប្តូរប្រាក់ (រៀលក្នុង ១ដុល្លារអាមេរិក, មធ្យម) | 4,070 | 4,077 | 4,100 | 4,150 | 4,110 | 4,100 | 4,090 | 4,080 |
| **បំណុលសាធារណៈសរុប (% នៃ ផសស)** | 28.1 | 35.9 | 36.1 | 36.7 | 33.6 | 35.6 | 35.5 | 34.8 |
| **សម្គាល់ ៖** | | | | | | | | |
| ផសស ណូមីណល លានដុល្លារអាមេរិក | 27,030 | 25,972 | 26,963 | 29,158 | 31,662 | 34,290 | 37,271 | 40,559 |

*ប្រភព ៖* អាជ្ញាធរកម្ពុជា, ការប៉ាន់ស្មាន និងការព្យាករណ៍របស់បុគ្គលិកធនាគារពិភពលោក

*ចំណាំ ៖* e = ការប៉ាន់ស្មាន; p = ការព្យាករ

**ការបង្កើនលទ្ធផលសិក្សា គឺជាកត្តាដ៏សំខាន់ដើម្បីការអភិវឌ្ឍកម្លាំងពលកម្ម "ដែលត្រៀមខ្លួនសម្រាប់ពេលអនាគត" និងជំរុញកំណើនផលិតភាពនាពេលអនាគតរបស់កម្ពុជា ក្នុងពេលដែលកម្ពុជាខិតខំប្រែក្លាយទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ ២០៥០។** កំណើនផលិតភាពកម្លាំងពលកម្ម ថយចុះយ៉ាងគំហុកក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះ។ មានកុមារកម្ពុជាតិចតួចដែលបានចុះឈ្មោះក្នុងការអប់រំកុមារតូច ខណៈដែលលទ្ធផលសិក្សារបស់សិស្សបឋមសិក្សា មានការធ្លាក់ចុះ។ មានសិស្សតិចតួចដែលបានឡើងទៅមធ្យមសិក្សា ហើយសិស្សទាំងនោះ ច្រើនតែមិនបានត្រៀមខ្លួនគ្រប់គ្រាន់ និងងាយនឹងបោះបង់ការសិក្សា។ (សម្រាប់កិច្ចពិភាក្សាកាន់តែស៊ីជម្រៅស្តីពីការពង្រឹងប្រព័ន្ធអប់រំរបស់កម្ពុជាដើម្បីកំណើននាពេលអនាគត សូមមើលផ្នែកអត្ថបទផ្តោតពិសេស)។

**ដែលសំខាន់ផងដែរគឺត្រូវបង្កើនសមិទ្ធកម្មឡូជីស្ទិក ទៅតាមចំណុចដៅក្នុងយុទ្ធសាស្ត្របញ្ចកោណ។**[24] ចាំបាច់ត្រូវខិតខំប្រឹងប្រែងបន្ថែមដើម្បីកាត់បន្ថយចំណាយថ្លៃដឹកជញ្ជូន និងឡូជីស្ទិក តាមរយៈការពិនិត្យតាមដានប្រសិទ្ធភាពនៃច្រកពាណិជ្ជកម្មសំខាន់ៗ ដូចជា កំពង់ផែ និងប៉ុស្តិ៍ត្រួតពិនិត្យតាមព្រំដែន។ អង្កេតសហគ្រាសបង្ហាញថា បច្ចុប្បន្នការដឹកជញ្ជូនគឺជារបាំងធំជាងគេទី ៤ សម្រាប់អាជីវកម្ម។ នេះស៊ីសង្វាក់គ្នានឹងលទ្ធផលរកឃើញមួយដែលត្រូវបានលើកមកពិភាក្សាក្នុងកំណត់សម្គាល់គោលនយោបាយដែលបានវិភាគការរំខានដល់ខ្សែច្រវាក់ផ្គត់ផ្គង់នៅក្រោយវិបត្តិកូវីដ-១៩។ លទ្ធផលរកឃើញទាំងនេះគូសបញ្ជាក់ថា ចំណាយផ្នែកឡូជីស្ទិកទូទាំងប្រទេសនៅកម្ពុជា ត្រូវបានប៉ាន់ស្មានថាស្មើនឹង ២៦,៤ ភាគរយនៃផសស ក្នុងឆ្នាំ ២០២០ គឺខ្ពស់ខ្លាំងជាងក្នុងប្រទេសក្នុងអាស៊ានដែលយកមកប្រៀបធៀប។ ក្នុងន័យនេះ ចាំបាច់ត្រូវបង្កើតក្រុមការងារមួយ និងអាជ្ញាធរមូលដ្ឋានដើម្បីសម្របសម្រួលពាណិជ្ជកម្មដោយមានការគាំទ្រតាមខ្សែទូរស័ព្ទ (hotline support) ជាពិសេសសម្រាប់ការដឹកជញ្ជូនផ្លូវគោក។

**ការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធរបស់កម្ពុជា ជាពិសេសការផ្គត់ផ្គង់អគ្គិសនី មានសារៈសំខាន់ណាស់សម្រាប់ការឈានដល់កម្មន្តសាល និងឧស្សាហកម្មកសិផល ដែលមានតម្លៃបន្ថែមកាន់តែខ្ពស់។** ខណៈដែលលទ្ធភាពទទួលបានអគ្គិសនីប្រើប្រាស់មានភាពប្រសើរឡើងខ្លាំង ភាពរអាក់រអួលនៃការផ្គត់ផ្គង់អគ្គិសនី នៅតែជាចំណុចរាំងស្ទះដ៏ធំមួយ។ អង្កេតសហគ្រាសបញ្ជាក់ថា នៅកម្ពុជា ៤៣ ភាគរយនៃក្រុមហ៊ុនដែលបានអង្កេតធ្លាប់ដាច់ភ្លើង (ដាច់ភ្លើង ០,៩ ដងក្នុងខែធម្មតាណាមួយ) ធៀបនឹងការដាច់ភ្លើង ១២,៧ ភាគរយ (ដាច់ភ្លើង ០,២ ដងក្នុងខែធម្មតាណាមួយ) នៅឥណ្ឌូនេស៊ី និងការដាច់ភ្លើង ២៨,៦ ភាគរយ (ដាច់ភ្លើង ០,៤ ដងក្នុងខែធម្មតាណាមួយ) នៅម៉ាឡេស៊ី (២០១៩)។ ការផ្គត់ផ្គង់អគ្គិសនីមិនគ្រប់គ្រាន់ អាចបង្កើនចំណាយ រំខានដល់ផលិតកម្ម និងកាត់បន្ថយភាពអាចរកបានប្រាក់ចំណេញ។ អង្កេតសហគ្រាសបានគូសបញ្ជាក់ថា នៅកម្ពុជា មានការខាតបង់កាន់តែច្រើនដោយសារការដាច់ភ្លើង ព្រោះចំណាយពាក់ព័ន្ធកើនពី ០,៣ ភាគរយនៃការលក់ប្រចាំឆ្នាំ ក្នុងឆ្នាំ ២០១៣ ដល់ ១,១ ភាគរយក្នុងឆ្នាំ ២០២៣ គឺខ្ពស់ខ្លាំងជាងឥណ្ឌូនេស៊ី (០,២ ភាគរយ) វៀតណាម (០,២ ភាគរយ) និងសិង្ហបុរី (០ ភាគរយ)។ ចាំបាច់ត្រូវមានការវិនិយោគធំៗលើវិស័យថាមពលដើម្បីដោះស្រាយបញ្ហាប្រឈម ២ នៃការបំពេញតម្រូវការអគ្គិសនីដែលកើនឡើងយ៉ាងលឿនរហ័ស ទន្ទឹមនឹងការបំពេញតាមការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះការប្រែប្រួលអាកាសធាតុ។ បន្ថែមលើនោះ ចាំបាច់ត្រូវមានការវិនិយោគដើម្បីកែលម្អសេវាមូលដ្ឋានក្នុងទីក្រុង ដូចជា ទឹកស្អាត អនាម័យ ការគ្រប់គ្រងសំណល់រឹង ទូរគមនាគមន៍ និងការដឹកជញ្ជូន រួមនឹងការពង្រឹងការធ្វើផែនការទីក្រុង។

24 យុទ្ធសាស្ត្របញ្ចកោណគឺជាផែនទីបង្ហាញផ្លូវសម្រាប់ប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានប្រាក់ចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។

# ផ្នែកទី២ ៖

## ការពង្រឹងប្រព័ន្ធអប់រំរបស់កម្ពុជា ដើម្បីកំណើននាពេលអនាគត[25]




25 ផ្នែកអត្ថបទផ្តោតពិសេសនេះ រួមចំណែកដោយ Lauri Pynnonen។



## សេចក្តីផ្តើម

**កម្ពុជាបានបោះជំហានគួរឱ្យកត់សម្គាល់ ក្នុងការពង្រីកលទ្ធភាពទទួលបានការអប់រំក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ។** អត្រាពិតនៃការសិក្សារបស់កម្ពុជា កើនឡើងជាបន្តបន្ទាប់ ដោយអត្រាចូលរៀននៅបឋមសិក្សា កើនដល់ ៩០ ភាគរយក្នុងឆ្នាំ ២០១៩ កើនពី ៨១ ភាគរយក្នុងឆ្នាំ ២០០៩។[26] ស្រដៀងគ្នានេះ ការចុះឈ្មោះចូលរៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ បានបង្ហាញពីវឌ្ឍនភាពល្អ។ ថ្វីបើសម្រេចបានសមិទ្ធផលទាំងនេះមែន ប៉ុន្តែកម្ពុជានៅតែប្រឈមនឹងបញ្ហាជាច្រើន ក្នុងការផ្តល់ការអប់រំប្រកបដោយគុណភាពដល់ប្រជាពលរដ្ឋគ្រប់រូប។ កន្លងមក វិបត្តិកូវីដ-១៩ បានបង្កើនភាពងាយរងគ្រោះនៃប្រព័ន្ធអប់រំ ជាមួយនឹងការអូសបន្លាយពេលបិទសាលារៀន ដែលនាំឱ្យមានការខាតបង់ការរៀនសូត្រយ៉ាងច្រើន[27]។សូម្បីតែកាលពីមុនវិបត្តិកូវីដ-១៩ ក៏ដោយ ក៏កម្ពុជាបានប្រឈមរួចទៅហើយនឹងអត្រាខ្ពស់នៃភាពខ្សត់ខ្សោយនៃការរៀនសូត្រ (learning poverty rate) ដោយសិស្សទទួលបានពិន្ទុទាបទាំងក្នុងមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា។ លើសពីនេះ ភាពខុសគ្នានៃលទ្ធភាពទទួលបានការអប់រំ ជាពិសេសនៅកម្រិតមធ្យមសិក្សា និងភាពខុសគ្នានៃលទ្ធផលសិក្សាបន្តលេចឡើងក្នុងតំបន់ភូមិសាស្រ្ត និងសាវតារសង្គមកិច្ច-សេដ្ឋកិច្ចផ្សេងៗ។

**ការវិនិយោគលើការអប់រំមិនត្រឹមតែជាកត្តាចាំបាច់មួយនៅក្នុងសង្គមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាកត្តាចាំបាច់នៅក្នុងសេដ្ឋកិច្ចផងដែរ។** កម្លាំងពលកម្មដែលមានការអប់រំល្អ និងមានបំណិន គឺជាមូលដ្ឋានគ្រឹះនៃផលិតភាព នវានុវត្តន៍ និងភាពប្រកួតប្រជែង នៅក្នុងសេដ្ឋកិច្ចសកលបច្ចុប្បន្នដែលជំរុញដោយពុទ្ធិ។ ប្រទេសដែលបានកំណត់យកការវិនិយោគលើការអប់រំ ជាអាទិភាព ដូចជា ហ្វាំងឡង់ សាធារណរដ្ឋកូរ៉េ និងសិង្ហបុរី បានច្បាមយកអត្ថប្រយោជន៍សេដ្ឋកិច្ចយ៉ាងច្រើន និងបានប្រែក្លាយទៅជាប្រទេសមានប្រាក់ចំណូលខ្ពស់ និងសេដ្ឋកិច្ចរស់រវើក។ ផ្ទុយទៅវិញ ការមិនខ្វល់ខ្វាយពីការអប់រំ អាចបង្កការខាតបង់ធ្ងន់ធ្ងរ និងធំទូលាយ។ កម្រិតទាបនៃការអប់រំ និងលទ្ធផលសិក្សានឹងបង្កឱ្យមានវដ្តនៃភាពក្រីក្រតជំនាន់ កាត់បន្ថយផលិតភាពរបស់កម្លាំងពលកម្ម និងរាំងស្ទះដល់សមត្ថភាពរបស់ប្រទេសក្នុងការសម្របខ្លួនទៅតាមភាពជឿនលឿននៃបច្ចេកវិទ្យា និងការប្រែប្រួលនៃទីផ្សារសកល។ នៅកម្ពុជាដែលភាពខ្សត់ខ្សោយការរៀនសូត្រ មានអត្រាខ្ពស់ និងមានភាពខុសគ្នានៃលទ្ធភាពទទួលបានការអប់រំ និងគុណភាព អាចមានផលវិបាកធំធេងដោយសារភាពអសកម្មផ្នែកសេដ្ឋកិច្ច និងសង្គម។

**ពិន្ទុ ០,៤៩ សម្រាប់សន្ទស្សន៍មូលធនមនុស្សរបស់កម្ពុជាបង្ហាញថា ចាំបាច់ត្រូវដោះស្រាយបញ្ហាប្រឈមទាំងនេះជាបន្ទាន់។** ពិន្ទុនេះបញ្ជាក់ថា កុមារម្នាក់ដែលបានកើតក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ នឹងមានផលិតភាពតែ ៤៩ ភាគរយប៉ុណ្ណោះ ប្រសិនបើពួកគេអាចទទួលបានការអប់រំពេញលេញ និងសុខភាពល្អបរិបូរណ៍ ឬអាចនិយាយបានថា បច្ចុប្បន្នកម្ពុជាសម្រេចបានសក្តានុពលមូលធនមនុស្សរបស់ខ្លួនបានតែប្រហែលពាក់កណ្តាលប៉ុណ្ណោះ។ ការបង្កើនលទ្ធផលអប់រំ ដោយចាប់ផ្តើមពីជំហានមូលដ្ឋាន ជាកត្តាសំខាន់សម្រាប់កម្ពុជាក្នុងការសម្រេចបានសក្តានុពលមូលនិធនមនុស្សពេញលេញ និងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។

**ក្នុងពេលដែលកម្ពុជាបានបំណងប្រែក្លាយទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ ២០៣០ ការផ្តោតអាទិភាពលើការអភិវឌ្ឍមូលធនមនុស្ស តាមរយៈការអប់រំ គឺជាការសំខាន់។** បំណិនមូលដ្ឋានរឹងមាំ គឺជាបាតគ្រឹះនៃបំណិនកម្រិតខ្ពស់ខាងការត្រិះរិះ បច្ចេកទេស និងបំណិនផ្នែកសង្គម និងអារម្មណ៍នៅដំណាក់កាលក្រោយមកទៀតនៃជីវិត។ បំណិនទាំងនេះមានសារៈសំខាន់សម្រាប់ការពង្រឹងសេដ្ឋកិច្ចដែលទ្រទ្រង់ដោយបច្ចេកវិទ្យា និងនវានុវត្តន៍ ការបង្កើនផលិតភាពកម្លាំងពលកម្ម និងការជំរុញឱ្យកម្ពុជាធ្វើអន្តរកាលដោយជោគជ័យឆ្ពោះទៅរកស្ថានភាពជាប្រទេសមានប្រាក់ចំណូលខ្ពស់។ ទោះជាយ៉ាងណា ការសម្រេចគោលដៅនេះ នឹងទាមទារកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការដោះស្រាយបញ្ហាប្រឈមដែលបន្តលេចឡើងនៅក្នុងប្រព័ន្ធអប់រំ ដូចជា វិភាជធនធានមិនស្មើគ្នា មានភាពកម្រិតនៃប្រសិទ្ធភាពរបស់គ្រូបង្រៀន និងគម្លាតក្នុងការរៀនសូត្រកម្រិតមូលដ្ឋាន។

**កាលពីមួយទសវត្សរ៍មុន មានការកើនឡើងគួរឱ្យកត់សម្គាល់នៃចំណាយសាធារណៈលើការអប់រំ ជាពិសេសចំណាយលើប្រាក់ខែគ្រូ។** ទោះជាយ៉ាងណា ការបង្កើនការផ្តល់ធនធាននេះ មិនបាននាំទៅរកវិភាជធនធានកាន់តែមានប្រសិទ្ធភាព ឬលទ្ធផលសិក្សាកាន់តែប្រសើរសម្រាប់សិស្សនោះទេ។ កម្ពុជាទទួលបានលទ្ធផលទាបនៅកម្រិតសកល ក្នុងការវាយតម្លៃអន្តរជាតិទ្រង់ទ្រាយធំ ដូចជា ម៉ាទ្រីសការសិក្សាបឋមសិក្សានៅអាស៊ីអាគ្នេយ៍ (SEA-PLM) និងកម្មវិធីសម្រាប់ការវាយតម្លៃសិស្សអន្តរជាតិ (PISA) បូករួមនឹងការថយចុះលទ្ធផលសិក្សា ឆ្លុះបញ្ចាំងពីភាពខុសគ្នានេះ។ ការកើនឡើងនៃចំណាយរបស់រដ្ឋាភិបាលលើការអប់រំ ជាចម្បងគឺបណ្តាលមកពីការដំឡើងប្រាក់ឈ្នួលសម្រាប់បុគ្គលិកអប់រំ ដោយចំណាយលើប្រាក់ឈ្នួលមានជិត ៨០ ភាគរយនៃចំណាយសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ក្នុងឆ្នាំ ២០២១។ ផ្ទុយទៅវិញ ចំណាយមូលធនរបស់ក្រសួងអប់រំ យុវជន និងកីឡា ថយចុះយ៉ាងខ្លាំង គឺថយពី ២៧ ភាគរយក្នុងឆ្នាំ ២០២១ មកត្រឹម ១៧ ភាគរយនៃចំណាយសរុបក្នុងឆ្នាំ ២០២១[28]។

**អ្វីដែលជាការព្រួយបារម្ភខ្លាំងបំផុតគឺអប្រសិទ្ធភាពនៃការដាក់ពង្រាយគ្រូបង្រៀន ដែលបានធ្វើឱ្យមានចំនួនសិស្សច្រើន**

26 របាយការណ៍អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ២០១៤, ២០១៩/២០២០។
27 Bhatta et al. ២០២២។
28 ធនាគារពិភពលោក ២០២៤e។

**ក្នុងមួយថ្នាក់ គឺ ៤៥-៦០ នាក់។** មកទល់បច្ចុប្បន្ន កម្ពុជានៅតែមានអនុបាតខ្ពស់នៃសិស្ស-គ្រូ ជាងប្រទេសអាស៊ានដែលយកមកប្រៀបធៀប។[29] ចាប់ពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៨ កម្ពុជាមានអនុបាតខ្ពស់បំផុតនៃសិស្ស-គ្រូ សម្រាប់សាលាបឋមសិក្សា ហើយទោះបីជាអនុបាតសម្រាប់សាលាមធ្យមសិក្សាគឺទាបជាងក្តី ប៉ុន្តែវាតែខ្ពស់ដដែល។ លើសពីនេះ មានអតុល្យភាពយ៉ាងខ្លាំងក្នុងរបាយគ្រូបង្រៀនរវាងតំបន់ទីក្រុង និងតំបន់ជនបទ ក៏ដូចជាក្នុងចំណោមខេត្តនានា។ តំបន់ជនបទជាច្រើននៅតែប្រឈមនឹងការខ្វះគ្រូបង្រៀនជាខ្លាំង ហើយនេះជាបញ្ហារ៉ាំរ៉ៃ និងបន្តលេចឡើង។ នៅកម្រិតខេត្ត មានការប្រមូលផ្តុំគ្រូបង្រៀនក្នុងក្រុងភ្នំពេញ ខណៈដែលខេត្តភាគច្រើនផ្សេងទៀតប្រឈមនឹងការខ្វះគ្រូ។

**ក្នុងអត្ថបទផ្តោតពិសេសនេះ ជំពូកស្តីពីការអប់រំ នឹងសិក្សាស៊ីជម្រៅអំពីបញ្ហាសំខាន់ៗទាំងនេះ។** តាមរយៈការពិនិត្យមើលលទ្ធភាពទទួលការអប់រំ ចំណាយ លទ្ធផលសិក្សា និងប្រសិទ្ធភាពគ្រូបង្រៀន និងការសិក្សាកម្រិតមូលដ្ឋាន យើងខិតខំផ្តល់អនុសាសន៍គោលនយោបាយដែលអាចចាត់វិធានការបាន ដើម្បីពង្រឹងប្រព័ន្ធអប់រំរបស់កម្ពុជា។ ជំពូកនេះនឹងលើកឡើងពីចំណុចដូចតទៅ ៖ លទ្ធភាពទទួលបាន និងសមធម៌ក្នុងការអប់រំ ដោយផ្តោតសំខាន់លើការអប់រំកុមារតូច និងការសិក្សាកម្រិតបឋមសិក្សា និងការពិនិត្យមើលនិន្នាការនៃការចុះឈ្មោះចូលរៀន និងលទ្ធផលសិក្សា និងការពិភាក្សាអំពីយុទ្ធសាស្ត្របង្កើនលទ្ធភាពទទួលបានការអប់រំ និងគុណភាព និន្នាការក្នុងចំណាយលើវិស័យអប់រំ និងភាពពាក់ព័ន្ធនឹងលទ្ធផលសិក្សា និងភាពចាំបាច់នៃការផ្តោតសំខាន់លើការចំណាយកាន់តែប្រសើរ និងសារៈសំខាន់នៃប្រសិទ្ធភាពគ្រូបង្រៀន និងគោលនយោបាយសម្រាប់កែលម្អការជ្រើសរើស ការបណ្តុះបណ្តាល និងការដាក់ពង្រាយគ្រូ។ ផ្នែកចុងក្រោយនេះសង្ខេបលទ្ធផលរកឃើញសំខាន់ៗ និងផ្តល់អនុសាសន៍គោលនយោបាយដែលផ្តោតអាទិភាពលើការចំណាយកាន់តែប្រសើរ ការបង្កើនប្រសិទ្ធភាពគ្រូបង្រៀន និងការពង្រឹងការសិក្សាកម្រិតមូលដ្ឋាន។

**តាមរយៈការដោះស្រាយចំណុចសំខាន់ៗទាំងនេះនៅក្នុងប្រព័ន្ធអប់រំរបស់កម្ពុជា អត្ថបទផ្តោតពិសេសនេះមានគោលបំណងរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ ក្នុងការផ្តល់ការអប់រំប្រកបដោយគុណភាពសម្រាប់កុមារកម្ពុជាគ្រប់រូប។** ការវិនិយោគលើមូលធនមនុស្សតាមរយៈការអប់រំ មិនត្រឹមតែសំខាន់សម្រាប់សុខុមាលភាពបុគ្គលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសំខាន់សម្រាប់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍរយៈពេលវែងរបស់កម្ពុជាទៀតផង។ ក្នុងពេលដែលកម្ពុជាកំពុងដោះស្រាយបញ្ហាប្រឈមនានា ដូចជា វិសមភាពនៃវិភាជធនធាន ភាពមានកម្រិតនៃប្រសិទ្ធភាពគ្រូបង្រៀន និងគម្លាតក្នុងការសិក្សាកម្រិតមូលដ្ឋាននៅក្នុងបរិបទធំទូលាយនៃអាទិភាពចម្រូងចម្រាស់សម្រាប់ភាពមានកម្រិតនៃធនធាន និងសមត្ថភាពអនុវត្តន៍នៅកម្រិតប្រព័ន្ធ អ្វីដែលសំខាន់ជាងពេលណាៗទាំងអស់គឺការធានាថា ប្រព័ន្ធអប់រំមានភាពធន់ មានសមធម៌ និងឆ្លើយតបនឹងតម្រូវការរបស់អ្នកសិក្សា។

## លទ្ធភាពទទួលបាន និងសមធម៌ក្នុងការអប់រំ

**ការធានាលទ្ធភាពទទួលបានការអប់រំ និងការលើកកម្ពស់សមធម៌ ជាបាតគ្រឹះសម្រាប់ឱ្យប្រព័ន្ធអប់រំដំណើរការយ៉ាងរលូន។** ពីរទសវត្សរ៍កន្លងមកនេះ កម្ពុជាសម្រេចបានវឌ្ឍនភាពយ៉ាងច្រើនក្នុងការពង្រីកលទ្ធភាពទទួលបានការអប់រំ ជាពិសេសនៅកម្រិតបឋមសិក្សា។ ទោះជាយ៉ាងណា នៅតែមានភាពខុសគ្នានៃឱកាសអប់រំ និងលទ្ធផលសិក្សា នៅតាមតំបន់ និងក្នុងចំណោមក្រុមសង្គមកិច្ច-សេដ្ឋកិច្ច និងយេនឌ័រផ្សេងៗ។ ការដោះស្រាយវិសមធម៌ទាំងនេះ ជាកត្តាសំខាន់សម្រាប់ការធានាថា កុមារគ្រប់រូបមានឱកាសបានរៀនសូត្រ រីកចម្រើន និងសម្រេចបានសក្តានុពលពេញលេញរបស់ខ្លួន ដោយមិនគិតពីសាវតារ ឬកាលៈទេសៈរបស់ពួកគេ។

រូប ទ.១. **អត្រាពិតនៃការសិក្សា បែងចែកតាមកម្រិតសាលា**




*ប្រភព ៖* ការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយផ្អែកលើ CSES ឆ្នាំ ២០០៩ និងឆ្នាំ ២០១៩/២០

រូប ទ.២. **មូលហេតុនៃការមិនចុះឈ្មោះចូលរៀន**




29 Boy and Water ២០២៣។

**មួយទសវត្សរ៍កន្លងមកនេះ (២០០៩-១០/២០២០) មានការបោះជំហានសំខាន់ៗក្នុងការបង្កើនអត្រាចុះឈ្មោះចូលរៀននៅកម្រិតអប់រំផ្សេងៗ ជាពិសេសក្នុងការអប់រំមធ្យមសិក្សា។** អត្រាពិតនៃការសិក្សានៅបឋមសិក្សា កើន ៨ ភាគរយ គឺកើនដល់ ៩០ ភាគរយ។ ពិសេសជាងនេះគឺការចុះឈ្មោះចូលរៀននៅអនុវិទ្យាល័យ កើន ១៦ ភាគរយ គឺកើនដល់ ៤៧ ភាគរយ ខណៈដែលការចុះឈ្មោះនៅវិទ្យាល័យ កើន ១៣ ភាគរយ គឺកើនដល់ ៣០ ភាគរយ។ ភាពប្រសើរឡើងទាំងនេះបានបង្ហាញក្នុងរូប S.1 ដែលបង្ហាញពីវឌ្ឍនភាពជាវិជ្ជមានក្នុងលទ្ធភាពទទួលបាន និងការចូលរួមក្នុងការអប់រំ។ ទោះបីជាមានវឌ្ឍនភាព ប៉ុន្តែការចុះឈ្មោះចូលរៀននៅសាលាមធ្យមសិក្សា នៅមានកម្រិតទាបនៅឡើយ។

**របាំងហិរញ្ញវត្ថុជាឧបសគ្គចម្បងនៃការចុះឈ្មោះចូលរៀនក្នុងសាលាមធ្យមសិក្សានៅកម្ពុជា។** ៥៩ ភាគរយនៃកុមារគ្រប់អាយុចូលរៀននៅវិទ្យាល័យ និង ៣៨ ភាគរយនៃសិស្សអនុវិទ្យាល័យ លើកឡើងថា សម្ពាធសេដ្ឋកិច្ច ជាមូលហេតុនៃការមិនចូលរៀន (រូប S.2)។ ការលំបាកផ្នែកសេដ្ឋកិច្ច ជាកត្តាបន្ទាប់បន្សំដែលរាំងស្ទះដល់ការចុះឈ្មោះចូលរៀននៅបឋមសិក្សា។ ក្នុងចំណោមកុមារគ្រប់អាយុចូលរៀននៅបឋមសិក្សាដែលមិនបានចុះឈ្មោះចូលរៀន បុព្វហេតុធំៗរួមមានការរៀនខ្សោយ (៣៣ ភាគរយ) និងការមិនសូវចាប់អារម្មណ៍ជាទូទៅលើការអប់រំ (៣០ ភាគរយ)។ ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរនៃការលំបាកផ្នែកហិរញ្ញវត្ថុលើការអប់រំមធ្យមសិក្សា គួសបញ្ជាក់ពីភាពចាំបាច់នៃកិច្ចអន្តរាគមន៍ចំគោលដៅដើម្បីកាត់បន្ថយបន្ទុកសេដ្ឋកិច្ចលើគ្រួសារ ដោយធានាថា កុមារអាចបន្តការសិក្សាក្រោយកម្រិតបឋមសិក្សា។

**អង្កេតសង្គមកិច្ច-សេដ្ឋកិច្ចកម្ពុជា (CSES) បានរំលេចភាពខុសគ្នាយ៉ាងខ្លាំងនៃអត្រាចុះឈ្មោះចូលរៀនរវាងតំបន់ទីក្រុង និងតំបន់ជនបទ ជាពិសេសក្នុងការអប់រំមធ្យមសិក្សា។** ក្នុងឆ្នាំ ២០១៩ តំបន់ទីក្រុងមានអត្រាពិតនៃការសិក្សា ៩២ ភាគរយ

**រូប S.៣. អត្រាពិតនៃការសិក្សា តាមយេនឌ័រ ទីតាំង និងស្ថានភាពសង្គមកិច្ច-សេដ្ឋកិច្ច បែងចែកតាមកម្រិតសាលា ឆ្នាំ ២០១៩**




*ប្រភព ៖ ការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយផ្អែកលើ CSES ២០១៩/២០*

**រូប S.៤. អត្រាពិតនៃការសិក្សា បែងចែកតាមតំបន់ ឆ្នាំ ២០០៩-១៩**




*ប្រភព ៖ ការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយផ្អែកលើ CSES ឆ្នាំ ២០០៩ និងឆ្នាំ ២០១៩/២០*

សម្រាប់បឋមសិក្សា គឺខ្ពស់ជាងបន្តិចបើធៀបនឹងតំបន់ជនបទ ដែលមានអត្រាពិតនៃការសិក្សា ៨៩ ភាគរយសម្រាប់បឋមសិក្សា (រូប S.3)។ ភាពខុសគ្នារវាងតំបន់ទីក្រុង និងតំបន់ជនបទនេះ រីកធំនៅកម្រិតឧត្តមសិក្សា។ សម្រាប់ការអប់រំមធ្យមសិក្សាបឋមភូមិ អត្រាពិតនៃការសិក្សាក្នុងតំបន់ទីក្រុងគឺ ៥២ ភាគរយ ធៀបនឹងអត្រា ៤៥ ភាគរយនៅតំបន់ជនបទ មានន័យថា ខុសគ្នា ៧ ភាគរយ។ ភាពខុសគ្នានេះកាន់តែរីកធំនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ដែលកុមារនៅទីក្រុងមានអត្រាចុះឈ្មោះចូលរៀនខ្ពស់ជាងកុមារនៅជនបទ ៦០ ភាគរយ។ នេះជាគម្លាតដ៏ធំក្នុងលទ្ធភាពទទួលបានការអប់រំក្រោយបឋមសិក្សា។

**ខណៈដែលនៅតែមានភាពខុសគ្នាខ្លាំងក្នុងអត្រាចុះឈ្មោះចូលរៀនសាលាមធ្យមសិក្សា រវាងតំបន់ទីក្រុង និងតំបន់ជនបទ មានការថយចុះគួរឱ្យកត់សម្គាល់នៃគម្លាតទាំងនេះ ក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ។** ឧទាហរណ៍ ក្នុងឆ្នាំ ២០១៩ គម្លាតក្នុងការចុះឈ្មោះចូលរៀននៅអនុវិទ្យាល័យ រវាងតំបន់ទីក្រុង និងតំបន់ជនបទ គឺ ៦ ភាគរយ។ នេះជាការថយចុះគួរឱ្យកត់សម្គាល់ពីគម្លាតរហូតដល់ ២៣ ភាគរយ កាលពីឆ្នាំ ២០០៩ (រូប S.4)។ ភាពប្រសើរឡើងនេះគូសបញ្ជាក់ពីវឌ្ឍនភាពនៃការលុបបំបាត់គម្លាតនៃការអប់រំនៅតាមតំបន់នានា។

**ស្ថានភាពសង្គមកិច្ច-សេដ្ឋកិច្ច ក៏ដើរតួនាទីសំខាន់ក្នុងការកំណត់ឱកាសអប់រំរបស់កុមារផងដែរ។** កុមារមកពីគ្រួសារក្រីក្របំផុត ច្រើនតែមិនសូវបានចុះឈ្មោះចូលរៀន បើធៀបនឹងកុមារមកពីគ្រួសារស្តុកស្តម្ភបំផុត។ យោងតាមទិន្នន័យ SCES ឆ្នាំ ២០១៩ អត្រាពិតនៃការសិក្សាសម្រាប់ការអប់រំបឋមសិក្សាគឺ ៨៥ ភាគរយ ក្នុងចំណោមកុមារមកពីបញ្ចភាគគ្រួសារក្រីក្របំផុត ធៀបនឹងអត្រា ៩៥ ភាគរយសម្រាប់កុមារមកពីបញ្ចភាគគ្រួសារស្តុកស្តម្ភបំផុត(រូប S.5)។ ភាពខុសគ្នាទាំងនេះរីកកាន់តែធំ នៅកម្រិតអប់រំមធ្យមសិក្សា ដែលគម្លាតនៃការចុះឈ្មោះចូលរៀនកើនដល់ ៣៧ ភាគរយ នៅអនុវិទ្យាល័យ និងកើនដល់ ៤៦ ភាគរយនៅវិទ្យាល័យ។ លើសពីនេះ នៅតែមានភាពខុសគ្នានៃអត្រាចុះឈ្មោះចូលរៀនបឋមសិក្សា និងមធ្យមសិក្សា រវាងក្រុមសិស្សមកពីគ្រួសារក្រីក្របំផុត និងក្រុមសិស្សមកពីគ្រួសារ

**រូប S.៥. អត្រាពិតនៃការសិក្សា បែងចែកតាមបញ្ចភាគទ្រព្យសម្បត្តិ (លើបំផុត និងក្រោមបំផុត) ឆ្នាំ ២០០៩-១៩**




*ប្រភព ៖* ការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយផ្អែកតាម CSES ឆ្នាំ ២០០៩ និង CSES ឆ្នាំ ២០១៩/២០

**រូប S.៦. អត្រាពិតនៃការសិក្សា បែងចែកតាមយេនឌ័រ ឆ្នាំ ២០០៩-១៩**




*ប្រភព ៖* ការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយផ្អែកលើ CSES ឆ្នាំ ២០០៩ និង CSES ឆ្នាំ ២០១៩/២០

ស្តុកស្តម្ភបំផុត ក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ។ គម្លាតនៃលទ្ធភាពទទួលបានការអប់រំដោយផ្អែកលើទ្រព្យសម្បត្តិគ្រួសារ បានជំរុញឱ្យមានវដ្តតជំនាន់នៃភាពក្រីក្រ និងវិសមភាព ព្រោះកុមារដែលមានស្ថានភាពជួបការលំបាក ច្រើនតែមិនសូវទទួលបានបំណិន និងចំណេះដឹងចាំបាច់ដើម្បីរំដោះខ្លួនចេញពីភាពក្រីក្រ និងសម្រេចស្ថានភាពល្អប្រសើរក្នុងសង្គម (upward social mobility)។

**ខណៈដែលកម្ពុជាសម្រេចបានសមភាពយេនឌ័រ ក្នុងការអប់រំបឋមសិក្សា មានបញ្ហាប្រឈមថ្មីៗនៅឧត្តមសិក្សា គឺនិស្សិតប្រុសរៀនខ្សោយជាងនិស្សិតស្រី។** ក្នុងឆ្នាំ ២០១៩ អត្រាចុះឈ្មោះចូលរៀនរបស់សិស្សស្រីនៅកម្រិតមធ្យមសិក្សាបឋមភូមិគឺ ៥២ ភាគរយ ធៀបនឹងអត្រា ៤៣ ភាគរយសម្រាប់សិស្សប្រុស ស្មើនឹងគម្លាត ៩ ភាគរយ។ គម្លាតនេះរីកកាន់តែធំនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ដែលអត្រាចុះឈ្មោះចូលរៀនរបស់សិស្សស្រីគឺ ៣៥ ភាគរយ ចំណែកអត្រាចុះឈ្មោះចូលរៀនរបស់សិស្សប្រុសគឺ ២៦ ភាគរយ ស្មើនឹងគម្លាត ៩ ភាគរយ (រូប S.6)។ ផ្អែកតាមទិន្នន័យសូចនាករអភិវឌ្ឍន៍ពិភពលោក ឆ្នាំ ២០២២ មានវិសមភាពយេនឌ័រគួរឱ្យកត់សម្គាល់ក្នុងអត្រាបញ្ចប់ការសិក្សា ដោយអត្រាបញ្ចប់ការសិក្សាសម្រាប់សិស្សស្រី គឺ ៦៧ ភាគរយ ជាអត្រាលើសសិស្សប្រុសដែលមានត្រឹមតែ ៥៧ ភាគរយ។ ទិន្នន័យទាំងនេះបញ្ជាក់ពីភាពបញ្ច្រាស់នៃគម្លាតយេនឌ័របែបប្រពៃណី ដែលសិស្សប្រុសមានវឌ្ឍនភាពតិចជាងសិស្សស្រី ទាំងក្នុងអត្រាចុះឈ្មោះចូលរៀន និងអត្រាបញ្ចប់ការសិក្សា។

**ការអប់រំកុមារតូច (ECE) និងការអប់រំនៅបឋមសិក្សា គឺជាមូលដ្ឋានគ្រឹះសម្រាប់ការរៀនសូត្រពេញមួយជីវិត និងការអភិវឌ្ឍរបស់កុមារ។** ការវិនិយោគលើដំណាក់កាលអប់រំសំខាន់ៗទាំងនេះ នឹងផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនពេញមួយជីវិតសម្រាប់បុគ្គល និងសង្គមកិច្ច។ ប៉ុន្តែនៅកម្ពុជា វឌ្ឍនភាពនៃការពង្រីកលទ្ធភាពទទួលបានការអប់រំកុមារតូច និងការអប់រំបឋមសិក្សា ត្រូវបានបង្អាក់ដោយកត្តា ដូចជា ធនធានមានកម្រិត គុណភាពមិនស្មើគ្នា និងផលប៉ះពាល់នៃវិបត្តិកូវីដ-១៩។

**ទោះជាមានការកត់សម្គាល់ពីសារៈសំខាន់នៃការអប់រំកុមារតូចក៏ដោយ ប៉ុន្តែអត្រាចុះឈ្មោះចូលរៀននៅកម្ពុជាក្នុងប៉ុន្មានឆ្នាំនេះ មានការថយចុះ។** ចំណែកនៃកុមារអាហុ ៣-៥ ឆ្នាំដែលបានចុះឈ្មោះចូលរួមក្នុងកម្មវិធីអប់រំកុមារតូច ថយពី ៤៣ ភាគរយក្នុងឆ្នាំ ២០១៧ មកត្រឹម ៣៤ ភាគរយក្នុងឆ្នាំ ២០២១ ដោយការថយចុះខ្លាំងបំផុតគឺក្នុងចំណោមកុមារអាយុ ៣ ឆ្នាំ ដែលអត្រាចុះឈ្មោះចូលរៀនថយពី ២២ ភាគរយ មកត្រឹមតែ ១២ ភាគរយក្នុងអំឡុងពេលដូចគ្នា (រូប S.7)។ ការថយចុះនេះ អាចបណ្តាលមកពីកត្តារួមផ្សំគ្នា ដូចជា ជំងឺកូវីដ-១៩ កង្វះលទ្ធភាពទទួលបានកម្មវិធីអប់រំកុមារតូចដែលមានគុណភាព ជាពិសេសនៅតំបន់ជនបទ ការយល់ដឹងទាបរបស់មាតាបិតាសិស្សស្តីពីតម្លៃនៃការអប់រំកុមារតូច និងបញ្ហាហិរញ្ញវត្ថុក្នុងគ្រួសារ។

30 ធនាគារពិភពលោក ២០២៤e

**រូប S.៧. អត្រាចុះឈ្មោះចូលរៀនរបស់កុមារតូច បែងចែកតាមអាយុ**




*ប្រភព ៖ ធនាគារពិភពលោក ២០២៤f*

**ជំងឺកូវីដ-១៩ បានពង្រីកបញ្ហាប្រឈមក្នុងការអប់រំកុមារតូចតាមរយៈការអូសបន្លាយពេលបិទសាលារៀន និងការលំបាកផ្នែកសេដ្ឋកិច្ចដែលបង្កផលប៉ះពាល់ធ្ងន់ធ្ងរលើកុមារតូចមកពីគ្រួសារជួបការលំបាក។** ដើម្បីដោះស្រាយបញ្ហាទាំងនេះ និងបង្កើនអត្រាចុះឈ្មោះចូលរៀនក្នុងការអប់រំកុមារតូច កម្ពុជាត្រូវផ្តោតអាទិភាពលើការវិនិយោគផ្នែកហេដ្ឋារចនាសម្ព័ន្ធ ការបណ្តុះបណ្តាលគ្រូ និងសម្ភារសិក្សា ទន្ទឹមនឹងការអភិវឌ្ឍក្របខណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយមួយដែលសង្កត់ធ្ងន់លើសមធម៌ គុណភាព និងនិរន្តរភាពក្នុងការផ្តល់សេវាការអប់រំកុមារតូច។

## ការចំណាយលើការអប់រំ និងលទ្ធផលសិក្សា

**មួយទសវត្សរ៍កន្លងមកនេះ កម្ពុជាបានបង្កើនការនិយោគលើការអប់រំជាបន្តបន្ទាប់ ព្រោះកម្ពុជាកត់សម្គាល់តួនាទីដ៏សំខាន់នៃការអប់រំក្នុងការទ្រទ្រង់ការអភិវឌ្ឍមូលធនមនុស្ស និងការជំរុញកំណើនសេដ្ឋកិច្ច។** ថ្វីបើមានការបង្កើនចំណាយយ៉ាងច្រើនក្តី ប៉ុន្តែកម្ពុជានៅតែប្រឈមនឹងបញ្ហាជាបន្តបន្ទាប់ក្នុងការបង្កើនលទ្ធផលសិក្សា ទាំងសម្រាប់កម្រិតបឋមសិក្សា និងកម្រិតមធ្យមសិក្សា។

**ជំពូក ២ ស្តីពីការអប់រំ[30] នៃការត្រួតពិនិត្យហិរញ្ញវត្ថុសម្រាប់វិស័យអប់រំនៅកម្ពុជា (Cambodia Public Finance Review) គូសបញ្ជាក់ពីការកើនឡើងនៃចំណាយលើការអប់រំគិតជាភាគរយនៃ ផសស គឺកើនពី ២,០ ភាគរយក្នុងឆ្នាំ ២០១១ ដល់ ៣,០ ភាគរយ ក្នុងឆ្នាំ ២០២១ (រូប S.8)។** កំណើននេះបណ្តាលមកពីការដំឡើងប្រាក់ខែសម្រាប់កម្លាំងអប់រំ ដែលកើន ៦ ភាគរយនៅចន្លោះឆ្នាំ ២០១៤ និងឆ្នាំ ២០២០ គឺចំនួនកម្លាំងអប់រំកើនដល់ ១១៤.១៧០ នាក់។ បច្ចុប្បន្ននេះ ចំណាយប្រាក់ឈ្នួលមានចំណែកជិត ៨០ ភាគរយនៃចំណាយសរុបលើការអប់រំ (រូប S.9)។

**ត្បិតការរៀនសូត្រចេះតែបង្គរ នៅពេលដែលកុមារខ្វះបំណិនមូលដ្ឋាន ពួកគេនឹងមានការលំបាកក្នុងការទាញប្រយោជន៍ដោយប្រសិទ្ធភាពពីឱកាសរៀនសូត្រនៅពេលក្រោយ និងការសម្រេចបានការអប់រំឧត្តមសិក្សា និងបំណិនបច្ចេកទេស ដូចជាភាពស្ទាត់ជំនាញផ្នែកឌីជីថល ដែលកាន់តែមានភាពចាំបាច់នៅក្នុងពិភពលោកសម័យទំនើប។** មានន័យថា ពួកគេនឹងបាត់បង់អត្ថប្រយោជន៍ និងឱកាសសេដ្ឋកិច្ចនៅក្នុងជីវិត ខណៈដែលជារួមកម្ពុជានឹងបន្តប្រឈមនឹងរបាំងក្នុងការទទួលបានកម្លាំងពលកម្មជំនាញ និងការបង្កើនផលិតភាពការងារ ដែលសុទ្ធសឹងជាកត្តាសំខាន់ៗសម្រាប់អន្តរកាលសេដ្ឋកិច្ច។ ជារួម ដើម្បីឱ្យកម្ពុជាអភិវឌ្ឍកម្លាំងពលកម្មដែលមានជំនាញកម្រិតខ្ពស់ កម្ពុជាត្រូវឆាប់ចាប់ផ្តើមកសាងបំណិនមូលដ្ឋាន នៅសាលាមត្តេយ្យសិក្សា និងសាលាបឋមសិក្សា។

**ទោះបីជាមានការកើនឡើងគួរឱ្យកត់សម្គាល់នៃចំណាយលើការអប់រំមែន ប៉ុន្តែលទ្ធផលសិក្សានៅកម្ពុជា នៅតែបង្កការព្រួយបារម្ភ។** សិស្សបឋមសិក្សារៀនខ្សោយទាំងផ្នែកគណិតវិទ្យា និងអំណាន បើធៀបនឹងសិស្សនៅបណ្តាប្រទេសអាស៊ានដែលប្រហាក់ប្រហែល។ យោងតាមរបាយការណ៍ម៉ាទ្រីសការសិក្សាបឋមសិក្សានៅអាស៊ីអាគ្នេយ៍ ( SEA-PLM) ឆ្នាំ ២០១៩ មានកុមារកម្ពុជាតែ ១៩ ភាគរយប៉ុណ្ណោះដែលមានភាពស្ទាត់ជំនាញផ្នែកគណិតវិទ្យា។ នេះជាអត្រាទាបខ្លាំងជាងមធ្យមភាគក្នុងតំបន់ដែលមានរហូតដល់ ៣៥ ភាគរយ (រូប S.10, ផ្ទាំង A)។ ស្រដៀងគ្នានេះ កម្ពុជាមានវឌ្ឍនភាពទាបក្នុងភាពស្ទាត់ជំនាញផ្នែកអំណាន ដោយមានកុមារតែ ១១ ភាគរយប៉ុណ្ណោះដែលអានស្ទាត់។ នេះជាអត្រាទាបខ្លាំងជាមធ្យមភាគក្នុងតំបន់ដែលមានរហូតដល់ ២៩ ភាគរយ (រូប S.10, ផ្ទាំង B)។

**សមិទ្ធកម្មទាបក្នុងបំណិនមូលដ្ឋាននេះ បាននាំឱ្យខ្វះវឌ្ឍនភាពនិងការបញ្ចប់ការសិក្សាក្នុងការអប់រំមធ្យមសិក្សា។** ចំណែកនៃកុមារដែលបានបញ្ចប់អនុវិទ្យាល័យ (ជាទូទៅ គឺកុមារដែលមានអាយុ ១២-១៥ ឆ្នាំ) ស្ថិតក្នុងចំណោមអត្រាទាបបំផុតនៅកម្ពុជា បើធៀបនឹងប្រទេសប្រហាក់ប្រហែលគ្នា។[31]

**នៅកម្រិតមធ្យមសិក្សា កម្ពុជានៅតែមានវឌ្ឍនភាពតិចជាងប្រទេសដែលយកមកប្រៀបធៀបក្នុងតំបន់ និងប្រឈមនឹងបញ្ហាក្នុងការសម្រេចបានលទ្ធផលសិក្សាគួរជាទីគាប់ប្រសើរ។**

**រូប S.៨. ចំណាយសាធារណៈលើការអប់រំ (% នៃ ផសស), ២០១១-២១**




**រូប S.៩. ចំណាយរបស់ក្រសួងអប់រំ យុវជន និងកីឡា បែងចែកជាប្រភេទ (% នៃចំណាយសរុបរបស់ក្រសួង), ២០១១-២១**




*ប្រភព ៖ ធនាគារពិភពលោក ២០២៤e*

**រូប S.១០. ចំណែកនៃសិស្សថ្នាក់ទី ៥ ដែលស្ទាត់ខាងគណិតវិទ្យា និងអំណាន, SEA-PLM ២០១៩**




*ប្រភព ៖ ការប៉ាន់ស្មានរបស់ធនាគារពិភពលោក ដោយផ្អែកលើ SEA-PLM ២០១៩*

31 ធនាគារពិភពលោក ២០២៤e

ទោះបីជាសម្រេចបានវឌ្ឍនភាពខ្លះៗក្នុងពិន្ទុ PISA នៅអំឡុងឆ្នាំ ២០១៧-២០២០ មែន ប៉ុន្តែកម្ពុជានៅតែស្ថិតក្នុងចំណោមប្រទេសដែលមានសមិទ្ធកម្មទាបបំផុតក្នុងការវាយតម្លៃ PISA ចុងក្រោយបង្អស់ (២០២២) គឺកម្ពុជាមានចំណាត់ថ្នាក់ទាបបំផុតក្នុងមុខវិជ្ជាទាំង ៣ ដែលបានធ្វើតេស្តៈ អំណាន គណិតវិទ្យា និងវិទ្យាសាស្ត្រ។ ការណ៍នេះធ្វើឱ្យកម្ពុជាមានវឌ្ឍនភាពតិចជាងប្រទេសដែលយកមកប្រៀបធៀប ដូចជា ក្វាតេម៉ាឡា និង ហ្វីលីពីន ដែលបានចូលរួមក្នុងការវាយតម្លៃនេះដែរ។[32]

**បន្ថែមពីលើក្តីកង្វល់ទាំងនេះគឺគម្រាតលទ្ធផលការសិក្សារបស់សិស្ស ដែលគេសង្កេតឃើញមានភាពខុសគ្នាទៅតាមស្ថានភាពជីវភាព យេនឌ័រ និងភូមិសាស្ត្រ រឹតតែធ្វើឲ្យបញ្ហាវិសមភាពការអប់រំកាន់តែធ្ងន់ធ្ងរ។** របាយការណ៍ម៉ាទ្រីសការសិក្សាបឋមសិក្សានៅអាស៊ីអាគ្នេយ៍ (SEA-PLM) ឆ្នាំ ២០១៩ បង្ហាញពីគម្លាតលទ្ធផលការសិក្សារបស់សិស្សតាមស្ថានភាពជីវភាពគួរឲ្យព្រួយបារម្ភ។ ឧទាហរណ៍ កម្រិតភាពស្ទាត់ជំនាញផ្នែកអំណាន ស្មើនឹង ២៥ ភាគរយ សម្រាប់កុមារមកពីគ្រួសារធូរធា ដែលខុសស្រលះពីកុមារមកពីគ្រួសារក្រីក្របំផុតដែលមានកម្រិតភាពស្ទាត់ជំនាញផ្នែកអំណានត្រឹមតែ ៥ ភាគរយ (រូប S.11)។ ស្រដៀងគ្នានេះ ៣៩ ភាគរយនៃសិស្សថ្នាក់ទី៥មកពីគ្រួសារធូរធា មានភាពស្ទាត់ជំនាញផ្នែកគណិតវិទ្យា ហើយមានតែ៩ ភាគរយប៉ុណ្ណោះមកពីគ្រួសារមានជីវភាពខ្វះខាតដែលមានភាពស្ទាត់ជំនាញផ្នែកគណិតវិទ្យាកម្រិតនេះ។ គម្រាតលទ្ធផលការសិក្សារវាងសិស្សមានស្ថានភាពជីវភាពខុសគ្នាបែបនេះ ត្រូវបានគេសង្កេតឃើញច្រើននៅកម្ពុជា ជាងបណ្តាប្រទេសផ្សេងទៀតដែលចូលរួមធ្វើការវាយតម្លៃ (SEA-PLM)។[33]

**លើសពីនេះ របាយការណ៍ម៉ាទ្រីសការសិក្សាបឋមសិក្សានៅអាស៊ីអាគ្នេយ៍ (SEA-PLM) ឆ្នាំ ២០១៩ គូសបញ្ជាក់នូវគម្លាតភាពស្ទាត់ជំនាញផ្នែកអំណានរវាងយេនឌ័រ ដោយសិស្សស្រីថ្នាក់ទី៥ មានលទ្ធផលល្អជាងសិស្សប្រុសៈ ១៤ ភាគរយនៃសិស្សស្រីមានភាពស្ទាត់ជំនាញផ្នែកអំណាន ធៀបនឹង ៨ ភាគរយនៃសិស្សប្រុស។** ទោះជាយ៉ាងណា ភាពស្ទាត់ជំនាញផ្នែកគណិតវិទ្យាមានគម្លាតតិចតួចរវាងសិស្សប្រុស និងសិស្សស្រី។[34] ក្នុងការវាយតម្លៃ PISA ឆ្នាំ ២០២២ បង្ហាញថា សិស្សរៀននៅសាលាតាមទីក្រុងមានលទ្ធផលល្អលើផ្នែកអំណាន គណិតវិទ្យា និងវិទ្យាសាស្ត្រ ជាងសិស្សរៀននៅសាលាតាមជនបទ។ ទោះជាយ៉ាងណា គម្លាតលទ្ធផលសិក្សារវាងសិស្សទីក្រុង-ជនបទនេះ មានការរួមតូចមកវិញបើប្រៀបធៀបទៅនឹងលទ្ធផលនៃការវាយតម្លៃ PISA-D ឆ្នាំ ២០១៧។[35]

**ជំងឺរាតត្បាតកូវីដ-១៩ បានធ្វើឲ្យឧបសគ្គខាងលើទាំងនេះកាន់តែធ្ងន់ធ្ងរ ហើយគូសបញ្ជាក់ពីការចំណាយយុទ្ធសាស្ត្រលើវិស័យអប់រំជាបន្ទាន់។** ការបិទសាលាដែលបន្តអូសបន្លាយ និងការជ្រើសយកវិធីសាស្ត្ររៀនពីចម្ងាយបានធ្វើឲ្យការសិក្សាមានការធ្លាក់ចុះគួរឲ្យកត់សម្គាល់ ជាពិសេសសម្រាប់សិស្សដែលខ្វះលទ្ធភាព។ ការសិក្សាមួយ[36] ប៉ាន់ស្មានថា ចំនួនឆ្នាំដែលមនុស្សម្នាក់បានរៀននៅសាលា (កែសម្រួលផ្អែកលើការរៀន) (learning-adjusted years of schooling) នៅ

**រូប S.១១. ភាគរយនៃសិស្សថ្នាក់ទី ៥ ដែលស្ទាត់ជំនាញផ្នែកអំណាន និងគណិតវិទ្យា តាមការបង្ហាញក្នុងអង្កេតសង្គមកិច្ច-សេដ្ឋកិច្ច (SES)**




*ប្រភព ៖* SEA-PLM ២០១៩

32 OECD ២០២២
33 SEA-PLM 2019.
34 SEA-PLM 2019.
35 OECD 2022.
36 Azevedo, Hasan, and Goldemberg 2022.

**រូប S១២. ពិន្ទុតេស្តសិស្សនៅថ្នាក់ជាតិ (រង្វាយតម្លៃការសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី ៦), ២០១៣-២១**




*ប្រភព ៖ Bhatta et al. ២០២៤*

កម្ពុជា អាចថយចុះពី ១,៣ ទៅ ២,៣ ឆ្នាំដោយសារជំងឺរាតត្បាតកូវីដ-១៩។

**លទ្ធផលនៃការវាយតម្លៃថ្នាក់ជាតិស្តីពីការរៀន (NLA) គឺជាសក្ខីកម្មនៃផលប៉ះពាល់របស់ជំងឺរាតត្បាតកូវីដ-១៩ មកលើលទ្ធផលសិក្សារបស់សិស្ស។** មុនពេលជំងឺរាតត្បាតកូវីដ-១៩ លទ្ធផលសិក្សាលើមុខវិជ្ជាគណិតវិទ្យា និងភាសាខ្មែររបស់សិស្សថ្នាក់ទី៦ មាននិន្នាការវិជ្ជមាន។ ទោះជាយ៉ាងណា និន្នាការនេះបានដើរបញ្ច្រាស់ព្រោះជំងឺរាតត្បាតកូវីដ-១៩ ដោយកម្រិតពិន្ទុរបស់សិស្សបានធ្លាក់ចុះ ៦ ភាគរយលើមុខវិជ្ជាគណិតវិទ្យា និង ៨ ភាគរយលើមុខវិជ្ជាភាសាខ្មែរ នៅចន្លោះឆ្នាំ២០១៦-២០២១ (រូប S.12)។ ការធ្លាក់ចុះនេះ ត្រូវបានគេសង្កេតឃើញកើតមានលើសិស្សទាំងពីរភេទ នៅគ្រប់តំបន់ និងដែលមានស្ថានភាពជីវភាពខុសៗគ្នា។[37] ស្រដៀងគ្នានេះ ចំណែកនៃសិស្សថ្នាក់ទី៨ ដែលមានលទ្ធផលសិក្សាក្រោមកម្រិតមូលដ្ឋានបានកើនឡើងសម្រាប់មុខវិជ្ជាគណិតវិទ្យា និងរូបវិទ្យានៅចន្លោះឆ្នាំ ២០១៧-២០២២។[38]

## ប្រសិទ្ធភាពគ្រូបង្រៀន

**ការបង្កើនគុណភាពនៃការបង្រៀន គឺជាបុរេលក្ខខណ្ឌមួយសម្រាប់ការធានាលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព និងការបង្កើនលទ្ធផលសិក្សា[39]។** កម្ពុជាកំពុងប្រឈមនឹងបញ្ហាធំៗក្នុងការធានាការផ្គត់ផ្គង់គ្រូបង្រៀនដែលមានការបណ្តុះបណ្តាលល្អ និងស្ទាត់ជំនាញ និងការដាក់ពង្រាយគ្រូបង្រៀនប្រកបដោយសមធម៌នៅទូទាំងប្រទេស។ ការដោះស្រាយបញ្ហាប្រឈមទាំងនេះ ទាមទារអភិក្រមគ្រប់ជ្រុងជ្រោយមួយសម្រាប់ការគ្រប់គ្រងគ្រូបង្រៀន ដែលរួមបញ្ចូលការជ្រើសរើស ការបណ្តុះបណ្តាល ការដាក់ពង្រាយ និងការអភិវឌ្ឍវិជ្ជាជីវៈជាបន្តបន្ទាប់។

**ទោះបីជាកម្ពុជាមានសមាមាត្រគ្រូបង្រៀនទាបមែន (បុគ្គលិកអប់រំ ០,៨ នាក់ក្នុងប្រជាជន ១០០ នាក់) ប៉ុន្តែកម្ពុជាចំណាយថវិកាអប់រំច្រើនលើប្រាក់ខែបុគ្គលិកអប់រំ គឺ ៨០ ភាគរយ ធៀបនឹងអត្រា ៦៩ ភាគរយសម្រាប់ប្រទេសមានប្រាក់ចំណូលទាប។[40]** ខណៈដែលការផ្តល់ប្រាក់ខែសមរម្យជាកត្តាសំខាន់សម្រាប់ការទាក់ទាញ និងភាពគង់វង្សនៃគ្រូបង្រៀនដែលមានគុណវុឌ្ឍិ ចំណាយខ្ពស់លើប្រាក់ឈ្នួលនឹងបង្កការព្រួយបារម្ភលើនិរន្តរភាពនៃហិរញ្ញប្បទានវិស័យអប់រំ និងកង្វះភាពពាក់ព័ន្ធគ្នារវាងការបង្កើនចំណាយ និងភាពប្រសើរឡើងនៃលទ្ធផលសិក្សា។

**ក្នុងចំណោមចំណុចសំខាន់ៗបំផុត មានចំណុចសំខាន់មួយដែលទាមទារការយកចិត្តទុកដាក់ គឺ ប្រព័ន្ធវិក្រឹតការគ្រូបង្រៀន។** ទោះបីជាធ្វើឡើងក្រោមចេតនាល្អបំផុតមែន ប៉ុន្តែនៅកម្ពុជា កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនជាច្រើនបានការលំបាកក្នុងការត្រៀមខ្លួនគរុសិស្សនិស្សិត ឱ្យបានពេញលេញសម្រាប់ការបង្រៀនក្នុងថ្នាក់ជាក់ស្តែង។បញ្ហាទូទៅមួយគឺកង្វះការសិក្សាស្វែងយល់ពីគរុកោសល្យបែបសិស្សមជ្ឈមណ្ឌលនៅក្នុងដំណើរការបណ្តុះបណ្តាល។ ជាញឹកញាប់ គរុសិស្សនិស្សិតដែលចូលរួមក្នុងកម្មវិធីទាំងនេះ រៀនសូត្រតាមបែបទន្ទេញឱ្យចាំ (rote learning) និងគោលវិធីគ្រូមជ្ឈមណ្ឌល (teacher-centered) នៅក្នុងដំណើរការអប់រំទាំងមូល។[41] ជាលទ្ធផល ពួកគេអាចមានការលំបាកក្នុងការអនុវត្តតាមគោលវិធីបង្រៀនបែបអន្តរកម្មដែលកាន់តែទំនើប ក្នុងកម្មវិធីសិក្សាថ្មី។ វគ្គសិក្សាទាំងនេះ ច្រើនតែមានទម្រង់ជាបាឋកថា និងការកត់ចម្លងពីក្តារខៀន មានលក្ខណៈទ្រឹស្តីខ្លាំង និងមិនសូវមានការអនុវត្តទ្រឹស្តីនៅក្នុងបន្ទប់រៀន។[42]

**ក្នុងកម្មសិក្សាបង្រៀន (teaching practicum) ដែលជាវិធីគន្លឹះមួយសម្រាប់ឱ្យបេក្ខជនអនុវត្តជំនាញបង្រៀន កម្មសិក្សាការីប្រហែលជាមិនសង្កេតមើលការអនុវត្តដែលមានប្រសិទ្ធភាពទៅតាមម៉ូឌែលនោះទេ ព្រោះវិក្រឹតការដោយគ្រូណែនាំ (in-service teaching of mentor teachers) ច្រើនតែខ្វះគោលវិធីគរុកោសល្យបែបសិស្សមជ្ឈមណ្ឌល។** ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើនរយៈពេលចុះកម្មសិក្សាបង្រៀនពី ១៤ សប្តាហ៍ដល់ ២២ សប្តាហ៍ ក្នុងកម្មវិធីអប់រំគ្រូបង្រៀន ឆ្នាំ ទី ៤។ ទោះជាយ៉ាងណា នៅតែមានបញ្ហាប្រឈម ដូចជាកង្វះការបណ្តុះបណ្តាលសម្រាប់គ្រូសហការ (cooperating teachers) គម្លាតក្នុងទំនាក់ទំនងរវាងមហាវិទ្យាល័យគរុកោសល្យ (teacher education college) និងសាលាដែលត្រូវចុះកម្មសិក្សាបង្រៀន

37 Bhatta et al. 2022.
38 World Bank 2024e.
39 ធនាគារពិភពលោក ២០២៣b
40 មូលនិធិរូបិយវត្ថុអន្តរជាតិ ២០១៦
41 Bremner, Sakata, and Cameron ២០២៣
42 Lewin ២០០៤

និងកង្វះឱកាសសម្រាប់ការចុះសង្កេតមើលការបង្រៀន និងយោបល់ត្រឡប់។[43] កង្វះការគាំទ្រ និងយោបល់ត្រឡប់ជាបន្តបន្ទាប់ក្នុងពេលកម្មសិក្សាបង្រៀន ជាកត្តានាំឱ្យបាត់ភាពពាក់ព័ន្ធ ដែលធ្វើឱ្យប៉ះពាល់ដល់សក្តានុពលនៃការធ្វើឱ្យបទពិសោធន៍ទាំងនេះបង្កើនបំណិនបង្រៀនប្រកបដោយប្រសិទ្ធភាព។

**ក្រៅពីបញ្ហាប្រឈមទាំងនេះ គឺភាពមិនបន្សុីគ្នារវាងកម្មវិធីសិក្សាដែលបានបង្រៀនក្នុងកម្មវិធីវិក្រឹតការ និងកម្មវិធីសិក្សាជាក់ស្តែងដែលប្រើប្រាស់ក្នុងសាលា។** ថ្មីៗនេះ កំណែទម្រង់កម្មវិធីសិក្សាក្នុងសាលារៀន មិនមានការសម្របសម្រួលបានល្អជាមួយគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនឡើយ (teacher training institutions)។ ការណ៍នេះធ្វើឱ្យគ្មានភាពបន្សុីគ្នារវាងអ្វីដែលគរុសិស្ស-និស្សិតត្រូវបានបង្រៀន និងខ្លឹមសារដែលពួកគេនឹងត្រូវបង្រៀនជាក់ស្តែងនៅក្នុងបន្ទប់រៀននាពេលអនាគត។

**ដើម្បីដោះស្រាយគម្លាតទាំងនេះ ចាំបាច់ត្រូវបានការកែសម្រួលគ្រប់ជ្រុងជ្រោយលើកម្មវិធីវិក្រឹតការគ្រូបង្រៀន។** ត្រូវរៀបចំកម្មវិធីទាំងនេះឡើងវិញ ដើម្បីផ្តល់មូលដ្ឋានរឹងមាំក្នុងផ្នែកចំណេះដឹងតាមមុខវិជ្ជា (subject matter knowledge) គរុកោសល្យបែបកុមារមជ្ឈមណ្ឌល និងបទពិសោធន៍ច្រើនសម្រាប់ការបង្រៀនក្នុងបន្ទប់រៀនជាក់ស្តែង។ ការធ្វើបច្ចុប្បន្នភាពកម្មវិធីអប់រំគ្រូបង្រៀនជាប្រចាំ ដើម្បីឱ្យស្របនឹងស្តង់ដារជាតិ ការសង្កត់ធ្ងន់លើការរៀនសូត្រផ្អែកតាមការអនុវត្ត និងការពង្រឹងភាពជាដៃគូរវាងគ្រឹះស្ថានបណ្តុះបណ្តាល និងសាលារៀន អាចជួយលុបបំបាត់គម្លាតរវាងទ្រឹស្តី និងការអនុវត្ត ដោយជួយឱ្យគរុសិស្ស-និស្សិត ត្រៀមខ្លួនបានកាន់តែប្រសើរសម្រាប់តថភាពជាក់ស្តែងនាពេលអនាគត។

**ទោះជាយ៉ាងណា ប្រសិទ្ធភាពនៃការអភិវឌ្ឍគ្រូបង្រៀនមិនបញ្ចប់ត្រឹមវិក្រឹតការគ្រូបង្រៀននោះទេ។** ការបន្តអភិវឌ្ឍវិជ្ជាជីវៈមានសារៈសំខាន់ដូចគ្នាសម្រាប់ការធានាថា គ្រូដែលកំពុងបង្រៀន (in-service teachers) នៅតែតាមទាន់វិធីសាស្ត្របង្រៀនថ្មីៗ បច្ចេកវិទ្យា និងការអនុវត្តល្អបំផុត។ កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនចំគោលដៅ ដែលលើកឡើងពីគម្លាតជំនាញជាក់លាក់ និងបំពេញតម្រូវការរបស់គ្រូបង្រៀននៅក្នុងបរិបទផ្សេងៗ គឺជាកត្តាសំខាន់។ គោលវិធីគ្រប់ជ្រុងជ្រោយសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន គួរច្របាច់បញ្ចូលគ្នានូវសិក្ខាសាលាដោយផ្ទាល់ ការបង្វឹកបង្ហាត់តាមសាលា និងធនធានរៀនសូត្រតាមអ៊ីនធឺណិត។ ការបង្កើតប្រព័ន្ធវាយតម្លៃសមិទ្ធកម្មគ្រូបង្រៀនដែលផ្តល់យោបល់ត្រឡប់ជាប្រចាំ និងគាំទ្រការកែលម្អជាបន្តបន្ទាប់ ក៏សំខាន់ផងដែរសម្រាប់ការកំណត់រកចំណុចខ្លាំង និងតម្រូវការអភិវឌ្ឍន៍។ ការពង្រឹងវប្បធម៌នៃកិច្ចសហការ និងការរៀនសូត្រពីគ្នាទៅវិញទៅមក (peer learning) ក្នុងចំណោមគ្រូបង្រៀនដូចគ្នា តាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន បណ្តាញគ្រូបង្រៀន និងកម្មវិធីណែនាំ អាចផ្តល់ឱកាសឱ្យអ្នកអប់រំចែករំលែកការអនុវត្តល្អបំផុត ពិភាក្សាពីបញ្ហាប្រឈមទូទៅ និងរៀនសូត្រពីគ្នាទៅវិញទៅមក។

**ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងបង្កើនការបណ្តុះបណ្តាលគ្រូបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈ បញ្ហាដែលត្រូវដោះស្រាយជាបន្ទាន់គឺការរបាយគ្រូបង្រៀនខុសគ្នានៅតាមសាលា និងតំបន់។** អ្វីដែលជាការព្រួយបារម្ភចម្បងគឺការខ្វះគ្រូជាខ្លាំងនៅតំបន់ជនបទ ជាពិសេសសាលាបឋមសិក្សា ដោយសារការប្រមូលផ្តុំគ្រូបង្រៀននៅតំបន់ទីក្រុង (រូប S.13)។ ភាពខុសគ្នានេះស្តែងឡើងយ៉ាងច្បាស់នៅកម្រិតខេត្ត គឺមានអតិរេកគ្រូបង្រៀននៅទីក្រុងភ្នំពេញ ប៉ុន្តែតែងមានការខ្វះគ្រូបង្រៀននៅតាមខេត្តភាគច្រើនផ្សេងទៀត ជាពិសេសក្នុងខេត្តសៀមរាប និងព្រៃវែង។[44]

**កត្តាមួយចំនួនដែលរួមចំណែកនាំឱ្យមានរបាយគ្រូបង្រៀនខុសគ្នា មានដូចជា កង្វះអត្ថប្រយោជន៍លើកទឹកចិត្តឱ្យគ្រូចុះបង្រៀននៅតំបន់ជនបទ ឬតំបន់ដាច់ស្រយាល កង្វះលំនៅឋាន និងសម្ភារប្រើប្រាស់ចាំបាច់ និងគ្រូបង្រៀនដែលឆ្លៀតឱកាសរកចំណូលបន្ថែម តាមរយៈការបង្រៀនក្រៅម៉ោង នៅតំបន់ទីប្រជុំជន។** ការបង្កើនអត្ថប្រយោជន៍លើកទឹកចិត្តឱ្យគ្រូបង្រៀន

**រូប S១៣.** **ឱនភាព/អតិរេកគ្រូបង្រៀនសរុប បែងចែកតាមតំបន់**




**រូប S១៤.** **លទ្ធផល PISA បែងចែកតាមទីតាំង**




43 Sok, Gondwe, and Wei ២០២២
44 ធនាគារពិភពលោក ២០២៤e

ធ្វើការក្នុងតំបន់ដែលមានសេវាមិនគ្រប់គ្រាន់ ជាកត្តាសំខាន់សម្រាប់ការទាក់ទាញ និងរក្សាអ្នកអប់រំប្រកបដោយគុណវុឌ្ឍិនៅតំបន់ដែលមានតម្រូវការខ្លាំងបំផុត។ នេះអាចរួមបញ្ចូលការផ្តល់កញ្ចប់ឧបត្ថម្ភដែលមានភាពទាក់ទាញ ការផ្តល់ប្រាក់ឧបត្ថម្ភការស្នាក់នៅ ការផ្តល់ជំនួយដល់ការធ្វើដំណើរ និងឱកាសវឌ្ឍនវិជ្ជាជីវៈ និងអាជីព។ ការបន្តពង្រឹងបទដ្ឋាន និងស្តង់ដារគ្រូបង្រៀននៅគ្រប់សាលារៀនទាំងអស់ និងការរក្សាឱ្យគណៈគ្រប់គ្រងសាលាទទួលខុសត្រូវលើការអនុលោមតាម ក៏អាចជួយធានារបាយគ្រូបង្រៀនដែលកាន់តែមានសមធម៌ផងដែរ។

**ផលប៉ះពាល់នៃបញ្ហាប្រឈមទាំងនេះលើការសិក្សារបស់សិស្ស ស្តែងឡើងក្នុងលទ្ធផល PISA នៅពេលប្រៀបធៀបលទ្ធផលសិក្សារវាងសិស្សនៅទីក្រុង និងសិស្សនៅជនបទ ក្នុងប្រទេសកម្ពុជា (រូប S14)។** ក្នុងការវាយតម្លៃ PISA-D ឆ្នាំ ២០១៧ សិស្សនៅទីក្រុងរៀនពូកែខ្លាំងជាងសិស្សនៅជនបទលើគ្រប់មុខវិជ្ជាទាំងអស់ ជាមួយនឹងគម្លាត ៤២ ពិន្ទុសម្រាប់អំណាន គម្លាត ៥១ ពិន្ទុសម្រាប់គណិតវិទ្យា និងគម្លាត ២៨ ពិន្ទុសម្រាប់វិទ្យាសាស្ត្រ។ លទ្ធផល PISA ឆ្នាំ ២០២២ បង្ហាញថា ខណៈដែលសិស្សនៅទីក្រុងរៀនពូកែជាសិស្សនៅជនបទ គម្លាតនេះបានរួមតូចមកវិញ គឺគម្លាត ២៦ ពិន្ទុសម្រាប់អំណាន គម្លាត ៣៦ ពិន្ទុសម្រាប់គណិតវិទ្យា និងគម្លាត ២៣ ពិន្ទុសម្រាប់វិទ្យាសាស្ត្រ។ នេះបង្ហាញពីវឌ្ឍនភាពមួយចំនួនក្នុងការដោះស្រាយវិសមភាពក្នុងការអប់រំ ប៉ុន្តែចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីលុបបំបាត់គម្លាតរវាងទីក្រុង និងទីជនបទ។

**ការបង្កើនប្រសិទ្ធភាពគ្រូបង្រៀននៅកម្ពុជា ទាមទារកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ និងគោលវិធីពហុមុខព្រួញ (multifaceted approach) ដែលដោះស្រាយគម្លាតក្នុងវិក្រឹតការគ្រូបង្រៀន ផ្តល់ឱកាសជាបន្តបន្ទាប់សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ និងធានាការដាក់ពង្រាយគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព និងសមធម៌នៅទូទាំងប្រទេស។** តាមរយៈការវិនិយោគលើផ្នែកទាំងនេះ កម្ពុជានឹងអាចកសាងកម្លាំងបង្រៀនប្រកបដោយជំនាញ និងភាពស្វាហាប់ ដែលអាចផ្តល់ការបង្រៀនប្រកបដោយគុណភាពខ្ពស់ និងការពង្រឹងបទពិសោធន៍រៀនសូត្រប្រកបដោយអត្ថន័យសម្រាប់សិស្សគ្រប់រូប។

**ទោះជាយ៉ាងណា កិច្ចខិតខំប្រឹងប្រែងទាំងនេះត្រូវបំពេញបន្ថែមដោយការពង្រីកការវិនិយោគលើការអប់រំកុមារតូច ការអប់រំកម្រិតបឋមសិក្សា និងលទ្ធភាពប្រកបដោយសមធម៌ក្នុងការទទួលបានការអប់រំ ។** ការបន្តពិនិត្យតាមដាន និងវាយតម្លៃក៏សំខាន់ផងដែរសម្រាប់ការធានាថា កំណែទម្រង់នានាត្រូវបានអនុវត្តដោយប្រសិទ្ធភាព និងសម្រេចបានផលជះដែលចង់បានលើលទ្ធផលសិក្សារបស់សិស្ស។ ចំណុចចុងក្រោយគឺការបង្កើនប្រសិទ្ធភាពគ្រូបង្រៀនមិនមែនជាដំណោះស្រាយដាច់តែឯងនោះទេ ប៉ុន្តែជាសមាសភាគសំខាន់មួយនៃយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយដើម្បីពង្រឹងប្រព័ន្ធអប់រំ និងសម្រេចបានសក្តានុពលពេញលេញសម្រាប់មូលធនមនុស្សរបស់កម្ពុជា។



# អនុសាសន៍

**មួយទសវត្សរ៍មកនេះ កម្ពុជាសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការពង្រីកលទ្ធភាពទទួលបានការអប់រំ។** ទោះជាយ៉ាងណា នៅតែមានបញ្ហាប្រឈមធំៗក្នុងការបង្កើនគុណភាពនៃការអប់រំ និងការធានាឱកាសរៀនសូត្រប្រកបដោយសមធម៌សម្រាប់កុមារគ្រប់រូប។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ និងលើកកម្ពស់ប្រព័ន្ធអប់រំដែលកាន់តែមានបរិយាបន្ន ប្រសិទ្ធភាព និងភាពធន់ ចាំបាច់ត្រូវមានគោលវិធីគ្រប់ជ្រុងជ្រោយ និងជាយុទ្ធសាស្ត្រមួយ។ ផ្នែកនេះរៀបរាប់ពីអនុសាសន៍គោលនយោបាយសំខាន់ៗ ដោយសង្កត់ធ្ងន់លើភាពចាំបាច់នៃការកំណត់អាទិភាព អន្តរាគមន៍ផ្អែកតាមភស្តុតាង និងកិច្ចខិតខំប្រឹងប្រែងបែបសហការរបស់ភាគីពាក់ព័ន្ធទាំងអស់។

១. **ផ្តោតអាទិភាពលើការវិនិយោគផ្នែកការអប់រំកុមារតូច និងការអប់រំបឋមសិក្សា ៖ មានភស្តុតាងជាច្រើនដែលគូសបញ្ជាក់ពីសារៈសំខាន់នៃការអប់រំកុមារតូច (ECE) និងការអប់រំបឋមសិក្សា ក្នុងការកសាងមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ការរៀនសូត្រពេញមួយជីវិត និងភាពជោគជ័យនាពេលអនាគត។** ចំណាយរបស់កម្ពុជាលើការអប់រំបឋមសិក្សាគិតជាភាគរយនៃចំណាយសរុបលើការអប់រំ គឺទាបជាងប្រទេសក្នុងតំបន់ដែលយកមកប្រៀបធៀប ដូចជា វៀតណាម និងថៃ[45]។ ដូច្នេះ ការសំខាន់គឺត្រូវផ្តោតអាទិភាពលើការបែងចែកធនធានដល់ការអប់រំកុមារតូច និងការអប់រំបឋមសិក្សា ដើម្បីធានាថា កុមារគ្រប់រូបអាចទទួលបានការអប់រំតាំងពីដំបូង ប្រកបដោយគុណភាព និងអាចទទួលបានបំណិនមូលដ្ឋានក្នុងផ្នែកអក្ខរកម្ម លេខនព្វន្ត និងការអភិវឌ្ឍផ្នែកសង្គម និងអារម្មណ៍។ វិធានការជាក់លាក់ ៖

- បង្កើនវិភាជថវិកាសម្រាប់កម្មវិធីការអប់រំកុមារតូច និងការអប់រំបឋមសិក្សា
- ពង្រីកលទ្ធភាពទទួលបានសេវាអប់រំកុមារតូចប្រកបដោយគុណភាព នៅតាមតំបន់ដែលខ្វះខាតសេវា។ នេះគួររួមបញ្ចូលការបង្កើតមជ្ឈមណ្ឌល ECE សាធារណៈ និងសាលាគរុកោសល្យ និងវិក្រឹតការខេត្តកាន់តែច្រើន ដែលផ្តល់កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនស្តីពី ECE។
- អនុវត្តកិច្ចអន្តរាគមន៍ចំគោលដៅដើម្បីបង្កើនលទ្ធផលសិក្សានៅថ្នាក់បឋមសិក្សា ដូចជា កម្មវិធីគរុកោសល្យមានរចនាសម្ព័ន្ធ ឬការបង្រៀនត្រូវកម្រិត។

២. **បង្កើនប្រសិទ្ធភាពគ្រូបង្រៀន តាមរយៈការគ្រប់គ្រងគ្រូបង្រៀនគ្រប់ជ្រុងជ្រោយ ៖** គុណភាពគ្រូបង្រៀនជាកត្តាសំខាន់មួយដែលកំណត់ពីលទ្ធផលសិក្សារបស់សិស្ស។ កិច្ចខិតខំបង្កើនប្រសិទ្ធភាពគ្រូបង្រៀន គួររួមបញ្ចូលគោលវិធីក្តោបរួមមួយសម្រាប់ការគ្រប់គ្រងគ្រូបង្រៀន ដូចជា ៖

- កែលម្អការជ្រើសរើស និងការដាក់ពង្រាយគ្រូបង្រៀន ៖
  - បង្កើនគ្រឿងលើកទឹកចិត្តឱ្យគ្រូចុះបង្រៀនតាមតំបន់ដែលខ្វះគ្រូ ដូចជា កញ្ចប់សំណងជំងឺចិត្តដែលមានភាពទាក់ទាញ ការផ្តល់ប្រាក់ឧបត្ថម្ភថ្លៃស្នាក់នៅ ការផ្តល់ជំនួយដល់ការធ្វើដំណើរ និងឱកាសសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ។
  - បន្តពង្រឹងបទដ្ឋាន និងស្តង់ដារគ្រូបង្រៀន នៅគ្រប់សាលារៀនទាំងអស់ និងរក្សាឱ្យគណៈគ្រប់គ្រងសាលារៀនទទួលខុសត្រូវលើការអនុលោមតាម ដើម្បីធានារបាយគ្រូបង្រៀនដែលកាន់តែមានសមធម៌។
- ការពង្រឹងកម្មវិធីវិក្រឹតការ និងបណ្តុះបណ្តាលគ្រូបង្រៀន ៖
  - ការរៀបចំឡើងវិញនូវកម្មវិធីវិក្រឹតការ ដើម្បីផ្តល់មូលដ្ឋានគ្រឹះរឹងមាំសម្រាប់ចំណេះដឹងតាមមុខវិជ្ជា គរុកោសល្យបែបកុមារមជ្ឈមណ្ឌល និងបទពិសោធន៍សំបូរបែបសម្រាប់ការអនុវត្តក្នុងបន្ទប់រៀន។
  - អនុវត្តកម្មវិធីបណ្តុះបណ្តាលចំគោលដៅដែលដោះស្រាយគម្លាតបំណិនជាក់លាក់ គឺកម្មវិធីបណ្តុះបណ្តាលដែលច្បាស់លាស់ អាចអនុវត្តបាន និងផ្តល់បទពិសោធន៍វិជ្ជមាន និងផ្តល់ការអនុវត្តក្នុងថ្នាក់រៀន និងយោបល់ត្រឡប់គ្រប់គ្រាន់។

45 ធនាគារពិភពលោក ២០២៣b

- ស្វែងរកម៉ូឌែល និងឧបករណ៍បង្រៀនបែបថ្មី ដូចជា ម៉ូឌែលគ្រូបង្រៀន ២ នាក់ (dual teacher model) កិច្ចតែងការបង្រៀនបែបរចនាសម្ព័ន្ធ ការបង្រៀនចំគោលដៅ និងបច្ចេកវិទ្យាសម្រាប់ការអប់រំ។

- បង្កើតប្រព័ន្ធគ្រប់ជ្រុងជ្រោយសម្រាប់វាយតម្លៃសមិទ្ធកម្មគ្រូបង្រៀន ៖
  - បង្កើតក្របខណ្ឌវាយតម្លៃគ្រូបង្រៀនដែលមិនលម្អៀង និងមានតម្លាភាព ដែលផ្តល់យោបល់ត្រឡប់ជាប្រចាំ និងគាំទ្រការកែលម្អជាបន្តបន្ទាប់
  - ប្រើប្រាស់លទ្ធផលពីការវាយតម្លៃដើម្បីកំណត់រកចំណុចខ្លាំង និងតម្រូវការអភិវឌ្ឍន៍ សម្រាប់ជាមូលដ្ឋាននៃឱកាសអភិវឌ្ឍន៍វិជ្ជាជីវៈចំគោលដៅ។
  - ពង្រឹងវប្បធម៌នៃកិច្ចសហការ និងការរៀនសូត្រពីគ្នាទៅវិញទៅមក តាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈ បណ្តាញគ្រូបង្រៀន និងកម្មវិធីណែនាំ។

៣. **ធានាការបែងចែកធនធានប្រកបដោយសមធម៌នៅតាមតំបន់ និងសាលារៀន ៖** ជារឿយៗ វិសមភាពក្នុងលទ្ធផលសិក្សាបណ្តាលមកពីការបែងចែកធនធានដោយគ្មានសមធម៌។ ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋាភិបាលអាច ៖

- បង្កើតរូបមន្តផ្តល់ជំនួយមូលនិធិផ្អែកតាមតម្រូវការដើម្បីបែងចែកធនធានទៅតាមលក្ខណៈសាលារៀន និងចំនួនសិស្ស
- ផ្តល់ការគាំទ្រ និងធនធានបន្ថែមដល់តំបន់ជួបការលំបាក និងសាលាដែលមានសំបូរដោយសិស្សជួបការលំបាក
- អនុវត្តកម្មវិធី និងកិច្ចអន្តរាគមន៍ចំគោលដៅដើម្បីគាំទ្រដល់សហគមន៍ជួបការលំបាកបំផុត ដូចជា អាហារូបករណ៍ កម្មវិធីផ្តល់អាហារតាមសាលារៀន និងការផ្តល់ជំនួយដល់ការធ្វើដំណើរ។

៤. **ផ្តោតអាទិភាពលើអន្តរាគមន៍ដែលផ្អែកតាមភស្តុតាង និងមានប្រសិទ្ធភាពចំណាយ ៖** ដោយធនធានមានកំណត់ ការសំខាន់គឺត្រូវផ្តោតអាទិភាពលើកិច្ចអន្តរាគមន៍ដែលត្រូវបានបញ្ជាក់ថាមានប្រសិទ្ធភាពចំណាយ និងមានផលជះលើលទ្ធផលសិក្សារបស់សិស្ស។ របាយការណ៍ធនាគារពិភពលោកស្តីពី "ការអនុវត្តល្អបំផុត ឬ Best Buys" ក្នុងការអប់រំ ផ្តល់ភស្តុតាងដ៏លេចធ្លោរស្តីពីកិច្ចអន្តរាគមន៍នានា ដូចជា កម្មវិធីគរុកោសល្យបែបរចនាសម្ព័ន្ធ ឬការបង្រៀនត្រូវកម្រិត ដែលត្រូវបានបង្ហាញថា មានប្រសិទ្ធភាពខ្ពស់ តែចំណាយទាប[46]។

ដោយស្ថាបនាពីលើ "ការអនុវត្តល្អបំផុត" ដែលផ្អែកតាមភស្តុតាងទាំងនេះ និងការវាយតម្លៃល្អិតល្អន់លើផលជះនៃកិច្ចអន្តរាគមន៍នានា កម្ពុជានឹងអាចធានាការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងបង្កើនជាអតិបរមានូវផលចំណេញពីការវិនិយោគលើវិស័យអប់រំ។

៥. **កាត់បន្ថយការខាតបង់ការរៀនសូត្រដោយសារវិបត្តិកូវីដ-១៩ និងបង្កើនភាពធន់ ៖** វិបត្តិកូវីដ-១៩ បានពង្រីកគម្លាតក្នុងការរៀនសូត្រ និងគូសបញ្ជាក់ពីតម្រូវការប្រព័ន្ធអប់រំដែលធន់។ កិច្ចអន្តរាគមន៍ដើម្បីដោះស្រាយការខាតបង់ការរៀនសូត្រអាចរួមមាន ៖

- អនុវត្តកម្មវិធីបំប៉ន និងការគាំទ្រចំគោលដៅសម្រាប់សិស្សដែលរៀនខ្សោយ
- ផ្តល់ការបណ្តុះបណ្តាលគ្រូបង្រៀនស្តីពីការអនុវត្តការសិក្សាពីចម្ងាយដែលមានប្រសិទ្ធភាព និងការទាញប្រយោជន៍ពីបច្ចេកវិទ្យាសម្រាប់ការអប់រំពីចម្ងាយ
- ធានាលទ្ធភាពទទួលបានសម្ភារៈរៀនសូត្រ និងធនធានឌីជីថលសម្រាប់សិស្សនៅតំបន់ដាច់ស្រយាល ឬតំបន់ជួបការលំបាក។

៦. **ពង្រឹងសមត្ថភាព និងអភិបាលកិច្ចស្ថាប័ន ៖** ការអនុវត្តកំណែទម្រង់វិស័យអប់រំប្រកបដោយប្រសិទ្ធភាព ទាមទារការពង្រឹងសមត្ថភាព និងអភិបាលកិច្ចស្ថាប័ននៅគ្រប់កម្រិត។ វិធានការជាក់លាក់ ៖

46 Banerjee et al. ២០២៣; ធនាគារពិភពលោក ២០២០

- ផ្តល់ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពសម្រាប់អាជ្ញាធរអប់រំស្តីពីការរៀបចំផែនការថវិកា ការអនុវត្ត ការពិនិត្យតាមដាន និងការវិភាគទិន្នន័យ
- បង្កើតយន្តការគណនេយ្យភាពគ្រប់ជ្រុងជ្រោយដើម្បីធានាប្រសិទ្ធភាព និងប្រសិទ្ធផលនៃការប្រើប្រាស់ធនធាន
- លើកកម្ពស់តម្លាភាព និងការចូលរួមរបស់ភាគីពាក់ព័ន្ធ ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។

៧. **ពង្រឹងកិច្ចសហការ និងភាពជាដៃគូក្នុងចំណោមភាគីពាក់ព័ន្ធ ៖** ការដោះស្រាយបញ្ហាប្រឈមចម្រុះក្នុងវិស័យអប់រំ ទាមទារកិច្ចខិតខំប្រឹងប្រែងបែបសហការ និងកម្លាំងផ្គួបក្នុងចំណោមភាគីពាក់ព័ន្ធផ្សេងៗ។ រដ្ឋាភិបាលគួរ ៖

- បង្កើនយន្តការសម្របសម្រួល និងវេទិកាសម្រាប់ការចែករំលែកចំណេះដឹងក្នុងចំណោមទីភ្នាក់ងាររដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងសហគមន៍នានា
- ទាញប្រយោជន៍ពីជំនាញ និងធនធានរបស់ភាគីពាក់ព័ន្ធផ្សេងៗដើម្បីគាំទ្រអន្តរាគមន៍អាទិភាព និងកិច្ចខិតខំធ្វើកំណែទម្រង់វិស័យអប់រំ
- លើកកម្ពស់ការចូលរួមរបស់សហគមន៍ក្នុង និងភាពម្ចាស់ការលើគំនិតផ្តួចផ្តើមអប់រំ ដើម្បីបង្កើននិរន្តរភាព និងផលជះ។

៨. **អនុវត្ត និងត្រួតពិនិត្យស្តង់ដារទាំង ៥ សម្រាប់សាលារៀន ៖** ថ្មីៗនេះ ការដាក់ចេញស្តង់ដារសាលារៀនគំរូចំនួន ៥ ដោយក្រសួងអប់រំ យុវជន និងកីឡា (រួមបញ្ចូលលទ្ធផលសិក្សារបស់សិស្ស ការបង្រៀន និងរៀន ការចូលរួមរបស់សហគមន៍ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន និងគណនេយ្យភាពរបស់សាលារៀន) បង្ហាញពីឱកាសក្នុងការបង្កើនគុណភាពការអប់រំទូទាំងប្រទេស។ ប្រសិទ្ធភាពនៃការអនុវត្ត និងការត្រួតពិនិត្យស្តង់ដារទាំងនេះនៅគ្រប់សាលារដ្ឋទាំងអស់ ចាប់ពីមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សា ជាកត្តាសំខាន់ក្នុងការសម្រេចបានភាពប្រសើរឡើងនៃការបង្រៀន ការរៀន និងឥរិយាបថរបស់សិស្ស។

**ខណៈដែលស្តង់ដារទាំងនេះមានសារៈសំខាន់ ការគោលវិធីជាយុទ្ធសាស្ត្រសម្រាប់ការកំណត់អាទិភាព និងការរៀបលំដាប់លំដោយ គឺជាការចាំបាច់ ត្បិតធនធាននៅមានកម្រិត។** ការវិនិយោគលើការអប់រំកុមារតូច និងការអប់រំបឋមសិក្សា គួរត្រូវបានកំណត់យកជាជំហានជាមូលដ្ឋានមួយ បន្ទាប់គឺកិច្ចខិតខំប្រឹងប្រែងបង្កើនប្រសិទ្ធភាពគ្រូបង្រៀន និងធានាការបែងចែកធនធានប្រកបដោយសមធម៌។ ការអនុវត្តកិច្ចអន្តរាគមន៍ដែលផ្អែកតាមភស្តុតាង និងមានប្រសិទ្ធភាពចំណាយ និងការកាត់បន្ថយការខាតបង់ការរៀនសូត្រដោយសារវិបត្តិកូវីដ-១៩ គួរតែជាអាទិភាពស្របគ្នា។ ការពង្រឹងសមត្ថភាពស្ថាប័ន ការបង្កើនកិច្ចសហការ និងការត្រួតពិនិត្យស្តង់ដារសាលារៀនអាចជាដំណើរការបន្តជាប់ដើម្បីទ្រទ្រង់កិច្ចខិតខំប្រឹងប្រែងជារួម។

**ការសម្រេចបានចក្ខុវិស័យរបស់កម្ពុជាក្នុងការក្លាយខ្លួនទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងសក្តានុពលពេញលេញនៃធនធានមនុស្សរបស់កម្ពុជា អាស្រ័យលើប្រជាជនដែលមានការអប់រំល្អ និងជំនាញ។** ការអនុវត្តអនុសាសន៍គោលនយោបាយទាំងនេះ នឹងទាមទារឆន្ទៈរឹងមាំផ្នែកនយោបាយ និរន្តរភាពនៃការប្តេជ្ញាចិត្តផ្នែកហិរញ្ញវត្ថុ និងប្រសិទ្ធភាពនៃការសម្របសម្រួលក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់។ ទោះជាយ៉ាងណា ការផ្តោតអាទិភាពលើកំណែទម្រង់ការអប់រំ ការវិនិយោគលើគុណភាព និងសមធម៌ និងការអនុវត្តគោលវិធីដែលផ្អែកតាមភស្តុតាង នឹងអាចឱ្យកម្ពុជាកសាងប្រព័ន្ធអប់រំដែលកាន់តែមានបរិយាបន្ន ប្រសិទ្ធភាព និងភាពធន់ ដែលមិនទុកកុមារណាម្នាក់ចោល។

# ឧបសម្ព័ន្ធ. កម្ពុជា – សូចនាករសំខាន់ៗ

| សូចនាករសំខាន់ៗ* | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 E | 2024 F |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ប្រាក់ចំណូល និងកំណើនសេដ្ឋកិច្ច** | | | | | | | | | | | | | | | |
| កំណើន ផ.ស.ស (ប្រចាំឆ្នាំ % ពិត) | 6.0 | 7.1 | 7.3 | 7.4 | 7.1 | 7.0 | 6.9 | 7.0 | 7.5 | 7.1 | -3.1 | 3.0 | 5.2 | 5.4 | 5.8 |
| កំណើន ផ.ស.ស ក្នុងមនុស្សម្នាក់ (ប្រចាំឆ្នាំ % ពិត) | 4.4 | 5.5 | 5.8 | 5.8 | 5.7 | 5.5 | 5.5 | 5.6 | 6.2 | 5.8 | -4.2 | 1.8 | 4.0 | 4.3 | 4.7 |
| កំណើន ផ.ស.ស ក្នុងមនុស្សម្នាក់ (ដុល្លារអាមេរិក ណូលនីណល) | 810.0 | 889.6 | 949.4 | 1030.1 | 1105.1 | 1183.2 | 1281.3 | 1397.0 | 1527.3 | 1667.8 | 1584.0 | 1625.3 | 1738.9 | 1876.0 | 2010.6 |
| កំណើនប្រើប្រាស់ឯកជន (ប្រចាំឆ្នាំ %) | 8.8 | 10.4 | 4.6 | 5.8 | 4.5 | 9.4 | 5.8 | 3.7 | 6.8 | 5.9 | -4.0 | -0.7 | 33.0 | -16.1 | 2.2 |
| ការវិនិយោគដុល ( % នៃ ផ.ស.ស ណូមីណល) | 16.2 | 16.0 | 17.4 | 18.7 | 20.9 | 21.4 | 21.7 | 21.9 | 22.6 | 23.4 | 23.5 | 39.3 | 53.4 | 37.3 | 31.2 |
| ការវិនិយោគ - សាធារណៈ ( % នៃ ផ.ស.ស ណូមីណល)[2] | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. |
| **រូបិយវត្ថុ និងតម្លៃ** | | | | | | | | | | | | | | | |
| អតិផរណា តម្លៃទំនិញប្រើប្រាស់ (ប្រចាំឆ្នាំ % EOP ឬ MRV)[1] | 2.9 | 4.6 | 2.3 | 4.5 | 0.9 | 2.8 | 3.8 | 2.2 | 1.6 | 3.1 | 2.9 | 3.8 | 3.0 | 2.8 | .. |
| អតិផរណា តម្លៃទំនិញប្រើប្រាស់ (ប្រចាំឆ្នាំ % រយៈពេលជាមធ្យម) | 2.6 | 5.5 | 3.0 | 2.9 | 3.9 | 1.2 | 3.0 | 2.9 | 2.5 | 1.9 | 2.9 | 2.8 | 5.5 | 2.1 | 2.8 |
| រូបិយវត្ថុទូទៅ (% នៃ ផ.ស.ស) | 41.6 | 39.1 | 50.1 | 55.5 | 67.1 | 72.4 | 79.2 | 88.2 | 100.7 | 116.3 | 143.3 | 130.7 | 89.7 | 83.0 | 84.0 |
| ឥណទានក្នុងស្រុកផ្តល់ឱ្យវិស័យឯកជន ( % នៃ ផ.ស.ស)[2] | 27.6 | 28.3 | 38.7 | 52.0 | 62.7 | 74.3 | 81.7 | 86.7 | 99.6 | 114.2 | 139.6 | 166.3 | 180.0 | .. | .. |
| អត្រាការប្រាក់រយៈពេល ១០ ឆ្នាំ (ជាមធ្យមប្រចាំឆ្នាំ)[1] | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. |
| អត្រាប្តូរប្រាក់ណូមីណល (រូបិយប័ណ្ណក្នុងស្រុកក្នុងមួយដុល្លារ) | 4044.0 | 4016.0 | 4033.0 | 4027.0 | 4030.0 | 4025.0 | 4058.0 | 4062.0 | 4067.0 | 4070.0 | 4077.4 | 4100.0 | 4150.0 | 4110.0 | 4100.0 |
| សន្ទស្សន៍អត្រាប្តូរប្រាក់ពិត (២០១៥=១០០) | 97.7 | 94.9 | 93.6 | 92.6 | 94.9 | 100.0 | 101.8 | 101.7 | 98.5 | 99.1 | 103.5 | 79.1 | 55.7 | 45.8 | 42.3 |
| **សារពើពន្ធ** | | | | | | | | | | | | | | | |
| ចំណូល (% នៃ ផ.ស.ស) | 17.7 | 17.6 | 17.7 | 18.2 | 20.0 | 19.7 | 20.9 | 21.9 | 23.8 | 27.0 | 24.1 | 22.0 | 23.4 | 21.4 | 20.7 |

| សូចនាករសំខាន់ៗ* | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 E | 2024 F |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ការចំណាយ (% នៃ ផ.ស.ស) | 21.0 | 23.0 | 21.9 | 21.4 | 21.9 | 20.2 | 21.1 | 22.7 | 23.4 | 25.5 | 28.8 | 29.2 | 27.7 | 26.7 | 26.2 |
| ការបង់សងការប្រាក់ (% នៃ ផ.ស.ស) | 0.3 | 0.3 | 0.5 | 0.7 | 0.7 | 0.3 | 0.4 | 0.4 | 0.4 | 0.4 | 0.6 | 0.7 | 0.6 | 0.6 | 0.6 |
| ការចំណាយមិនមែនការប្រាក់ (% នៃ ផ.ស.ស) | 20.7 | 22.7 | 21.4 | 20.7 | 21.2 | 19.9 | 20.7 | 22.3 | 23.0 | 25.1 | 28.2 | 28.5 | 27.2 | 26.2 | 27.4 |
| សមតុល្យសារពើពន្ធសរុប (% នៃ ផ.ស.ស) | -3.3 | -5.4 | -4.2 | -3.2 | -1.9 | -0.5 | -0.2 | -0.8 | 0.4 | 1.5 | -4.7 | -7.2 | -4.4 | -5.3 | -5.5 |
| សមតុល្យសារពើពន្ធចម្បង (% នៃ ផ.ស.ស) | -3.0 | -5.1 | -3.7 | -2.5 | -1.2 | -0.2 | 0.2 | -0.4 | 0.8 | 1.9 | -4.3 | -6.5 | -3.8 | -4.7 | -5.3 |
| បំណុលរដ្ឋាភិបាលទូទៅ (% នៃ ផ.ស.ស) | 28.7 | 29.7 | 31.6 | 31.3 | 31.8 | 31.2 | 29.1 | 30.3 | 28.3 | 28.1 | 35.9 | 36.1 | 36.7 | 33.6 | 35.6 |
| បំណុលសាធារណៈបរទេស (% នៃ ផ.ស.ស)² | 28.7 | 29.7 | 31.6 | 31.7 | 31.8 | 31.2 | 29.1 | 30.3 | 28.7 | 28.1 | 33.9 | 35.2 | 32.5 | 35.2 | 35.6 |
| **គណនីខាងក្រៅ** | | | | | | | | | | | | | | | |
| កំណើននាំចេញ G&S (ដុល្លារអាមេរិកឈ្មោះមិណល ប្រចាំឆ្នាំ %) | 22.9 | 11.4 | 16.0 | 16.8 | 10.3 | 7.5 | 9.0 | 9.4 | 12.3 | 8.5 | 2.1 | 11.2 | 31.9 | 19.0 | 22.4 |
| ចំណើននាំចូល G&S (ដុល្លារអាមេរិកណ្ឌមីណល ប្រចាំឆ្នាំ %) | 19.1 | 11.4 | 14.2 | 16.9 | 8.8 | 7.6 | 9.0 | 7.8 | 9.3 | 17.4 | 9.7 | 47.8 | 37.2 | -20.6 | 11.9 |
| ការនាំចេញទំនិញ (% នៃ ផ.ស.ស) | 38.3 | 38.8 | 41.6 | 44.6 | 45.4 | 45.4 | 45.5 | 45.2 | 46.0 | 46.0 | 51.8 | 62.8 | 71.4 | 73.7 | 76.2 |
| ការនាំចូលទំនិញ (% នៃ ផ.ស.ស) | 50.4 | 50.5 | 53.7 | 57.5 | 57.5 | 57.3 | 56.9 | 55.6 | 55.1 | 54.6 | 65.7 | 92.4 | 93.0 | 73.9 | 74.7 |
| សេវាកម្ម សុទ្ធ (% នៃ ផ.ស.ស) | 6.8 | 6.3 | 7.3 | 7.8 | 7.7 | 7.5 | 7.0 | 7.0 | 7.4 | 1.8 | 1.4 | -10.9 | -33.2 | -10.2 | -1.6 |
| សមតុល្យគណនីចរន្ត (លានដុល្លារអាមេរិកចរន្ត) | -1165.3 | -1309.3 | -1390.7 | -1489.3 | -1899.7 | -1680.6 | -1756.6 | -1634.4 | -1540.5 | -2155.0 | -1938.3 | -10711.1 | -7437.5 | 551.6 | 924.0 |
| សមតុល្យគណនីចរន្ត (% នៃ ផ.ស.ស) | -10.0 | -10.1 | -9.9 | -9.6 | -11.3 | -9.2 | -8.8 | -7.4 | -6.3 | -8.0 | -7.5 | -39.7 | -25.5 | 1.7 | 2.7 |
| ការវិនិយោគផ្ទាល់ពីបរទេស លំហូរចូលសុទ្ធ (% នៃ ផ.ស.ស) | 11.8 | 11.8 | 14.0 | 13.0 | 10.6 | 9.5 | 12.0 | 12.1 | 12.6 | 13.2 | 13.5 | 12.6 | 11.7 | 11.5 | 11.9 |
| បំណុលពហុភាគី (% នៃបំណុលបរទេសសរុប)² | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. |

| សូចនាករសំខាន់ៗ* | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 E | 2024 F |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ប្រជាជន ការងារ និងភាពក្រីក្រ** | | | | | | | | | | | | | | | |
| ចំនួនប្រជាជនសរុប (លាន) | 14.4 | 14.6 | 14.8 | 15.0 | 15.2 | 15.4 | 15.6 | 15.8 | 16.0 | 16.2 | 16.4 | 16.6 | 16.8 | 16.9 | 17.1 |
| កំណើនប្រជាជន (ប្រចាំឆ្នាំ %) | 1.5 | 1.5 | 1.5 | 1.4 | 1.4 | 1.4 | 1.3 | 1.3 | 1.2 | 1.1 | 1.2 | 1.2 | 1.1 | 1.1 | 1.0 |
| អត្រាគ្មានការងារធ្វើ[2] | 0.8 | 0.6 | 0.5 | 0.4 | 0.7 | 0.4 | 0.7 | 0.1 | 0.1 | 0.1 | 0.3 | 0.3 | 0.4 | .. | .. |
| វិសមភាព - មេគុណ Gini[2] | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. |
| អាយុរស់រំពឹងទុក[2] | 67.7 | 68.4 | 68.9 | 69.3 | 69.7 | 69.9 | 70.2 | 70.5 | 70.6 | 70.7 | 70.4 | 69.6 | .. | .. | .. |
| **ផ្សេងៗ** | | | | | | | | | | | | | | | |
| ផ.ស.ស (ពាន់លាន LCU ចរន្ត) | 47047985.2 | 52068692.7 | 56616800.5 | 62219524.1 | 67740449.6 | 73422701.6 | 81241866.0 | 89830524.8 | 99544274.8 | 110014048.2 | 105899309.1 | 110548038.2 | 121006210.9 | 130652522.2 | 141145762.6 |
| ផ.ស.ស (លានដុល្លារអាមេរិក ចរន្ត) | 11634.0 | 12965.3 | 14038.4 | 15450.6 | 16809.0 | 18241.7 | 20020.2 | 22114.9 | 24476.1 | 27030.5 | 25972.0 | 26962.9 | 29158.1 | 31788.9 | 34425.8 |
| ផ.ស.ស ក្នុងមនុស្សម្នាក់ LCU (ពិត ពាន់) | 2102966.9 | 2219138.4 | 2347166.9 | 2484050.4 | 2624532.8 | 2769713.7 | 2922496.8 | 3086269.9 | 3276522.2 | 3468153.5 | 3322017.5 | 3382908.7 | 3519610.8 | 3671316.0 | 3844388.1 |
| ចំណាត់ថ្នាក់សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស[3] | 149 | 150 | 150 | 151 | 151 | 150 | 150 | 149 | 150 | 150 | 149 | 147 | 148 | .. | .. |
| CPIA (ចំណាត់ថ្នាក់សរុប)[2] | 3.4 | 3.4 | 3.5 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.5 | 3.6 | .. | .. |
| ការគ្រប់គ្រងសេដ្ឋកិច្ច[2] | 4.0 | 3.8 | 3.8 | 3.8 | 3.8 | 4.0 | 4.0 | 4.0 | 4.2 | 4.2 | 4.2 | 4.2 | 4.2 | .. | .. |
| គោលនយោបាយរចនាសម្ព័ន្ធ[2] | 3.3 | 3.5 | 3.7 | 3.7 | 3.7 | 3.5 | 3.5 | 3.3 | 3.3 | 3.3 | 3.3 | 3.5 | 3.5 | .. | .. |
| គោលនយោបាយសម្រាប់បរិយាបន្នសង្គម និងសមធម៌[2] | 3.4 | 3.5 | 3.5 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.5 | 3.5 | 3.6 | 3.8 | .. | .. |
| ការគ្រប់គ្រងវិស័យសាធារណៈ និងស្ថាប័ន[2] | 2.7 | 2.8 | 2.8 | 2.8 | 2.8 | 2.7 | 2.7 | 2.7 | 2.6 | 2.6 | 2.7 | 2.8 | 2.8 | .. | .. |

*សម្គាល់ ៖* «..» បង្ហាញថា ទិន្នន័យមិនអាចរកបាល, E = ប៉ាន់ប្រមាណ, F = ព្យាករ។ ទិន្នន័យទទួលបានពី MFMOD លុះត្រាតែមានកំណត់សម្គាល់ផ្សេងពីនេះ។

*១/ មូលដ្ឋានទិន្នន័យ* GEM របស់ធនាគារពិភពលោក, MRV = តម្លៃបច្ចុប្បន្នបំផុត។

*២/ មូលដ្ឋានសូចនាករការអភិវឌ្ឍពិភពលោក* និងការប៉ាន់ប្រមាណរបស់បុគ្គលិកធនាគារពិភពលោក។

*៣/ ចំណាត់ថ្នាក់* HDI ឆ្នាំ២០០១ ដែលមានប្រទេសចំនួន ១៧៥ ហើយក្នុងឆ្នាំ២០១០ មានប្រទេសចំនួន ១៦៩។ ការពង្រឹងវិធីសាស្ត្រ ក្នុងការគណនា HDI បានបណ្តាលឱ្យមានការកើនឡើងគួរឱ្យកត់សម្គាល់នូវចំណាត់ថ្នាក់របស់ប្រទេសនានា។

*ប្រភព៖ មូលដ្ឋានទិន្នន័យ* MFMOD, ធនាគារពិភពលោក និងមូលដ្ឋានទិន្នន័យ GEM, មូលនិធិរូបិយវត្ថុអន្តរជាតិ។

# គន្ថនិទ្ទេស


Angkor Enterprise. 2024. “Monthly Revenue from Angkor Entrance Fees 2024.” Angkor Enterprise, Phnom Penh. https://www.angkorenterprise.gov.kh/.

Azevedo, J. P., A. Hasan, and D. Goldemberg. 2022. “Learning losses from COVID-19 school closures in Cambodia: Simulation results.” World Bank, Washington, DC.

Banerjee, A., T. Andrab, R. Banerji, S. Dynarski, R. Glennerster, S. Grantham-Mcgregor, K. Muralidharan, B. Piper, J. S. Chanduvi, H. Yoshikawa, S. Ruto, and S. Schmelkes. 2020. “COST-EFFECTIVE APPROACHES TO IMPROVE GLOBAL LEARNING What does recent evidence tell us are ‘Smart Buys’ for improving learning in low- and middle-income countries? Recommendations of the Global Education Evidence Advisory Panel.” World Bank, Washington, DC, October.

Bhatta, S. D., S. Katwal, T. Pfutze, V. Ros, Y. N. Wong, F. No. 2022. “CAMBODIA Learning Loss in Cambodia and the Use of EdTech during COVID-19.” World Bank, Washington, DC.

Boy, V., and T. Water. 2023. “Challenges of teaching English as an additional language in high schools in Cambodia.” Cambodian Journal of Educational Research 3 (1): 44–75. https://doi.org/10.62037/cjer.2023.03.01.03.

Bremner, N., N. Sakata, and L. Cameron. 2023. “Teacher Education as an Enabler or Constraint of Learner-Centred Pedagogy Implementation in Low-to Middle-Income Countries.” Teaching and Teacher Education 126 (May).

Cambodia National Institute of Statistics. 2014. “Cambodia Socio-Economic Survey Report 2014.” https://nis.gov.kh/index.php/km/.

———. 2019. “Cambodia Socio-Economic Survey Report 2019.” https://nis.gov.kh/index.php/km/.

———. 2021. “Cambodia Socio-Economic Survey Report 2021.” https://nis.gov.kh/index.php/km/.

Cambodia Socio-Economic Survey Reports. 2014. https://nis.gov.kh/index.php/km/.

Cambodia Socio-Economic Survey Reports. 2019/20. https://nis.gov.kh/index.php/km/.

Carranza, Luis. 2002. “Current Account Sustainability.” International Monetary Fund, Washington, DC. https://www.elibrary.imf.org/display/book/9781589060944/ch05.xml#:~:text=variable%20for%20policymakers.-,Deficits%20in%20the%20external%20current%20account%20are%20the%20result%20of,unsustainable%20in%20the%20long%20run.

Devadas, S., and N. Loayza. 2018. “When Is a Current Account Deficit Bad?” Research & Policy Briefs, From the World Bank Malaysia Hub, No. 17, October. World Bank, Washington, DC. https://documents1.worldbank.org/curated/en/507731538487989157/pdf/130415-BRI-PUBLIC-ADD-SERIES-When-is-a-current-account-deficit-bad.pdf.

Food and Agriculture Organization of the United Nations. 2022. Rome. https://www.fao.org/faostat/en/#data.

International Monetary Fund. 2016. “Managing Government Compensation and Employment – Institutions, Policies, and Reform Challenges.” Volume 2016, Issue 047. International Monetary Fund, Washington, DC. https://doi.org/10.5089/9781498345774.007.

———. 2024. “Cambodia: 2023 Article IV Consultation” Press Release and Staff Report. International Monetary Fund, Washington, DC. https://www.imf.org/en/Publications/CR/Issues/2024/01/29/Cambodia-2023-Article-IV-Consultation-Press-Release-and-Staff-Report-544276.

Lewin, K. 2004. "The Pre-Service Training of Teachers: Does It Meet Its Objectives and How Can It Be Improved?" UNESCO UNESDOC Digital Library. Background paper prepared for the Education for All Global Monitoring Report 2005. https://unesdoc.unesco.org/ark:/48223/pf0000146658.

Ministry of Agriculture, Forestry and Fisheries. 2023. "Annual report for 2023 and target for 2024." Ministry of Agriculture, Forestry and Fisheries, Phnom Penh.

Ministry of Economy and Finance. 2024a. Public Debt Statistical Bulletin, Volume 21, February. Ministry of Economy and Finance, Phnom Penh. https://gdicdm.mef.gov.kh/en/2024/02/16/11166.html.

———. 2024b. Government Finance Statistics (GFS) and Tableau des Opérations Financières de l'Etat (TOFE). Ministry of Economy and Finance, Phnom Penh. https://mef.gov.kh/documents-category/publication/tofe/.

Ministry of Planning. 2014. Cambodia Socio-Economic Survey (CSES) 2014. National Institute of Statistics, Ministry of Planning, Ministry of Planning, Phnom Penh.

———. 2019. Cambodia Socio-Economic Survey 2019. National Institute of Statistics Ministry of Planning, Phnom Penh.

———. 2021. Cambodia Socio-Economic Survey 2021. National Institute of Statistics, Ministry of Planning, Phnom Penh.

———. 2022. National Accounts 2022. Ministry of Planning, Phnom Penh.

———. 2024. Monthly Consumer Price Index 2024. Ministry of Planning, Phnom Penh.

Ministry of Tourism. 2023. "Cambodia Tourism Statistics Report, 2023." Ministry of Tourism, Phnom Penh.

———. 2024. "Monthly Cambodia Tourism Statistics Report," February 2024. Ministry of Tourism, Phnom Penh.

National Bank of Cambodia. 2023a. "Annual Report, 2023." National Bank of Cambodia, Phnom Penh. https://www.nbc.gov.kh/download_files/publication/annual_rep_kh/Annual_Report_2023_KHM.pdf.

———. 2023b. Cambodia Balance of Payments Fourth Quarter 2023. National Bank of Cambodia, Phnom Penh. https://www.nbc.gov.kh/english/economic_research/balance_of_payment_data.php.

———. 2024. Monetary and Financial Statistics Data 2024. National Bank of Cambodia, Phnom Penh. https://www.nbc.gov.kh/english/economic_research/monetary_and_financial_statistics_data.php.

Royal Government of Cambodia. 2022. The 2022 Budget Settlement Law. Royal Government of Cambodia, Phnom Penh. http://www.treasury.gov.kh/document/5.

———. 2024. The 2024 Annual Budget Law. Royal Government of Cambodia, Phnom Penh. https://mef.gov.kh/documents-category/law-and-regulation/.

SEA-PLM 2019 (Southeast Asia Primary Learning Metrics 2019 report). 2019. https://www.seaplm.org/PUBLICATIONS/regional%20results/SEA-PLM%202019%20Main%20Regional%20Report.pdf.

Sok, S., F. Gondwe, and L. Wei. 2022. "Implementation of Teaching Practicum for Primary School Teachers: China, Cambodia and Malawi Case Studies." African Journal of Teacher Education 11: 190–217.

United States Federal Reserve. 2024. "Federal Reserve issues FOMC statement," Press Release, March 20, Washington, DC. https://www.federalreserve.gov/newsevents/pressreleases/monetary20240320a.htm

World Bank. 2016. Enterprise Survey for Cambodia. World Bank, Washington, DC. https://microdata.worldbank.org/index.php/catalog/2802.

———. 2019. “Cambodia Economic Update – November 2019: Upgrading Cambodia in Global Value Chains” (English). Washington, DC: World Bank. https://documents.worldbank.org/en/publication/documents-reports/documentdetail/707971575947227090.

———. 2020. “Lasting Scars of the COVID-19 Pandemic.” Global Economic Prospects, June 2020. Washington, DC: World Bank. https://elibrary.worldbank.org/doi/epdf/10.1596/978-1-4648-1553-9_ch3.

p1773400c74b8e06308c8a00ff3a41dd50c.

———. 2023a. Enterprise Survey for Cambodia. World Bank, Washington, DC. https://www.enterprisesurveys.org/content/dam/enterprisesurveys/documents/country/Cambodia-2023.pdf.

———. 2023b. “Making Teacher Policy Work.” World Bank, Washington, DC.

———. 2024a. Global Economic Prospects, January 2024. Washington, DC: World Bank. https://www.worldbank.org/en/publication/global-economic-prospects.

———. 2024b. East Asia and Pacific Economic Update, April 2024: Firm Foundations for Growth. Washington, DC: World Bank. https://openknowledge.worldbank.org/server/api/core/bitstreams/9bf0f0aa-bd08-4c91-b665-caee561fb5d3/content.

———.2024c. Commodity Markets Outlook. Washington, DC: World Bank, April 25. https://www.worldbank.org/en/research/commodity-markets.

———. 2024d. Firm Foundations of Growth. East Asia and Pacific Economic Update, April. Washington, DC: World Bank.

———. 2024e. “Cambodia Public Finance Review (PFR) – From Spending More to Spending Better,” Chapter 2. World Bank, Washington, DC.

———. 2024f. “Cambodia: Second-Generation Systematic Country Diagnostic Update.” World Bank, Washington, DC. https://www.worldbank.org/en/country/cambodia/publication/cambodia-systematic-country-diagnostic-update.



THE WORLD BANK
IBRD • IDA | WORLD BANK GROUP
East Asia & Pacific